# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ១៧-១៨-១៩-២០

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# សារបណ្ណ

## ព្រះសុត្តន្តបិដក
## ខុទ្ទកនិកាយគាថាធម្មបទ

### គាថាធម្មបទ កោធវគ្គ ទី ១៧ មាន ៨ រឿង


| ល.រ | | ទំព័រ |
|---|---|---|
| ០១ | អារម្ភកថា ............ | ក |
| ០២ | ឧទ្ទិសកថា ............ | គ |
| ០៣ | ព្រះពុទ្ធសាសនាមានអង្គ ៩ ............ | ឃ |
| ០៤ | សារបណ្ណ ............ | ១ |
| ០៥ | គាថាធម្មបទ ក្នុង កោធវគ្គទី ១៧ ............ | ៤ |
| ០៦ | រឿងខត្តិយកញ្ញាឈ្មោះរោហិណី ............ | ៩ |
| ០៧ | រឿងភិក្ខុមួយរូប ............ | ២១ |
| ០៨ | រឿងឧត្តរាឧបាសិកា ............ | ២៧ |
| ០៩ | រឿងបញ្ហារបស់ព្រះមហាមោគ្គល្លាន ............ | ៥០ |
| ១០ | រឿងបញ្ហាភិក្ខុដែលភិក្ខុទូលសួរ ............ | ៥៦ |
| ១១ | រឿងនាងបុណ្ណាទាសី ............ | ៦៥ |
| ១២ | រឿងអតុលឧបាសក ............ | ៧៣ |
| ១៣ | រឿងឆព្វគ្គិយភិក្ខុ ............ | ៨៣ |

## គាថាធម្មបទ មលវគ្គ ទី ១៨ មាន ១២ រឿង


| | | |
|---|---|---|
| ១ | គាថាធម្មបទ ក្នុងមលវគ្គទី ១៨ | ៨៧ |
| ២ | រឿងបុត្ររបស់បុរសអ្នកសម្លាប់គោ | ៩៦ |
| ៣ | រឿងព្រាហ្មណ៍ម្នាក់ | ១០៩ |
| ៤ | រឿងព្រះតិស្សត្ថេរ | ១១៤ |
| ៥ | រឿងព្រះលោឡុទាយី | ១២២ |
| ៦ | រឿងកុលបុត្រម្នាក់ | ១៣០ |
| ៧ | រឿងភិក្ខុឈ្មោះចូឡសារី | ១៣៥ |
| ៨ | រឿងឧបាសក ៥ នាក់ | ១៤៤ |
| ៩ | រឿងភិក្ខុលំលោះឈ្មោះតិស្សៈ | ១៤៩ |
| ១០ | រឿងឧបាសក ៥ នាក់ | ១៥៦ |
| ១១ | រឿងមេណ្ឌកសេដ្ឋី | ១៦៥ |
| ១២ | រឿងឧជ្ឈានសញ្ញិត្ថេរ | ១៨៨ |
| ១៣ | រឿងសុភទ្ទបរិព្វាជក | ១៩១ |


## គាថាធម្មបទ ធម្មដ្ឋវគ្គ ទី ១៩ មាន ... រឿង


| | | |
|---|---|---|
| ១ | គាថាធម្មបទ ក្នុង ធម្មដ្ឋវគ្គទី ១៩ | ១៩៦ |
| ២ | រឿងមហាអមាត្យអ្នកវិនិច្ឆ័យ | ២០៣ |
| ៣ | រឿងឆព្វគ្គិយភិក្ខុ | ២០៩ |
| ៤ | រឿងឯកុទានត្ថេរ | ២១២ |
| ៥ | រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ | ២១៨ |
| ៦ | រឿងភិក្ខុច្រើនរូប | ២២២ |

| | | |
|---|---|---|
| ៧ | រឿងភិក្ខុឈ្មោះហត្ថកៈ | ២២៦ |
| ៨ | រឿងព្រាហ្មណ៍ម្នាក់ | ២៣០ |
| ៩ | រឿងតិត្ថិយ | ២៣៤ |
| ១០ | រឿងព្រានសន្ទូចឈ្មោះអរិយៈ | ២៤០ |
| ១១ | រឿងភិក្ខុច្រើនរូប | ២៤៣ |


## គាថាធម្មបទ ធម្មដ្ឋវគ្គ ទី ២០ មាន ... រឿង


| | | |
|---|---|---|
| ១ | គាថាធម្មបទ ក្នុង មគ្គវគ្គទី ២០ | ២៤៨ |
| ២ | រឿងភិក្ខុ ៥០០ រូប | ២៥៦ |
| ៣ | រឿងភិក្ខុ ៥០០ រូបដទៃទៀត | ២៦៤ |
| ៤ | រឿងព្រះបធានកម្មិកតិស្សត្ថេរ | ២៧០ |
| ៥ | រឿងសូករប្រេត | ២៧៧ |
| ៦ | រឿងព្រះបោឋិលត្ថេរ | ២៩២ |
| ៧ | រឿងព្រះថេរៈចាស់ | ៣០០ |
| ៨ | រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្រ | ៣០៧ |
| ៩ | រឿងឈ្មួញឈ្មោះមហាធនពាណិជ | ៣១៥ |
| ១០ | រឿងនាងកិសាគោតមី | ៣២១ |
| ១១ | រឿងបដាចារា | ៣២៥ |

# គាថាធម្មបទ

## កោធវគ្គទី ១៧

១. កោធំ ជហេ វិប្បជហេយ្យ មានំ
សញ្ញោជនំ សព្វមតិក្កមេយ្យ
តន្នាមរូបស្មិ មសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ ទុក្ខា ។

បុគ្គលគួរលះបង់សេចក្ដីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់បោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គលដែលមិនជំពាក់ក្នុងនាមនិងរូប មិនមានកិលេសគ្រឿងកង្វល់នោះឡើយ ។

២ យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ

**តមហំ សារថឹ ព្រូមិ  រស្មិគ្គាហោ ឥតរោ ជនោ ។**

បុគ្គលណា ឃាត់សេចក្តីក្រោធដែលកើតឡើង ហើយ ដូចសារថីទប់រថ ដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះ ថាជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ ( មិនមែនសារថីឡើយ ) ។

**៣ អក្កោធេន ជិនេ កោធំ  អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន  សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរសដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

**៤ សច្ចំ ភណេ ន កុជ្ឈេយ្យ  ទជ្ជា អប្បស្មិ យាចិតោ**
**ឯតេហិ តីហិ ឋានេហិ  គច្ឆេ ទេវាន សន្តិកេ ។**

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឲ្យ ( តាមតិច ) ១ បុគ្គល គប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយបាន

ដោយហេតុទាំង ៣ នេះឯង ។

**៥ អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**
**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ ( ជាដើម ) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

**៦ សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ**
**និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។**

អាសវៈទាំងឡាយរបស់បុគ្គលអ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

**៧ បោរាណមេតំ អតុល នេតំ អជ្ជតនាមិវ**
**និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ**

មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ ។

ម្នាលអតុល: ការតិះដៀល និងការសរសើរនេះ ជារបស់បូរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ ( ព្រោះថា ) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើន ក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណ ក៏មាន ( អ្នកណាៗ ក៏ដោយ ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយតែក្នុងអតីតទេ និងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តិំ មេធាវឹ បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ

ទេវាបិ នំ បសំសន្តិ  ព្រហ្មុនាបិ  បសំសិតោ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា  ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តដម្កល់ខ្ជាប់ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាគ្រឿងតោរនៃមាសជម្ពូនទ:នោះបាន  សូម្បីទេវតា និងមនុស្សទាំងឡាយ  ក៏សរសើរបុគ្គលនោះ  ទាំងព្រហ្មក៏សរសើរ ( ដូចគ្នា ) ។

៨ កាយប្បកោបំ រក្ខេយ្យ   កាយេន សំវុតោ សិយា
កាយទុច្ចរិតំ  ហិត្វា    កាយេន សុចរិតំ ចរេ
វចីបកោបំ  រក្ខេយ្យ    វាចាយ សំវុតោ សិយា
មនោបកោបំ រក្ខេយ្យ   មនសា សំវុតោ សិយា
មនោទុច្ចរិតំ  ហិត្វា    មនសា សុចរិតំ  ចរេ
កាយេន សំវុតា ធីរា    អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា    តេ វេ សុបរិសំវុតា ។

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួម

កាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកអ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

**កោធវគ្គទី ១៧ ចប់**

# ១៧ កោធវគ្គវណ្ណនា

## ១. រឿងខត្តិយកញ្ញាឈ្មោះរោហិណី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធខត្តិយកញ្ញា ឈ្មោះរោហិណី ត្រាស់ព្រះធម្មទេសនានេះថា “ **កោធំ ជហេ** ” ជាដើម ។

### [ សាងរោងធាន់ជារោគសើស្បែក ]

បានឮថា សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុបាននិមន្តទៅកាន់ក្រុងកបិលពស្តុមួយអន្លើដោយភិក្ខុ ៥០០ ។

គ្រានោះ ក្សត្រិយ៍ជាព្រះញាតិទាំងឡាយរបស់លោកទ្រង់ព្រះសណ្តាប់ថា ព្រះថេរៈនិមន្តមក ក៏បាននាំគ្នាទៅ

កាន់សម្នាក់ព្រះថេរៈ លើកលែងតែប្អូនស្រីរបស់ព្រះថេរៈឈ្មោះ រោហិណី ។ ព្រះថេរៈសួរពួកព្រះញាតិថា “ ព្រះនាង



រោហិណីយាងទៅណា ?” ។

ពួកព្រះញាតិ. បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះនាងនៅក្នុងសម្នាក់ ។

ព្រះថេរៈ. ហេតុអ្វី ទើបមិនយាងមក ?

ពួកព្រះញាតិ. ព្រះនាងមិនយាងមក ព្រោះខ្មាសថា “ រោគសើស្បែកកើតឡើងក្នុងសរីរៈរបស់អញ ” ។

ព្រះថេរៈចាត់ឲ្យហៅមកដោយថេរដីកាថា “ អ្នកទាំងឡាយ ចូរទៅយាងព្រះនាងមកចុះ ” ឲ្យគេទៅយាងព្រះនាងរោហិណីមកហើយ ពោលយ៉ាងនេះទៅកាន់ព្រះនាងដែលជាអ្នកទទួនូវកញ្ចក់ជាវិការៈនៃផ្ទាំងសំពត់ ( ស្បៃ ) ដែលយាងមកហើយថា “ ម្នាលព្រះនាងរោហិណី ហេតុអ្វី ទើបព្រះនាងមិនយាងមក ?” ។

ព្រះនាងរោហិណី. បពិត្រលោកម្ចាស់ដ៏ចម្រើន រោគសើស្បែកកើតឡើងក្នុងសរីរៈរបស់ខ្ញុំព្រះករុណា, ហេតុនោះទើបខ្ញុំព្រះករុណាមិនយាងមក ព្រោះខ្មាសគេ ។

ព្រះថេរៈ. ក៏កិរិយាធ្វើបុណ្យមិនគួរដល់ព្រះនាងឬ ?



ព្រះនាងរោហិណី. បពិត្រលោកម្ចាសដ៏ចម្រើន ខ្ញុំព្រះករុណានឹងធ្វើអ្វី ?

ព្រះថេរៈ. ចូរញុំាងបុគ្គលឲ្យសាងសាលាឆាន់ចុះ ។

ព្រះនាងរោហិណី. ខ្ញុំព្រះករុណាយកអ្វីធ្វើ ?

ព្រះថេរៈ. គ្រឿងប្រដាប់របស់ព្រះនាងមិនមានទេឬ ?

ព្រះនាងរោ. បពិត្រលោកម្ចាស់ដ៏ចម្រើន មាន ។

ព្រះថេរៈ. មានតម្លៃប៉ុន្មាន ?

ព្រះនាងរោហិណី. នឹងមានតម្លៃមួយម៉ឺន ។

ព្រះថេរៈ. បើដូច្នោះ ចូរព្រះនាងលក់គ្រឿងប្រដាប់នោះ ឲ្យគេសាងសាលាឆាន់ចុះ ។

ព្រះនាងរោ. បពិត្រលោកម្ចាស់ដ៏ចម្រើន នរណានឹងឈរបញ្ជាឲ្យគេធ្វើដើម្បីខ្ញុំព្រះករុណា ?

ព្រះថេរៈសម្លឹងមើលព្រះញាតិ ដែលឈរនៅក្នុងទីជិតហើយ ពោលថា “ ភារៈនៃការញ៉ាំងបុគ្គលឲ្យធ្វើសាលាធាន់ ចូរជាភារៈរបស់អ្នកទាំងឡាយចុះ ” ។

ពួកព្រះញាតិ. បពិត្រលោកម្ចាស់ តើលោកម្ចាស់នឹង



ធ្វើអ្វី ?

ព្រះថេរៈ. សូម្បីអាត្មាភាពក៏នៅទីនេះដែរ , បើដូច្នោះអ្នកទាំងឡាយ ចូរនាំទព្វសម្ភារៈមកដើម្បីសាលាធាន់នេះ ។

ពួកព្រះញាតិទទួលព្រមដោយពាក្យថា “ ប្រពៃហើយលោកម្ចាស់ ” លុះពោលដូច្នោះហើយ ក៏នាំទព្វសម្ភារៈមក ។

ព្រះថេរៈ កាលនឹងចាត់ចែងសាលាធាន់នោះ បានពោលទៅកាន់ព្រះនាងរោហិណីថា “ នាងចូរបញ្ជាឲ្យគេធ្វើសាលាធាន់ពីរជាន់ កាលណាជាន់ខាងលើស្រេចហើយ ចូរ

នាងបោសសំអាតផ្ទៃខាងក្រោម ហើយបញ្ជាឲ្យគេក្រាលអាសនៈ , តម្កល់នូវក្អមដែលពេញដោយទឹកឆាន់អស់កាលជានិច្ចចុះ ” ។ ព្រះនាងរោហិណីទទួលព្រមដោយព្រះសវនីយ៍ថា “ ប្រពៃហើយលោកម្ចាស់ ” ហើយចំណាយគ្រឿងប្រដាប់បញ្ជាឲ្យគេធ្វើសាលាឆាន់ពីរជាន់ នៅពេលដែលជាន់ខាងលើរួចស្រេចហើយ ទ្រង់បានធ្វើកិច្ចគ្រប់យ៉ាង មានបោសផ្ទៃខាងក្រោមជាដើមជានិច្ច ។ ពួកភិក្ខុនិមន្តមកគង់រឿយៗដែរ ។

ថ្ងៃក្រោយមក កាលព្រះនាងកំពុងតែបោសសំអាត

*កោធវគ្គវណ្ណនា រឿងខត្តិយកញ្ញាឈ្មោះរោហិណី*

សាលាឆាន់នោះឯង , រោគសើស្បែកក៏ជាសះស្បើយទៅ ។ កាលសាលាឆាន់ស្រេចហើយ ព្រះនាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបានប្រគេនខាទនីយៈនិងភោជនីយៈចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដែលគង់ពេញសាលាឆាន់នោះ ។

ព្រះសាស្ដា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់សួរថា “ នេះជាទានរបស់អ្នកណា ? ” ។

ព្រះអនុរុទ្ធ. បពិត្រព្រះអង្គដ៏ចម្រើន របស់ព្រះនាងរោហិណី ដែលជាប្អូនស្រីរបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្ដា. នាងទៅណា ?

ព្រះអនុរុទ្ធ. បពិត្រព្រះអង្គដ៏ចម្រើន នាងនៅក្នុងដំណាក់ ។

ព្រះសាស្ដា. អ្នកទាំងឡាយ ចូរទៅហៅនាងមក ។

ព្រះនាងមិនប្រាថ្នានឹងយាងមក ។ គ្រានោះ ព្រះ-សាស្ដាឲ្យហៅព្រះនាងដែលមិនប្រាថ្នានឹងយាងមក ឲ្យយាងមកទាល់តែបាន , ព្រះសាស្ដាត្រាស់ទៅកាន់ព្រះនាង ដែល



យាងមកថ្វាយបង្គំហើយ ទ្រង់សួរថា “ ម្នាលនាងរោហិណី ហេតុអ្វី ទើបនាងមិនមក ? ” ។

ព្រះនាងរោហិណី. “ បពិត្រព្រះអង្គដ៏ចម្រើន រោគសើស្បែកកើតឡើងក្នុងសរីរៈរបស់ខ្ញុំព្រះអង្គ ។ ខ្ញុំព្រះអង្គខ្មាសដោយរោគនោះ ទើបខ្ញុំព្រះអង្គមិនមក ” ។

ព្រះសាស្ដា. នាងដឹងទេថា រោគនោះអាស្រ័យកម្មអ្វីរបស់នាង ទើបកើតឡើង ?

ព្រះនាងរោហិណី. ខ្ញុំព្រះអង្គមិនដឹងទេ ព្រះអង្គ ។

ព្រះសាស្ដា. រោគនោះអាស្រ័យសេចក្ដីក្រោធរបស់នាង ទើបកើតឡើង ។

ព្រះនាងរោហិណី. បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គបានធ្វើកម្មអ្វីទុក ?

## [ បុព្វកម្មរបស់ព្រះនាងរោហិណី ]

គ្រានោះ ព្រះសាស្ដាទ្រង់នាំអតីតនិទានមក ( ត្រាស់ដល់ព្រះនាង ) ថា ៖

ក្នុងអតីត ព្រះអគ្គមហេសីនៃព្រះរាជាក្រុងពារាណសី

បានចងគំនុំនឹងស្ត្រីវបាំរបស់ព្រះរាជាម្នាក់ ទ្រង់ព្រះតម្រិះថា “ យើងនឹងញ៉ាំងទុក្ខឲ្យកើតឡើងដល់ស្ត្រីនោះ ” លុះគិតដូច្នោះហើយ ក៏បញ្ជាឲ្យគេនាំផ្លែខ្ទៃមក រួចបញ្ជាឲ្យហៅស្ត្រីរបាំនោះមកកាន់សម្នាក់របស់ខ្លួន ហើយប្រើគេឲ្យដាក់លំអងខ្ទៃទាំងឡាយលើទីដេក លើសំពត់ដណ្តប់ និងក្នុងចន្លោះនៃវត្ថុសម្រាប់ប្រើប្រាស់ទាំងឡាយ មានកម្រាលជាដើមរបស់ស្ត្រីរបាំនោះ ដោយប្រការដែលនាងមិនដឹងខ្លួន ដើរទៅជិតនាងធ្វើដូចជាប្រលែងលេងជាមួយនឹងនាង ហើយរោយលំអងខ្ទៃលើខ្លួនរបស់នាង ភ្លាមៗ នោះឯង សរីរៈរបស់ស្ត្រីរបាំនោះ មានពកតូច និងពកធំកើតឡើង ។ នាងរមាស់រត់ទៅដេកលើទីដេក ។ មិនត្រឹមតែប៉ុណ្ណោះ កាលត្រូវលំអងខ្ទៃបៀតបៀននៅលើទីដេកនោះ វេទនាដ៏ខ្លាំងក្លាក្រៃលែងបានកើតឡើង ។ ព្រះអគ្គមហេសីក្នុងកាលនោះ បានមកជាព្រះនាងរោហិណី ។

ព្រះសាស្តា លុះទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា “ ម្នាលនាងរោហិណី ក៏កម្មនោះនាងបានធ្វើហើយ

**ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ**

ក្នុងកាលនោះ , សេចក្តីក្រោធក្តី សេចក្តីប្រណែនក្តី សូម្បីមានប្រមាណតិចតួច ក៏មិនគួរធ្វើដែរ ” ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

**១ កោធំ ជហេ វិប្បជហេយ្យ មានំ**
**សញ្ញោជនំ សព្វមតិក្កមេយ្យ**
**តន្នាមរូបស្មឹ អសជ្ជមានំ**
**អកិញ្ចនំ នានុបតន្តិ ទុក្ខា ។**

បុគ្គលគប្បីលះបង់សេចក្តីក្រោធចេញ គប្បីលះបង់មានះចេញ គប្បីកន្លងសញ្ញោជនធម៌ទាំងអស់បោលចេញ ទុក្ខទាំងឡាយតែងមិនជាប់តាមបុគ្គលដែលមិនជំពាក់ក្នុងនាម និងរូប មិនមានកិលេសគ្រឿងកង្វល់នោះឡើយ ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កោធំ** សេចក្ដីថា គប្បីលះបង់នូវសេចក្ដីក្រោធ ដែលមានអាការទាំងពួងផង មានៈ ៩ យ៉ាងផង ។

*កោធវគ្គវណ្ណនា រឿងខត្តិយកញ្ញាឈ្មោះរោហិណី*

បទថា **សំយោជនំ** សេចក្ដីថា គប្បីកន្ទងនូវសំយោជនៈទាំង ១០ យ៉ាង មានកាមរាគសំយោជនៈជាដើម ។

បទថា **អសជ្ជមានំ** សេចក្ដីថា មិនជាប់ អធិប្បាយថា បុគ្គលប្រកាន់មាំនូវនាម និងរូបដោយន័យថា “ រូបរបស់យើង , វេទនារបស់យើងជាដើម ហើយកាលនាម និងរូបនោះវិនាសទៅ រមែងសោកសៅក្ដៅក្រហាយ , បុគ្គលនេះឈ្មោះថា ជាប់ជំពាក់នៅក្នុងនាមរូប , ចំណែកបុគ្គលណាមិនប្រកាន់យ៉ាងនោះ ឈ្មោះថា រមែងមិនជាប់ជំពាក់ , ទុក្ខទាំងឡាយ រមែងមិនជាប់តាមបុគ្គលនោះ អ្នកមិនជាប់ជំពាក់

យ៉ាងនោះ បុគ្គលដែលឈ្មោះថា មិនមានកិលេសគ្រឿងកង្វល់ ព្រោះមិនមានរាគៈជាដើម ។

ក្នុងកាលចប់ព្រះធម្មទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

សូម្បីព្រះនាងរោហិណី ក៏បានសម្រេចសោតាបត្តិផលដែរ ។ សរីរៈរបស់នាងមានពណ៌សម្បុរដូចមាសក្នុងខណៈនោះឯង ។ ព្រះនាងចុតិចាកអត្តភាពនោះហើយ បដិ-



សន្ធិក្នុងចន្លោះព្រំដែននៃទេវបុត្រ ៤ អង្គ ក្នុងភពតាវត្តិង្ស ជាទេពធីតានាំមកនូវសេចក្តីជ្រះថ្លា ដល់នូវភាពជាអ្នកលើសដោយលម្អនៃរូប ។ ទេវបុត្រទាំង ៤ អង្គនោះឃើញទេវធីតានោះភ្លាម កើតសេចក្តីស្នេហាឡើង ជជែកគ្នាថា “ នាងកើតក្នុងដែនរបស់យើង , នាងកើតក្នុងដែនរបស់យើង ” ទៅកាន់សម្នាក់សក្កទេវរាជ ក្រាបទូលថា “ បពិត្រទេវរាជ ខ្ញុំព្រះអង្គទាំងបួនកើតក្តីឡើង ព្រោះអាស្រ័យទេវធីតានេះ , សូមព្រះ

អង្គទ្រង់វិនិច្ឆ័យក្តីនោះ ” ។ ចំណែកសក្កទេវរាជ គ្រាន់តែក្រឡេកឃើញនាងទេពធីតានោះភ្លាម ក៏កើតសេចក្តីស្នេហាឡើង ត្រាស់សួរទេវបុត្រទាំងបួននោះយ៉ាងនេះថា “ ចាប់ផ្តើមអំពីកាលដែលពួកអ្នកបានឃើញទេពធីតានេះមក ចិត្តរបស់អ្នកទាំងឡាយ កើតឡើងយ៉ាងណាដែរ ?” ។

គ្រានោះ ទេវបុត្រមួយអង្គក្រាបទូលថា “ ចិត្តរបស់ខ្ញុំព្រះអង្គកើតឡើងដូចជាស្គរក្នុងសង្គ្រាមដំបង មិនអាចស្ងប់ឡើយ ” ។

អង្គទី ២. ចិត្តរបស់ខ្ញុំព្រះអង្គកើតឡើង ដូចជាស្ទឹង

*កោធវគ្គវណ្ណនា រឿងខត្តិយកញ្ញាឈ្មោះរោហិណី*

ដែលហូរអំពីភ្នំ រមែងប្រព្រឹត្តទៅយ៉ាងរហ័ស ។

អង្គទី ៣. ចាប់ដើមអំពីកាលដែលខ្ញុំព្រះអង្គឃើញទេពធីតានេះកាលណា ភ្នែកទាំងពីររបស់ខ្ញុំព្រះអង្គ លៀនចេញ ដូចជាភ្នែកក្តាម ។

អន្ទទី ៤. ចិត្តរបស់ខ្ញុំព្រះអង្គដូចជាទង់ដែលគេតម្លើង នៅលើចេតិយ ។

គ្រានោះ សក្កទេវរាជត្រាស់ទៅកាន់ទេវបុត្រទាំងបួន នោះថា “ នែអ្នកទាំងឡាយ ចិត្តរបស់អ្នកទាំងឡាយនៅអាច អត់សង្កត់បាន ចំណែកយើងកាលបានឃើញទេពធីតានេះ ទើបអាចរស់នៅបាន យើងនឹងស្លាប់ ប្រសិនបើមិនបាន ឃើញទេពធីតានេះ ” ។

ទេវបុត្រទាំងបួននោះក្រាបទូលថា “ បពិត្រមហារាជ ពួកខ្ញុំព្រះអង្គមិនត្រូវការមរណៈរបស់ព្រះអង្គទេ ” លុះក្រាប ទូលសក្កទេវរាជដូច្នោះហើយ ក៏លះបង់ទេវធីតានោះថ្វាយ សក្កទេវរាជ ហើយចៀសចេញទៅ ។ ទេវធីតានោះបានជា ទីស្រឡាញ់របស់សក្កទេវរាជខ្លាំងណាស់ ។ កាលនាងក្រាប

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ទូលថា “ បពិត្រមហារាជ នាងខ្ញុំនឹងទៅកាន់ទីលេងឈ្មោះ ឯណោះ ” សក្កទេវរាជក៏មិនអាចហាមឃាត់បានឡើយ ។

*( រឿងខត្តិយកញ្ញាឈ្មោះរោហិណី ចប់ )*

********************************

# ២ រឿងភិក្ខុមួយរូប

# សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្បែរអគ្គាឡវចេតិយ ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា " **យោ វេ ឧប្បតិតំ កោធំ** " ជាដើម ។

## [ ភិក្ខុកាប់ដើមឈើដែលទេវតានៅ ]

សេចក្តីពិស្តារថា កាលព្រះសាស្តាទ្រង់អនុញ្ញាតសេនាសនៈដល់ភិក្ខុសង្ឃហើយ , ( និង ) កាលសេនាសនៈទាំងឡាយ ដែលសប្បុរសជនទាំងឡាយ មានសេដ្ឋីក្នុងនគររាជគ្រឹះជាដើមកំពុងឲ្យគេកសាង , ភិក្ខុអ្នកនៅក្នុងដែនអាឡវីមួយរូបកសាងសេនាសនៈរបស់ខ្លួន ឃើញដើមឈើមួយដើមដែលជាទីពេញចិត្តហើយ ផ្តើមនឹងកាប់ ។

ទេវតាមានកូនខ្ចីមួយអង្គ ដែលនៅនឹងដើមឈើនោះបីកូនដោយចង្កេះ ឈរអង្វរភិក្ខុនោះថា " បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំកាប់វិមានរបស់ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណាមិនមានលំនៅទេ " ។

ភិក្ខុនោះគិតថា “ យើងនឹងមិនបានដើមឈើដូច្នេះក្នុងទីដទៃទេ ” ទើបមិនអើពើនឹងពាក្យរបស់ទេវតានោះ ។

ទេវតានោះគិតថា “ ភិក្ខុនេះឃើញទារកនេះហើយនឹងឈប់ដោយពិត ” ទើបដាក់កូនលើមែកឈើ ។ ចំណែកភិក្ខុនោះ មិនអាចទប់ពូថៅដែលខ្លួនលើកឡើងហើយបាន ទើបកាប់ដៃទារកនោះដាច់ ទេវតាកើតសេចក្ដីក្រោធយ៉ាងខ្លាំង លើកដៃទាំងពីរឡើងដោយធ្វើទុកក្នុងចិត្តថា “ នឹងប្រហារភិក្ខុនេះឲ្យស្លាប់ ” ប៉ុន្តែភ្លាមៗ នោះ ទេវតានោះគិតឃើញយ៉ាងនេះថា “ ភិក្ខុនេះជាអ្នកមានសីល ប្រសិនបើអញសម្លាប់ភិក្ខុនេះឲ្យស្លាប់ អញនឹងទៅកាន់នរក , សូម្បីទេវតាដ៏សេសកាលជួបភិក្ខុកាត់ដើមឈើរបស់ខ្លួន នឹងធ្វើអញឲ្យជាប្រមាណថា ទេវតាឯណោះសម្លាប់ភិក្ខុដែរ ហើយនឹងសម្លាប់ភិក្ខុទាំងឡាយដូចយើងដែរ , ភិក្ខុនេះជាអ្នកមានម្ចាស់ យើងទៅប្រាប់ដល់ម្ចាស់របស់ភិក្ខុនេះ ” ។ ដាក់ដៃដែលលើកឡើង ហើយ

យាំដើរទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរមួយ ។

*គោធវគ្គវណ្ណនា រឿងភិក្ខុមួយរូប*

គ្រានោះ ព្រះសាស្ដា ត្រាស់ទៅកាន់ទេវតានោះថា " ម្នាលទេវតា អ្នកមានរឿងអ្វី ?" ទេវតានោះក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន សាវករបស់ព្រះអង្គ ធ្វើកម្មបែបនេះ , ចំណែកខ្ញុំព្រះអង្គក៏ប្រាថ្នានឹងញុំាងសាវករបស់ព្រះអង្គឲ្យស្លាប់ ប៉ុន្តែគិតនូវហេតុនេះបាន ទើបមិនសម្លាប់ ហើយប្រញាប់មកកាន់សម្នាក់ព្រះអង្គ " ដូច្នេះហើយ ក៏ក្រាបទូលរឿងនោះទាំងអស់ដោយពិស្ដារ ។

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ត្រាស់ថា " ម្នាលទេវតា ត្រូវហើយៗ ទេវតាឯងគ្របសង្កត់សេចក្ដីក្រោធ ដែលកើតឡើងហើយយ៉ាងនោះទុក ដូចជាឃាត់រថដែលលឿនជ្រុលបាន ឈ្មោះថា បានធ្វើកម្មដ៏ប្រពៃហើយ " ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

២ យោ វេ ឧប្បតិតំ កោធំ  រថំ ភន្តំវ ធារយេ
តមហំ សារថឹ ព្រូមិ  រស្មិគ្គាហោ ឥតរោ ជនោ ។
បុគ្គលណាឃាត់សេចក្ដីក្រោធ ដែលកើតឡើង
ហើយ  ដូចសារថីទប់រថ  ដែលកំពុងលឿនបាន

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

តថាគតហៅបុគ្គលនោះថា ជាសារថី ជនក្រៅនេះ
គ្រាន់តែជាអ្នកកាន់ខ្សែបរ ( មិនមែនសារថីឡើយ ) ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឧប្បតិតំ** បានដល់ ដែលកើតឡើងហើយ ។

ពីរបទថា **រថំ ភន្តំវ** សេចក្ដីថា ដូចសារថីដែលច្លាតទប់រថ ដែលកំពុងលឿនបានតាមត្រូវការ យ៉ាងណាមិញ , បុគ្គលណាគ្រប់សង្កត់  គឺអាចឃាត់សេចក្ដីក្រោធដែលកើតឡើងបាន ក៏ដូច្នោះដែរ ។

បទថា **តមហំ** តថាគតហៅបុគ្គលនោះថា សារថី ។

ពីរបទថា **ឥតរោ ជនោ** សេចក្ដីថា ចំណែកជនក្រៅនេះ គឺសារថី រថរបស់ឥស្សរជនទាំងឡាយ មានព្រះរាជានិងឧបរាជជាដើម គ្រាន់តែមានឈ្មោះថា ជាអ្នកកាន់ខ្សែបរប៉ុណ្ណោះ មិនមែនជាសារថីដ៏ខ្ពង់ខ្ពស់ឡើយ ។

ក្នុងកាលចប់ទេសនា ទេវតានោះតាំងនៅក្នុងសោតាបត្តិផល , ទេសនាបានជាកថាមានប្រយោជន៍ សូម្បីដល់

*កោធវគ្គវណ្ណនា រឿងភិក្ខុមួយរូប*

បរិស័ទដែលប្រជុំគ្នានៅទីនោះ ។

ចំណែកទេវតានោះ សូម្បីបានជាព្រះសោតាបន្នហើយក៏ដោយ ក៏នៅតែឈរយំ ។ គ្រានោះ ព្រះសាស្ដា ត្រាស់សួរទេវតានោះថា “ ម្នាលទេវតា អ្នកមានបញ្ហាអ្វី ?” កាលទេវតាក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន វិមានរបស់ខ្ញុំព្រះអង្គវិនាសហើយ , ឥឡូវនេះ ខ្ញុំព្រះអង្គនឹងធ្វើដូចម្ដេច ?” ទើបទ្រង់ត្រាស់ថា “ម្នាលទេវតា អ្នកកុំព្រួយ តថាគតនឹងឲ្យវិមានដល់អ្នក ” ហើយទ្រង់ចង្អុលបង្ហាញដើមឈើមួយដើម

ដែលទេវតាចុតិកាលពីថ្ងៃមុន ក្នុងទីជិតព្រះគន្ធកុដិ ក្នុងវត្តជេតពន ហើយត្រាស់ថា “ម្នាលទេវតា ដើមឈើក្នុងឱកាសឯណោះទំនេរ , អ្នកចូរចូលទៅនៅឰដ៏ដើមឈើនោះចុះ ” ។ ទេវតានោះ ក៏បានទៅនៅឰដ៏ដើមឈើនោះតាមព្រះតម្រាស់របស់ព្រះមានព្រះភាគ ។ ចាប់តាំងពីពេលនោះមក ទេវតាដែលមានសក្តិធំៗ ក៏បានជ្រាបថា “ វិមានរបស់ទេវតានេះ ព្រះមានព្រះភាគ ទ្រង់ប្រទានឲ្យ ” ក៏មិនអាចមកធ្វើទេវតានោះឲ្យកម្រើកបាន ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ព្រះសាស្តា ទ្រង់ធ្វើរឿងនោះឲ្យជាហេតុកើតឡើង ហើយ ទ្រង់បញ្ញត្តកូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ។

( រឿងភិក្ខុមួយរូប ចប់ )

****************

# ៣ រឿងខុជ្ជុត្តរាឧបាសិកា

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ធ្វើកត្ត-កិច្ចក្នុងផ្ទះរបស់នាងឧត្តរាហើយ ទ្រង់ប្រារព្ធឧបាសិកាឧត្តរា ត្រាស់ទេសនានេះថា “ **អក្កោធេន ជិនេ កោធំ** ” ជាដើម ។

## [ នាយបុណ្ណៈសម្បត្តិត្រូវបម្រើសុមនសេដ្ឋី ]

អនុបុព្វីកថាក្នុងរឿងឧត្តរាឧបាសិកានោះ មានដូចត-ទៅនេះ :

បានឮថា បុរសកម្សត់ឈ្មោះបុណ្ណៈ អាស្រ័យសុមន-សេដ្ឋី ដែលមានប្រក្រតីនៅក្នុងក្រុងរាជគ្រឹះ ធ្វើការឈ្នួលចិញ្ចឹមជីវិត ។ ក្នុងផ្ទះរបស់គាត់មានមនុស្សពីរនាក់ប៉ុណ្ណោះ គឺភរិយារបស់គាត់ និងធីតាឈ្មោះឧត្តរាម្នាក់ ។

ក្រោយមក ពួករាជបុរសដើរឃោសនាក្នុងក្រុងរាជ-គ្រឹះថា " អ្នកនគរទាំងអស់ចូរនាំគ្នាលេងនក្ខត្តឫក្ស ៧ ថ្ងៃចុះ " សុមនសេដ្ឋីបានឮការឃោសនានោះហើយ ក៏ហៅនាយបុណ្ណៈមកពីព្រលឹមប្រាប់ថា " នែ បា ជនជាបរិវាររបស់ខ្ញុំ គេប្រាថ្នា

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

នឹងលេងនក្ខត្តឫក្ស , ឯងនឹងលេងនក្ខត្តឫក្សជាមួយនឹងគេឬ ឬក៏នឹងធ្វើការឈ្នួល ?" ។

នាយបុណ្ណៈ. បពិត្រនាយ ដែលឈ្មោះថា ការលេង នក្ខត្តឫក្សនោះ ជារបស់ពួកអ្នកដែលមានទ្រព្យទេ , ក៏ក្នុងផ្ទះរបស់ខ្ញុំ សូម្បីតែអង្ករសម្រាប់បបរទទួលទានក្នុងថ្ងៃស្អែកនេះ មិនទាន់មានផង ។ ប្រយោជន៍អ្វីដោយនក្ខត្តឫក្សដល់ខ្ញុំនោះ ? ខ្ញុំបានគោហើយ ក៏នឹងទៅភ្ជួរ ។

សុមនសេដ្ឋី. បើដូច្នោះ ឯងចូរទទួលយកគោចុះ ។

នាយបុណ្ណៈ ទទួលយកគោដ៏មានកម្លាំង និងនង្គ័ល ហើយ និយាយទៅកាន់ភរិយាថា “ នែនាងដ៏ចម្រើន អ្នកនគរគេនាំគ្នាលេងនក្ខត្តឫក្ស , ខ្ញុំត្រូវទៅធ្វើការឈ្នួល ព្រោះយើងជាមនុស្សក្រ , ថ្ងៃនេះនាងគប្បីចំអិនបន្លែឲ្យជាទ្វេគុណ ហើយនាំយកទៅឲ្យខ្ញុំ និយាយជាមួយភរិយាដូច្នេះហើយ ទើបទៅស្រែ ។

## [ ព្រះសារីបុត្តត្រេកអរនាយបុណ្ណៈ ]

ក្នុងកាលនោះ ព្រះសារីបុត្រចូលនិរោធសមាបត្តិអស់

៧ ថ្ងៃ ហើយក្នុងថ្ងៃនោះ ចេញអំពីនិរោធសមាបត្តិ រមិលមើលថា “ ថ្ងៃនេះ យើងគួរសង្គ្រោះអ្នកណាហ្ន៎ ” ឃើញនាយបុណ្ណៈចូលទៅក្នុងសំណាញ់ គឺញាណរបស់ខ្លួនហើយក៏ពិចារណាថា “ នាយបុណ្ណៈនេះ មានសទ្ធាឬហ្ន៎ គេអាចសង្គ្រោះយើងឬហ្ន៎ ” ដឹងថា នាយបុណ្ណៈមានសទ្ធា អាចសង្គ្រោះបាន ហើយគេនឹងបានទទួលសម្បត្តិដ៏ធំ ព្រោះបុណ្យនោះជាបច្ច័យ ហើយទើបកាន់បាត្រ និងចីវរទៅកាន់ទីកន្លែងស្រែរបស់នាយបុណ្ណៈ ឈរសម្លឹងមើលគុម្ពឈើ មួយគុម្ពជិតមាត់រណ្តៅ ។ នាយបុណ្ណៈឃើញព្រះថេរៈហើយ បញ្ឈប់ការភ្ជួរ ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ហើយគិតថា “ ព្រះថេរៈគង់នឹងត្រូវការឈើស្ទន់ ” ទើបធ្វើឈើស្ទន់ឲ្យជាកប្បិយៈ ហើយប្រគេនព្រះថេរៈ ។

គ្រានោះ ព្រះថេរៈបាននាំយកបាត្រ និងសំពត់តម្រងទឹកចេញមកឲ្យនាយបុណ្ណៈ ។ នាយបុណ្ណៈគិតថា “ ព្រះថេរៈ

ត្រូវការទឹក " ទើបទទួលយកបាត្រ និងសំពត់តម្រងទឹកនោះ មកត្រងទឹកធាន់ប្រគេនព្រះថេរៈ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ព្រះថេរៈគិតថា " នាយបុណ្ណៈនេះ នៅផ្ទះខាងក្រោយនៃជនដទៃ, ប្រសិនបើយើងទៅកាន់ផ្ទះរបស់គេ ភរិយារបស់គេនឹងមិនបានឃើញយើង , យើងត្រូវនៅទីនេះ ដរាបណាភរិយារបស់គេនាំភត្តមកជូនគេ " ព្រះថេរៈបានញ៉ាំងកាលឲ្យកន្លងទៅបន្តិចបន្តួចនៅទីនោះ បានដឹងថា ភរិយារបស់នាយបុណ្ណៈឡើងកាន់ផ្លូវហើយ ក៏និមន្តចូលទៅកាន់ព្រះនគរ ។

## [ ភរិយារបស់នាយបុណ្ណៈប្រគេនភត្តព្រះថេរៈ ]

នាងជួបព្រះថេរៈក្នុងចន្លោះផ្លូវហើយ គិតថា " ពេលខ្លះ ទេយ្យធម៌មាន , យើងមិនបានជួបព្រះថេរៈ , ពេលខ្លះយើងបានជួបព្រះថេរៈ , តែទេយ្យធម៌មិនមាន , ក្នុងថ្ងៃនេះយើងបានជួបព្រះថេរៈហើយ ទាំងទេយ្យធម៌ក៏មាន , ព្រះថេរៈនឹងអនុគ្រោះយើងឬហ្ន៎ ?" នាងដាក់ភាជនៈភត្តចុះ ថ្វាយបង្គំ

ព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំគិតថា ភត្តនេះសៅហ្មង ឬប្រណីតឡើយ សូមធ្វើសេចក្តីអនុគ្រោះទាសៈរបស់លោកម្ចាស់ចុះ ” ។

*គោធវគ្គវណ្ណនា រឿងឧបាសិកាឧត្តរា*

ព្រះថេរៈបង្អោនបាត្រចូលទៅ នាងយកដៃម្ខាងទ្រភាជនៈ ប្រគេនភត្តព្រះថេរៈដោយដៃម្ខាងទៀត , កាលនាងប្រគេនភត្តបានពាក់កណ្តាល ព្រះថេរៈក៏យកដៃបិទបាត្រដោយនិយាយថា “ ល្មមហើយ ” នាងពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ភត្តមានតែមួយចំណែក ខ្ញុំព្រះករុណាមិនអាចធ្វើឲ្យជាពីរចំណែកបានទេ , លោកម្ចាស់កុំអនុគ្រោះទាសៈរបស់លោកម្ចាស់ក្នុងលោកនេះអី សូមធ្វើនូវសេចក្តីអនុគ្រោះក្នុងបរលោកចុះ , ខ្ញុំព្រះករុណាប្រាថ្នាប្រគេនមិនឲ្យសេសសល់”ដូច្នេះហើយ បានដាក់ភត្តទាំងអស់ទៅក្នុងបាត្ររបស់ព្រះថេរៈ ហើយធ្វើសេចក្តីប្រាថ្នាថា “ ខ្ញុំព្រះករុណា

គប្បីជាអ្នកមានចំណែកនៃធម៌ ដែលលោកម្ចាស់បានឃើញហើយផងចុះ ” ។

ព្រះថេរៈពោលថា “ចូរសម្រេចតាមសេចក្ដីប្រាថ្នាចុះ” ឈរនៅទីនោះឯង ធ្វើអនុមោទនាហើយ បានគង់ធ្វើភត្តកិច្ច នៅក្នុងទីសប្បាយដោយទឹកមួយកន្ទែង ។

ចំណែកនាងត្រឡប់ទៅស្វែងរកអង្ករ ចំអិនភត្តជាថ្មី ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ចំណែកនាយបុណ្ណៈភ្ជួរស្រែបានប្រមាណកន្លះករីស មិនអាចអត់ទ្រាំនឹងសេចក្ដីស្រេកឃ្លានបាន ក៏ដោះគោ ចូលទៅកាន់ម្លប់ឈើមួយដើម អង្គុយទន្ទឹងមើលផ្លូវភរិយា ។

គ្រានោះ ភរិយារបស់គាត់កាន់ភត្តដើរទៅ លុះឃើញគាត់ក៏គិតថា “ស្វាមីរបស់យើងត្រូវសេចក្ដីស្រេកឃ្លានបៀតបៀន អង្គុយទន្ទឹងមើលផ្លូវយើង , ប្រសិនបើគាត់នឹងគំរាមយើងថា “ នាងឯងយូរម្ល៉េះ ហើយយកជន្ទញប្រហារយើង , កម្មដែលយើងធ្វើហើយ នឹងជារបស់ឥតប្រយោជន៍ , ដូច្នេះ

យើងនឹងប្រាប់ស្វាមីរបស់យើង ឲ្យបានមុនតែម្តង ” ដូច្នេះ ហើយ ទើបពោលយ៉ាងនេះថា “ បពិត្រស្វាមី សូមអ្នកញុាំងចិត្តឲ្យជ្រះថ្លាក្នុងថ្ងៃមួយនេះចុះ , សូមអ្នកកុំញុាំងកម្មដែលខ្ញុំធ្វើហើយឲ្យឥតប្រយោជន៍ឡើយ , តាមពិតនោះ ខ្ញុំបាននាំភត្តមកជូនអ្នកតាំងអំពីព្រលឹមម៉្លេះ ប៉ុន្តែមកតាមផ្លូវខ្ញុំបានជួបព្រះធម្មសេនាបតីក្នុងចន្លោះផ្លូវ ខ្ញុំក៏យកភត្តរបស់អ្នកប្រគេនព្រះថេរៈនោះ ហើយត្រឡប់ទៅចំអិនភត្តជាថ្មី , សូមញុាំងចិត្តឲ្យជ្រះថ្លាចុះ នាយ ” នាយបុណ្ណៈសួរភរិយាថា “ នែ នាងដ៏



ចម្រើន នាងនិយាយអ្វី ? ” បានស្តាប់រឿងនោះម្តងទៀត ហើយ ក៏ពោលថា “ នែនាងដ៏ចម្រើន នាងបានប្រគេនភត្តរបស់យើងដល់លោកម្ចាស់ នាងបានធ្វើកម្មដ៏ប្រពៃហើយ , ពីព្រឹកមិញ ខ្ញុំក៏បានប្រគេនឈើជម្រះធ្មេញ និងទឹកខ្ពុរមាត់ដល់លោកម្ចាស់ដែរ ” មានចិត្តជ្រះថ្លា ត្រេកអរ រីករាយនឹងពាក្យនោះហើយ ជាអ្នកមានកាយនឿយហត់ ព្រោះបានភត្ត

ក្នុងវេលាថ្ងៃពេក យកក្បាលកើយភ្លៅភរិយា ហើយក៏លក់ទៅ ។

## [ ទានរបស់ស្វាមីភរិយាឲ្យផលក្នុងថ្ងៃនោះ ]

គ្រានោះ ទីដែលនាយបុណ្ណៈភ្ជួរអំពីព្រលឹមនោះ បានក្លាយទៅជាដុំមាសទាំងអស់ រហូតដល់លំអិតអាចម៍ដី តាំងនៅដូចជាគំនរផ្កាកណិការ ។ នាយបុណ្ណៈភ្ញាក់ឡើង ក្រឡេកឃើញ ក៏និយាយទៅកាន់ភរិយាថា " ម្នាលនាងដ៏ចម្រើន ទីដែលខ្ញុំភ្ជួរហើយនោះ ប្រាកដដល់ខ្ញុំជាមាសទាំងអស់, ព្រោះខ្ញុំបានកត្តក្នុងវេលាថ្ងៃពេក ភ្នែករបស់ខ្ញុំស្រវាំងទេដឹង ? " ។

ចំណែកភរិយារបស់គាត់ក៏ពោលថា " បពិត្រស្វាមី



មាសមានពណ៌ក្រហមក៏បានប្រាកដដល់ខ្ញុំដូច្នោះដែរ " ។

នាយបុណ្ណៈក្រោកឡើងដើរទៅកាន់ទីនោះ ចាប់យកមួយដុំ វាយនឹងក្បាលនង្គ័ល ហើយដឹងថាជាមាស ទើបគិតថា " ឱ ! ទានដែលយើងធ្វើហើយចំពោះព្រះធម្មសេនាបតី

ឲ្យផលក្នុងថ្ងៃនេះឯង , យើងមិនអាចបិទបាំងទ្រព្យ មានប្រមាណប៉ុណ្ណេះទុកប្រើប្រាស់បានទេ ” ទើបយកមាសដាក់ពេញថាសកត្តដែលករិយានាំមក ហើយទៅកាន់រាជត្រកូល បានឱកាសដែលព្រះរាជាព្រះរាជទានឲ្យហើយ ចូលទៅថ្វាយព្រះរាជា , កាលព្រះរាជាត្រាស់សួរថា “ នែបា អ្នកឯងមានការអ្វី ?” ទើបក្រាបទូលថា “ បពិត្រព្រះសម្មតិទេព ទីដែលខ្ញុំព្រះអង្គភ្ជួរហើយ ក្នុងថ្ងៃនេះទាំងអស់ ជាទីពេញទៅដោយមាសទាំងអស់ , ព្រះអង្គគួរបញ្ជារាជបុរស ឲ្យទៅនាំយកមកទុក ” ។

ព្រះរាជា. អ្នកជានរណា ?

នាយបុណ្ណៈ. ខ្ញុំព្រះអង្គជាទុគ្គតបុរសឈ្មោះបុណ្ណៈ ។

ព្រះរាជា. ក៏ថ្ងៃនេះ អ្នកបានធ្វើកម្មអ្វី ?



នាយបុណ្ណៈ.ខ្ញុំព្រះអង្គបានប្រគេនឈើជម្រះធ្មេញ និងទឹកខ្ពុរមាត់ចំពោះព្រះធម្មសេនាបតីអំពីព្រលឹម , មិនត្រឹមតែ

ប៉ុណ្ណោះទេ កិរិយារបស់ខ្ញុំព្រះអង្គបានប្រគេនភត្តដែលនាង នាំមកដើម្បីខ្ញុំព្រះអង្គចំពោះព្រះធម្មសេនាបតីដែរ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយត្រាស់ថា " នែ បា យើងនឹងធ្វើដូចម្តេចទៅ ? " ។

សូមព្រះអង្គទ្រង់បញ្ជូនរទេះច្រើនពាន់ ទៅនាំយកមាសនោះមកចុះ ។

ព្រះរាជា ទ្រង់បានបញ្ជូនរទេះជាច្រើនទៅកាន់ទីនោះ ។ កាលរាជបុរសកាន់យកដោយពាក្យថា " របស់ព្រះរាជា " មាសដែលរាជបុរសកាន់យកហើយនោះៗ ទៅជាដីដូចដើមវិញ ។ ពួករាជបុរសទៅក្រាបទូលព្រះរាជា ព្រះរាជាត្រាស់សួរថា " ពួកអ្នកពោលពាក្យដូចម្តេច ? ទើបកាន់យក " ក៏ក្រាបទូលថា " ពួកខ្ញុំព្រះអង្គបានពោលពាក្យថា ជាព្រះរាជទ្រព្យរបស់ព្រះអង្គ " ។

ព្រះរាជាត្រាស់ថា នែ អ្នកទាំងឡាយ ទុំះមិនមែនជា

ទ្រព្យរបស់យើងទេ , អ្នកទាំងឡាយចូរទៅ , ចូរពោលពាក្យថា ជាទ្រព្យរបស់នាយបុណ្ណៈ ហើយកាន់យកចុះ ។

ពួករាជបុរសបានធ្វើហើយ ដោយប្រការដូច្នោះ ។

មាសដែលពួកគេកាន់យកហើយនោះ ក៏បានជាទៅមាសពិតៗ ។ ពួករាជបុរស បានជញ្ជូនមាសទាំងអស់នោះមកធ្វើជាគំនរព្ទដ៏លានៃព្រះរាជវាំង ( មាសទាំងអស់នោះ ) បានជាគំនរមានកម្ពស់ប្រមាណ ៨០ ហត្ថ ។

## [ នាយបុណ្ណៈបានទទួលតំណែងជាសេដ្ឋី ]

ព្រះរាជា ទ្រង់បញ្ជាឲ្យអ្នកនគរប្រជុំគ្នា ហើយត្រាស់សួរថា “ នៅក្នុងនគរនេះ អ្នកដែលមានមាសប្រមាណប៉ុណ្ណេះ មានដែរឬ ?” ។

អ្នកនគរ. បពិត្រមហារាជ មិនមានទេ ។

ព្រះរាជា. ក៏យើងនឹងឲ្យអ្វីដល់នាយបុណ្ណៈ ទើបគួរ ?

អ្នកនគរ. ឆត្រសម្រាប់សេដ្ឋី ព្រះអង្គ ។

ព្រះរាជា ទ្រង់ត្រាស់ថា “ នាយបុណ្ណៈ ចូរជាសេដ្ឋី ឈ្មោះពហុធនសេដ្ឋី ” ហើយបានព្រះរាជទានឆត្រសម្រាប់

*កោធវគ្គវណ្ណនា រឿងឧបាសិកាឧត្តរា*

សេដ្ឋី មួយអន្ទើដោយភោគៈដ៏ច្រើនដល់គាត់ ។

គ្រានោះ គាត់បានក្រាបទូលព្រះរាជាថា “ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយអាស្រ័យនៅក្នុងត្រកូលដទៃអស់កាលមានប្រមាណប៉ុណ្ណោះ , សូមព្រះអង្គព្រះរាជទាននូវទីលំនៅដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ” ។

ព្រះរាជាត្រាស់ថា “ បើដូច្នោះ អ្នកចូរមើលគុម្ពឈើដែលនៅខាងស្តាំអ្នក , ចូរនាំយកគុម្ពឈើនោះចេញ ហើយឲ្យជាងធ្វើផ្ទះនៅទីនោះចុះ ” ។ ដូច្នេះហើយ ត្រាស់ប្រាប់នូវទីផ្ទះរបស់សេដ្ឋីជំនាន់ចាស់ ។

បុណ្ណសេដ្ឋីឲ្យជាងធ្វើផ្ទះក្នុងទីនោះ ដោយ ២-៣ ថ្ងៃប៉ុណ្ណោះ កាលធ្វើគេហប្បវេសនមង្គល ( មង្គលជាទីចូលកាន់ផ្ទះ ) និងឆត្រមង្គល ( មង្គលជាទីទទួលឆត្រ ) បាន

ថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ។ គ្រានោះ ព្រះសាស្តា មុននឹងទ្រង់ធ្វើអនុមោទនាចំពោះទានបុណ្ណសេដ្ឋីនោះ បានត្រាស់អនុបុព្វីកថា ។

ក្នុងកាលចប់ទេសនា ជនទាំង ៣ នាក់ គឺបុណ្ណសេដ្ឋី

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

១ ភរិយារបស់បុណ្ណសេដ្ឋី ១ នាងឧត្តរាដែលជាធីតារបស់បុណ្ណសេដ្ឋី ១ បានជាសោតាបន្ន ។

## [ ធីតាបុណ្ណសេដ្ឋីបានជាភរិយាបុត្ររបស់សុមនសេដ្ឋី ]

ក្រោយមក សេដ្ឋីក្នុងក្រុងរាជគ្រឹះដណ្តឹងធីតារបស់បុណ្ណសេដ្ឋីឲ្យបុត្ររបស់ខ្លួន ។ បុណ្ណសេដ្ឋីពោលថា “ ខ្ញុំឲ្យមិនបានទេ ”, កាលសេដ្ឋីក្នុងក្រុងរាជគ្រឹះពោលថា “ លោកកុំធ្វើយ៉ាងនោះឡើយ , លោកអាស្រ័យខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ ទើបបានសម្បត្តិនេះ , ចូរឲ្យធីតាដល់បុត្ររបស់ខ្ញុំចុះ ” ទើបពោលថា “ បុត្ររបស់លោកជាមនុស្ស

មិច្ឆាទិដ្ឋិ ចំណែកធីតារបស់ខ្ញុំឃ្លាតឆ្ងាយអំពីព្រះរតនៈទាំងបី ហើយ រស់នៅមិនបាន, ទើបខ្ញុំលើកធីតាឲ្យបុត្ររបស់លោក មិនបាន " ។ គ្រានោះ កុលបុត្រទាំងឡាយ មានសេដ្ឋី និង គហបតីជាដើមអង្វរបុណ្ណសេដ្ឋីថា " នែបុណ្ណៈ សូមលោកកុំ ទម្លាយនូវសេចក្តីស្និទ្ធស្នាលនឹងសេដ្ឋីក្នុងក្រុងរាជនោះ , ចូរ លើកធីតាឲ្យបុត្ររបស់គេចុះ " ។ បុណ្ណសេដ្ឋីទទួលយល់

*គោធវត្ថុវណ្ណនា រឿងឧបាសិកាឧត្តរា*

ព្រមតាមពាក្យរបស់កុលបុត្រទាំងនោះហើយ បានលើកធីតា ឲ្យក្នុងតិថី ពេញបូរមីខែអាសាឍ ។

នាងមិនបានដើម្បីនឹងចូលទៅរកភិក្ខុ ឬភិក្ខុនី ឬថ្វាយ ទាន ឬក៏ស្តាប់ធម៌ឡើយ ចាប់តាំងអំពីកាលដែលនាងទៅ កាន់ត្រកូលស្វាមី ។ កាលកន្លងទៅបាន ២ ខែកន្លះ ដោយ អាការយ៉ាងនេះ ។ ទើបសួរស្ត្រីបម្រើក្នុងសម្នាក់នោះថា " ពេលនេះខាងក្នុងវស្សានៅសល់ប៉ុន្មានទៀត ?" ។

ស្ត្រីបម្រើ. បពិត្រនាងម្ចាស់ នៅសល់កន្លះខែទៀត ។

នាងបញ្ជូនដំណឹងទៅប្រាប់បិតារបស់នាងថា “ ហេតុដូចម្ដេច ទើបបិតាយកខ្ញុំមកដាក់គុកយ៉ាងនេះ ? ការបិតាប្រកាសខ្ញុំថាជាស្ត្រីខាតលក្ខណ៍ ហើយធ្វើឲ្យជាទាសីនៃជនពួកដទៃ នៅប្រសើរជាង , ការបិតាលើកខ្ញុំឲ្យទៅត្រកូលមិច្ឆាទិដ្ឋិបែបនេះ មិនប្រសើរឡើយ, តាំងពីខ្ញុំមកកាន់ត្រកូលនេះកាលណា ខ្ញុំមិនដែលបានធ្វើបុណ្យសូម្បីក្នុងបុញ្ញកម្មទាំងឡាយ មានការឃើញ ការជួបភិក្ខុទាំងឡាយឡើយ ” ។

គ្រានោះ បិតារបស់នាងសម្ដែងការមិនសប្បាយចិត្ត

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

ដោយគិតថា “ ធីតារបស់យើងដល់នូវសេចក្ដីទុក្ខ ” ទើបបញ្ជូនទ្រព្យទៅ ១៥,០០០ កហាបណៈ ដោយផ្ដាំថា “ ក្នុងនគរនេះ មានស្ត្រីគណិកា ( ស្រីបន ) ឈ្មោះសិរិមា , កូនឯងចូរនិយាយនឹងនាងថា នាងចូរទទួលយកទ្រព្យមួយថ្ងៃមួយពាន់កហាបណៈចុះ នាំនាងមកដោយកហាបណៈទាំងនេះ ឲ្យ

ធ្វើជាស្ត្រីបម្រើជើងស្វាមីរបស់កូនឯង ហើយចំណែកកូនឯង ចូរធ្វើបុណ្យទាំងឡាយចុះ ” ។

នាងប្រើគេឲ្យហៅនាងសិរិមាមកហើយ ពោលថា “នៃសម្លាញ់ នាងចូរទទួលយកកហាបណៈទាំងនេះ ហើយចូរបម្រើបុរសជាសម្លាញ់របស់នាងអស់កន្លះខែនេះចុះ ” ។

នាងសិរិមានោះ យល់ព្រមដោយពាក្យថា “ ប្រពៃហើយ ”។ នាងឧត្តរានាំនាងសិរិមាទៅកាន់សម្នាក់ស្វាមីរបស់ខ្លួន កាលស្វាមីរបស់នាងឃើញនាងសិរិមាមក ក៏សួរថា “ នៃនាងឧត្តរា តើនាងមានបញ្ហាអ្វី ? ” នាងក៏ប្រាប់ថា “ បពិត្រស្វាមី ខ្ញុំសូមឲ្យស្ត្រីដែលជាសម្លាញ់របស់ខ្ញុំ បម្រើអ្នកអស់កន្លះខែនេះ , ចំណែកខ្ញុំប្រាថ្នានឹងថ្វាយទាន និងស្តាប់ធម៌អស់



កន្លះខែនេះ ” ។

សេដ្ឋីបុត្រឃើញនាងសិរិមាមានរូបល្អ កើតសេចក្តីស្នេហា ក៏យល់ព្រមដោយពាក្យថា “ ប្រពៃហើយ នាង ”។

## [ នាងឧត្តរាបានឱកាសធ្វើបុណ្យ ]

ចំណែកនាងឧត្តរា និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំស្ដេចទៅកាន់ទីដទៃឡើយ សូមព្រះអង្គទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គអស់កន្លះខែនេះចុះ ” បានទទួលពាក្យប្ដេជ្ញាអំពីព្រះសម្មាសម្ពុទ្ធហើយ មានចិត្តត្រេកអរថា “ ឥឡូវនេះអញនឹងបានបម្រើព្រះសាស្ដាផង ស្ដាប់ធម៌ផង តាំងពីពេលនេះទៅ រហូតដល់ថ្ងៃមហាបវារណា ” ចាត់ចែងនូវកិច្ចទាំងពួងក្នុងជនអ្នកចំអិនភោជនាហារថា “ អ្នកទាំងឡាយ ចូរចំអិនបបរយ៉ាងនេះ ចូរចំអិននំយ៉ាងនេះ ” ។

គ្រានោះ ស្វាមីរបស់នាងគិតថា “ ថ្ងៃនេះជាថ្ងៃមហាបវារណា ” ឈរនៅក្បែរបង្អួច សម្លឹងមើលទៅរោងបាយដោយគិតថា “ នាងអន្ធពាលនោះ កំពុងធ្វើអ្វីហ្ន៎ ? ” ឃើញ

*កោធវគ្គវណ្ណនា រឿងឧបាសិកាឧត្តរា*

ធីតាសេដ្ឋីនោះ សៅហ្មងដោយញើស ប្រឡូកប្រឡាក់ដោយ ផេះ ប្រឡាក់ធូលី និងម្រែងភ្លើង កំពុងចាត់ចែងដូច្នោះ ក៏ គិតថា " ពុទ្ធោអើយ ស្ត្រីអន្ធពាលនេះ មិនសោយនូវ សម្បត្តិដ៏ប្រកបដោយសិរីដូច្នេះ , ត្រឡប់ជាមានចិត្តត្រេកអរ ថា យើងនឹងបម្រើសមណៈត្រងោលទៅវិញ " សើចហើយ ត្រឡប់ទៅវិញ " ។

កាលសេដ្ឋីបុត្រនោះត្រឡប់ទៅវិញ នាងសិរិមាដែល ឈរនៅជិតសេដ្ឋីបុត្រនោះគិតថា " សេដ្ឋីបុត្រនេះសម្លឹងមើល អ្វី ហើយសើចហ្ន៎ " សម្លឹងមើលទៅតាមបង្អួចនោះ ឃើញ នាងឧត្តរាហើយគិតថា " សេដ្ឋីបុត្រនេះសើច ក៏ព្រោះឃើញ នាងនេះ , សេចក្តីស្និទ្ធស្នាលជាមួយនឹងនាងឧត្តរានុ៎ះ របស់ សេដ្ឋីបុត្រនេះនៅមានដោយពិត " ។

**[ នាងសិរិមាខឹងនាងឧត្តរាយកទឹកដោះក្តៅស្រោច ]**

បានឮថា នាងសិរិមានោះ ខ្ញុំជាពាហិរស្រ្តី នៅក្នុងផ្ទះនោះអស់កន្លះខែ សោយសម្បត្តិនោះ ក៏មិនដឹងថាខ្ញុំ ជាពាហិរស្រ្តី ( ស្រ្តីអំពីខាងក្រៅ ) បានធ្វើការសម្គាល់ថា “ ខ្ញុំ



ជាស្រ្តីមេផ្ទះ ” ចងអាឃាតនឹងនាងឧត្តរាថា “ យើងនឹងញ៉ាំងសេចក្តីទុក្ខឲ្យកើតដល់វា ” ទើបចុះចាកប្រសាទ ដើរចូលទៅកាន់រោងបាយ យកវែកដួសទឹកដោះថ្លាដែលកំពុងពុះនៅលើទីជាទីចំអិននំហើយ ដើរសំដៅទៅរកនាងឧត្តរា ។ នាងឧត្តរាឃើញនាងសិរិមាដើរមក ក៏ផ្សាយមេត្តាទៅរកនាងថា “ ស្រ្តីជាសម្លាញ់របស់អញមានឧបការៈចំពោះអញច្រើនណាស់ , ចក្រវាឡនៅចង្អៀតពេកណាស់ , ព្រហ្មលោក ក៏នៅទាបពេកណាស់ដែរ , ចំណែកគុណរបស់ស្រ្តីសម្លាញ់យើងធំពេកណាស់ , យើងអាស្រ័យនាង ទើបបានឱកាសថ្វាយទាន និងស្តាប់ធម៌ , ប្រសិនបើអញមានសេចក្តីក្រោធចំពោះនាងសិរិមានោះ ទឹកដោះថ្លានេះចូររលាកយើងចុះ , បើ

យើងមិនមានទេ ចូរកុំរលាកឡើយ ” ទឹកដោះថ្លាកំពុងពុះ ដែលនាងសិរិមាស្រោចលើសីសៈនាងឧត្តរានោះ បានក្លាយទៅជាវត្ថុដូចជាទឹកត្រជាក់ ។

គ្រានោះ ពួកទាសីរបស់នាងឧត្តរា ឃើញនាងសិរិមាញ៉ាំងវែកឲ្យពេញដោយទឹកដោះថ្លាកាន់យកមកទៀត ដោយ



គំនិតថា “ ទឹកដោះថ្លានេះត្រជាក់ ” ក៏គំរាមថា “ នែ ស្រីកំណាច ( ស្រីប្រដៅក្រ ) ហឯចូរចៀសចេញ, ហឯឯងមិនគួរយកទឹកដោះថ្លាដែលកំពុងពុះ ស្រោចលើនាងម្ចាស់របស់យើងទាំងឡាយទេ ក្រោកឡើងអំពីខាងនេះផង ខាងនោះផង ប្រើដៃផង ប្រើជើងផង វាយឲ្យដួលដេកលើផែនដី ។ នាងឧត្តរា មិនអាចនឹងហាមឃាត់នាងទាសីទាំងនោះបាន ។ គ្រានោះ នាងហាមឃាត់ទាសីទាំងឡាយ ដែលឈរនៅខាងលើនាងសិរិមានោះហើយ សួរសិរិមាថា “នែ នាងដ៏ចម្រើន នាងធ្វើកម្មដ៏ធ្ងន់បែបនេះ ដើម្បីអ្វី ? ” ដូច្នេះហើយ បានឲ្យឱវាទ

នាងសិរិមា ឲ្យផ្ងូតដោយទឹកដែលលាយដោយទឹកក្តៅ បាន ស្រឡាប ( បន្តក់ ) ដោយប្រេង ដែលគេចំអិនអស់មួយ រយដង ។

## [ នាងសិរិមាដឹងខ្លួនសូមទោសនាងឧត្តរា ]

ខណៈនោះ នាងសិរិមាដឹងខ្លួនថា ខ្លួនជាស្ត្រីខាងក្រៅ ហើយគិតថា “ យើងយកទឹកដោះដែលកំពុងពុះ ទៅស្រោច លើនាងឧត្តរា ព្រោះហេតុត្រឹមតែការសើចរបស់ស្វាមី យើង



បានកម្មធ្ងន់ណាស់ , នាងឧត្តរានេះមិនបញ្ជាពួកទាសីថា ពួក នាងចូរចាប់ស្ត្រីនេះ ត្រឡប់ជាហាមឃាត់ពួកទាសីទាំងអស់ ក្នុងកាលដែលបៀតបៀនយើង បានធ្វើនូវកិច្ចដែលបុគ្គល គប្បីធ្វើដល់យើង , ប្រសិនបើយើងមិនសូមឲ្យនាងអត់ទោស ឲ្យទេ , ក្បាលរបស់អញនឹងបែកជា ៧ ចំរៀក ” ដូច្នេះហើយ ទើបក្រាបចុះទៀបជើងនាងឧត្តរា ហើយពោលថា “ បពិត្រ នាងម្ចាស់ សូមនាងអត់នូវទោសនោះឲ្យខ្ញុំផងចុះ ” ។

នាងឧត្តរា. ខ្ញុំជាធីតាដែលមានបិតា កាលបើបិតារបស់ខ្ញុំអត់ទោសឲ្យនាង , ខ្ញុំក៏អត់ទោសឲ្យនាងដែរ ។

នាងសិរិមា. បពិត្រនាងម្ចាស់ សេចក្តីនោះលើកទុកសិនចុះ , ខ្ញុំនឹងឲ្យបុណ្ណសេដ្ឋីដែលជាបិតារបស់នាងអត់ឲ្យដែរ ។

នាងឧត្តរា. បុណ្ណសេដ្ឋីនោះ ជាបិតាបង្កើតរបស់យើងក្នុងវដ្ដៈ , ប៉ុន្តែកាលបិតាបង្កើតរបស់យើងក្នុងវិវដ្ដៈអត់ឲ្យ ខ្ញុំក៏អត់ទោសឲ្យដែរ ។

សិរិមា. អ្នកណាជាបិតាបង្កើតរបស់នាងក្នុងវិវដ្ដៈ ។

នាងឧត្តរា. ព្រះសម្មាសម្ពុទ្ធ ។

*គោធវគ្គវណ្ណនា រឿងឧបាសិកាឧត្តរា*

នាងសិរិមា. ខ្ញុំមិនមានសេចក្តីស្និទ្ធស្នាលជាមួយនឹងព្រះសម្មាសម្ពុទ្ធអង្គទេ ។

នាងឧត្តរា. ខ្ញុំជានាំរ៉ាប់រង , ថ្ងៃស្អែកនេះ ព្រះសាស្តាទ្រង់នាំភិក្ខុសង្ឃមកកាន់ទីនេះ នាងចូរកាន់យកគ្រឿងសក្ការៈ

តាមមានតាមបានមកកាន់ទីនេះ ហើយសូមឲ្យព្រះអង្គអត់ទោសឲ្យចុះ ។

## [ នាងសិរិមាសូមឲ្យព្រះសាស្តាអត់ទោសឲ្យ ]

នាងសិរិមាយល់ព្រមដោយពាក្យថា “ ប្រពៃហើយនាងម្ចាស់ ” ក្រោកឡើងដើរទៅកាន់ផ្ទះរបស់ខ្លួន ហើយប្រើស្ត្រីដែលជាបរិវារ ៥០០ ឲ្យត្រៀមខាទនីយៈ និងរបស់ស្រួបហុតមានប្រការផ្សេងៗ ស្អែកឡើងក៏កាន់សក្ការៈនោះមកផ្ទះនាងឧត្តរា មិនហ៊ានដាក់បាត្រភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទេ ទើបឈរនៅក្នុងទីមួយ នាងឧត្តរាឃើញដូច្នោះ ក៏ទៅយកវត្ថុទាំងអស់នោះមកចាត់ចែងប្រគេនភិក្ខុសង្ឃ មានព្រះពុទ្ធប្រធាន ។

ក្នុងវេលាស្រេចភត្តកិច្ច នាងសិរិមា ព្រមទាំងបរិវារ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ក្រាបចុះទៀបព្រះបាទរបស់ព្រះសាស្តា ។

គ្រានោះ ព្រះសាស្តាត្រាស់សួរនាងសិរិមាថា “ ម្នាល នាងសិរិមា នាងមានកំហុសអ្វី ?” ។

នាងសិរិមា. បពិត្រព្រះអង្គដ៏ចម្រើន កាលពីថ្ងៃម្សិល ខ្ញុំព្រះអង្គបានធ្វើកម្មឈ្មោះនេះ, កាលបើដូច្នោះ ស្ត្រីដែលជាសម្លាញ់របស់ខ្ញុំព្រះអង្គ បានហាមឃាត់ទាសីដែលបៀតបៀនខ្ញុំព្រះអង្គ បានធ្វើឧបការៈដល់ខ្ញុំព្រះអង្គដោយពិត ខ្ញុំព្រះអង្គដឹងនូវគុណនៃស្ត្រីដែលជាសម្លាញ់របស់ខ្ញុំព្រះអង្គ ទើបសូមឲ្យនាងអត់ទោសឲ្យ , កាលបើដូច្នោះ នាងពោលនឹងខ្ញុំព្រះអង្គថា កាលបើព្រះអង្គទ្រង់អត់ទោសឲ្យខ្ញុំព្រះអង្គ ទើបនាងអត់ទោសឲ្យដែរ ។

ព្រះសាស្តា. ម្នាលនាងឧត្តរា យ៉ាងនោះឬ ?

នាងឧត្តរា. ព្រះករុណា ព្រះអង្គ , កាលពីថ្ងៃម្សិល ស្ត្រីជាសម្លាញ់របស់ខ្ញុំព្រះអង្គ បានយកទឹកដោះដែលកំពុងពុះមកស្រោចលើក្បាលរបស់ខ្ញុំព្រះអង្គពិតមែន ។

ព្រះសាស្តាត្រាស់សួរថា “ ម្នាលនាងឧត្តរា កាលបើ

ដូច្នោះ នាងគិតយ៉ាងណា ?

នាងឧត្តរា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា ចក្រវាឡនេះចង្អៀតពេកណាស់ ព្រហ្មលោកក៏ទាបពេកដែរ , គុណរបស់ស្ត្រីជាសម្លាញ់របស់ខ្ញុំព្រះអង្គប៉ុណ្ណោះធំ , ព្រោះខ្ញុំព្រះអង្គអាស្រ័យនាង ទើបបានឱកាសធ្វើទាន និងស្តាប់ធម៌ , " ប្រសិនបើខ្ញុំព្រះអង្គ មានសេចក្តីក្រោធលើនាង , ទឹកដោះដ៏ក្តៅនេះចូរលោកខ្ញុំព្រះអង្គចុះ , បើខ្ញុំព្រះអង្គមិនមានសេចក្តីក្រោធទេ " កុំរលាកឡើយ , ហើយបានផ្សាយមេត្តាទៅកាន់នាង ។

ព្រះសាស្តាត្រាស់ថា " ប្រពៃហើយ នាងឧត្តរា ការឈ្នះសេចក្តីក្រោធយ៉ាងនោះ គួរ , ក៏ធម្មតាបុគ្គលអ្នកក្រោធគប្បីឈ្នះដោយការមិនក្រោធ , បុគ្គលដែលជេរគេ ផ្តាសាគេ គប្បីឈ្នះដោយការមិនជេរ ( តប ) មិនផ្តាសា ( តប ), បុគ្គលដែលកំណាញ់ស្វិតស្វាញ គប្បីឈ្នះដោយការឲ្យទាន,

បុគ្គលដែលនិយាយកុហក គប្បីឈ្នះដោយការពោលពាក្យពិត ” ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា :-

**៣ អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្ដីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អក្កោធេន** បុគ្គលដែលក្រោធ គប្បីឈ្នះដោយមិនក្រោធ ។ បុគ្គលដែលមិនល្អ គឺអ្នកមិនចំរើន គប្បីឈ្នះដោយអំពើល្អ , បុគ្គលកំណាញ់ គឺអ្នកស្វិតស្វាញ គប្បីឈ្នះដោយចិត្តដែលគិតលះវត្ថុជារបស់ខ្លួន , បុគ្គលនិយាយពាក្យឡេះឡោះ គប្បីឈ្នះដោយពាក្យ

ពិត , ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់យ៉ាងនេះថា
“ **អក្កោធេន ជិនេ កោធំ ។ បេ ។ សច្ចេនាលិកវាទិនំ** ” ។

កាលចប់ទេសនា នាងសិរិមា មួយអន្លើដោយបរិវារទាំង ៥០០ តាំងនៅក្នុងសោតាបត្តិផល ។៚

( **រឿងឧត្តរាឧបាសិកា ចប់** )

.....................

## ៤ រឿងបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **សច្ចំ ភណេ** ” ជាដើម ។

### [ ព្រះមហាមោគ្គល្លានទៅទេវលោក ]

សេចក្តីពិស្តារថា“សម័យមួយ ព្រះថេរៈនិមន្តទៅកាន់ទេវលោក ឈរនៅទៀបទ្វារវិមាននៃទេពធីតាអ្នកមានសក្តិធំ ហើយសួរទេពធីតានោះ ដែលមកកាន់សម្នាក់របស់ខ្លួន

ថ្វាយបង្គំហើយ ឈរនៅថា “ នែ ទេពធីតា សម្បត្តិរបស់នាងច្រើនណាស់ នាងបានដោយកម្មអ្វី ? ” ។

ទេពធីតា. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំសួរខ្ញុំព្រះករុណាធ្វើអ្វី ។

បានឮថា ទេពធីតានោះខ្មាសព្រះថេរៈ ព្រោះកម្មបន្តិចបន្តួចរបស់ខ្លួន ទើបបានពោលយ៉ាងនេះ ។ ទេពធីតានោះ កាលព្រះថេរៈពោលថា “ ចូរប្រាប់មកចុះ ” ទើប



ប្រាប់ព្រះថេរថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ទានក៏ខ្ញុំព្រះករុណាមិនបានថ្វាយ , ការបូជាក៏ខ្ញុំព្រះករុណាមិនបានធ្វើ , ព្រះធម៌ក៏មិនបានស្តាប់ , ខ្ញុំព្រះករុណារក្សាត្រឹមតែពាក្យសច្ចៈប៉ុណ្ណោះ ” ។

ព្រះថេរៈ ទៅកាន់ទ្វារវិមាននៃទេពធីតាដទៃៗ ហើយសួរទេពធីតាដទៃៗ ដែលមកហើយៗ កាលទេពធីតាទាំងនោះ មិនអាចនឹងលាក់លៀមព្រះថេរៈបានយ៉ាងនោះ , ទើប

ទេពធីតាមួយអង្គនិយាយមុនថា “ បពិត្រលោកម្ចាស់ បណ្តាបុញ្ញកម្មក្នុងបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានជាដើម ជាបុញ្ញកម្មដែលខ្ញុំព្រះករុណាបានធ្វើហើយ មិនមាន , ប៉ុន្តែក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ខ្ញុំព្រះករុណាជាទាសីនៃអ្នកដទៃ, ចៅហ្វាយរបស់ខ្ញុំនោះ កាចអាក្រក់ក្រៃលែងណាស់ តែងតែបំបែកក្បាលរបស់ខ្ញុំដោយកំណាត់ខ្ទះ ដោយអង្កត់ឧសខ្វះ ដែលខ្លួនកាន់យកហើយៗ , ខ្ញុំនោះកាលសេចក្តីក្រោធកើតឡើង ក៏ទូន្មានខ្លួនឯងប៉ុណ្ណោះថា “ ចៅហ្វាយរបស់នាងជាធំ នឹងធ្វើនាងឲ្យមានលក្ខណៈខ្ទាត់ខ្ទាយក៏បាន នឹងកាត់



អវយវៈទាំងឡាយ មានច្រមុះជាដើមរបស់នាងក៏បាន, ដូច្នេះហើយ ក៏មិនធ្វើសេចក្តីក្រោធ , ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាបាននូវសម្បត្តិនេះ ” ។

ទេពធីតាអង្គដទៃៗ ក៏ប្រាប់ទានបន្តិចបន្តួចដែលខ្លួនធ្វើហើយដោយន័យជាដើមថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំ

ព្រះករុណារក្សាចម្ការអំពៅ បានប្រគេនអំពៅមួយដើមដល់ភិក្ខុមួយរូប ” ។ អន្លដទៃប្រាប់ថា ខ្ញុំបានប្រគេនផ្លែទន្លាប់មួយផ្លែ ។ អន្លដទៃប្រាប់ថា ខ្ញុំបានប្រគេនផ្លែល្ពៅមួយផ្លែ ។ អន្លដទៃប្រាប់ថា ខ្ញុំបានប្រគេនផ្លែដីប៉ូមួយផ្លែ ។ អន្លដទៃប្រាប់ថា ខ្ញុំបានប្រគេនជំឡូងមួយមើម ។ អន្លដទៃប្រាប់ថា ខ្ញុំបានប្រគេនស្ពៅមួយក្តាប់ ដូច្នេះហើយ ក៏ប្រាប់ថា ព្រោះហេតុនោះ ទើបពួកខ្ញុំបានសម្បត្តិនេះ ” ។

## [ ពោលពាក្យសច្ចះប៉ុណ្ណោះក៏ទៅឋានសួគ៌បាន ]

ព្រះថេរៈ បានស្តាប់បុញ្ញកម្មដែលទេពធីតាទាំងនោះធ្វើហើយ ទើបចុះចាកស្ថានសួគ៌ ចូលទៅគាល់ព្រះសាស្តាហើយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអាចដែរ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ឬ ដើម្បីបាននូវទិព្វសម្បត្តិ ដោយហេតុត្រឹមតែពោលពាក្យពិត ត្រឹមតែរំលត់សេចក្តីក្រោធ ត្រឹមតែថ្វាយទាន មានផ្លែទន្លាប់ជាដើម ដ៏តិចតួចក្រៃពេក ?” ។

ព្រះសាស្តា. ម្នាលមោគ្គល្លាន ហេតុអ្វី ទើបអ្នកសួរតថាគត ពួកទេពធីតា ប្រាប់សេចក្តីនោះដល់អ្នកហើយ មិនមែនឬ ?

មោគ្គល្លាន. ព្រះករុណា ព្រះអង្គ ។ បុគ្គលប្រហែលជាបានទិព្វសម្បត្តិដោយបុញ្ញកម្មត្រឹមតែប៉ុណ្ណោះ ។

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់ព្រះមោគ្គល្លានថា " ម្នាលមោគ្គល្លាន បុគ្គលពោលត្រឹមតែពាក្យពិតក្តី លះបង់សេចក្តីក្រោធក្តី ថ្វាយទានត្រឹមតែបន្តិចបន្តួចក្តី រមែងទៅកាន់ទេវលោកបានដោយពិត " ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា :-

៤ សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១

*គោធវគ្គវណ្ណនា រឿងបញ្ហារបស់ព្រះមហាមោគ្គល្លានត្ថេរ*

កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឲ្យ ( តាមតិច )

១ បុគ្គលគប្បីទៅកើតក្នុងសម្នាក់ទេវតាទាំងឡាយ បាន ដោយហេតុទាំង ៣ នេះឯង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **សច្ចំ ភណេ** សេចក្ដីថា គប្បីសម្ដែង គឺគប្បីពោលពាក្យពិត , អធិប្បាយថា គួរតាំងមាំនៅក្នុងពាក្យពិត ។

បទថា **ន កុជ្ឈេយ្យ** បានដល់ មិនគួរក្រោធចំពោះបុគ្គលដទៃ ។

បទថា **យាចិតោ** សេចក្ដីថា បព្វជិតអ្នកមានសីលឈ្មោះថា អ្នកសូម ។ ពិតណាស់ បព្វជិតទាំងនោះ មិនសុំឡើយថា “ អ្នកទាំងឡាយចូរឲ្យ ” រមែងឈរនៅក្បែរទ្វារផ្ទះ ក៏ពិតមែន ប៉ុន្តែ ដោយអត្ថ ឈ្មោះថា សូមដែរ , បុគ្គលអ្នកមានសីល សូមហើយយ៉ាងនោះ កាលមានទេយ្យធម៌បន្តិចបន្តួច ក៏គប្បីឲ្យតាមបន្តិចបន្តួច ។

ពីរបទថា **ឯតេហិ តីហិ** សេចក្ដីថា បណ្ដាហេតុទាំង

នោះ ដោយហេតុត្រឹមតែមួយ បុគ្គលក៏អាចទៅទេវលោកបានដែរ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ។ល។

( រឿងបញ្ហារបស់ព្រះមហាមោគ្គល្លាន ចប់ )

# ៥ រឿងបញ្ហាដែលភិក្ខុទូលសួរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលទ្រង់អាស្រ័យក្រុងសាកេត ទ្រង់គង់នៅក្នុងអញ្ជនវ័ន ប្រារព្ធបញ្ហាដែលភិក្ខុទាំងឡាយទូលសួរ ត្រាស់ព្រះធម្មទេសនានេះថា “ **អហឹសកា យេ** ” ជាដើម ។

## [ ពីរនាក់ប្ដីប្រពន្ធសម្គែងខ្លួនថា ជាពុទ្ធបិតា និងពុទ្ធមាតា ]

បានឮមកថា ក្នុងកាលដែលព្រះមានព្រះភាគមានភិក្ខុសង្ឃចោមរោម ស្ដេចចូលទៅកាន់ក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់ដែលមានប្រក្រតីនៅក្នុងក្រុងសាកេតម្នាក់ ដើរចេញចាកព្រះនគរ ជួបព្រះទសពលក្បែរចន្លោះទ្វារ ក៏ក្រាបចុះទៀបព្រះបាទទាំងពីរ ហើយចាប់ឱ្យដ៏កព្រះបាទយ៉ាង

មាំ ពោលថា “ នែបា ធម្មតាមាតា និងបិតាទាំងឡាយ បុត្រទាំងឡាយ គប្បីប្រតិបត្តិក្នុងកាលដែលលោកចាស់ជរាហើយមិនមែនឬ ? ហេតុអ្វី ទើបកូនឯង មិនសម្ដែងខ្លួនឲ្យប្រាកដដល់យើងទាំងឡាយអស់កាលមានប្រមាណប៉ុណ្ណោះ ? បិតា



បានឃើញជួបកូនឯងហើយ ចំណែកមាតារបស់កូនឯង មិនទាន់បានជួបកូនឯងនៅឡើយ ដូច្នេះ កូនចូរទៅសួរសុខទុក្ខមាតារបស់កូនឯងបន្តិចទៅ ” លុះពោលដូច្នេះហើយ ក៏បាននាំព្រះសាស្ដាទៅកាន់ផ្ទះរបស់ខ្លួន ។ ព្រះសាស្ដា ស្ដេចទៅកាន់ផ្ទះនោះ ហើយទ្រង់គង់នៅលើអាសនៈដែលគេក្រាលទុកជាមួយនឹងភិក្ខុសង្ឃ ។

ចំណែកព្រាហ្មណី ក្រាបទៀបព្រះបាទទាំងពីររបស់ព្រះសាស្ដាហើយទូលថា “ នែកូនសម្លាញ់ កូនឯងទៅទីណាអស់កាលប្រមាណប៉ុណ្ណោះ ? ធម្មតាមាតា និងបិតាទាំងឡាយ បុត្រធីតាទាំងឡាយគប្បីបម្រើក្នុងកាលដែលខ្លួនចាស់

ជរាហើយ មិនមែនឬ ? ហើយញ៉ាំងបុត្រ និងធីតាឲ្យថ្វាយបង្គំព្រះសាស្ដាដោយពាក្យថា “ អ្នកទាំងឡាយចូរមក , ចូរថ្វាយបង្គំបងប្រុស ” ។

ចំណែកពីរនាក់ប្ដីប្រពន្ធនោះ មានចិត្តត្រេកអរ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលភិក្ខាក្នុងផ្ទះនេះអស់

*កោធវគ្គវណ្ណនា រឿងបញ្ហាដែលភិក្ខុទូលសួរ*

កាលជានិច្ចចុះ ” កាលព្រះសាស្ដាត្រាស់ថា “ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនទ្រង់ទទួលភិក្ខាតែក្នុងកន្លែងមួយអស់កាលជានិច្ចទេ ” ។ ទើបក្រាបទូលថា “ បើដូច្នោះ សូមព្រះអង្គទ្រង់បញ្ជូនពួកមនុស្ស ដែលមកនិមន្តព្រះអង្គ ឲ្យទៅសម្នាក់ខ្ញុំព្រះអង្គ ” ។

ចាប់ពីពេលនោះមក ព្រះសាស្ដាទ្រង់បញ្ជូនពួកជនដែលមកនិមន្តព្រះអង្គ ឲ្យទៅកាន់សម្នាក់ព្រាហ្មណ៍ដោយព្រះតម្រាស់ថា “ ពួកអ្នកចូរទៅប្រាប់ព្រាហ្មណ៍ចុះ ” អ្នក

ដែលមកនិមន្តព្រះអង្គទាំងនោះ តែងតែទៅប្រាប់ព្រាហ្មណ៍ថា “ យើងទាំងឡាយនិមន្តព្រះសាស្ដាដើម្បីទទួលភត្តក្នុងថ្ងៃស្អែក ” ។

ឲ្យតែថ្ងៃស្អែកឡើង ព្រាហ្មណ៍តែងតែកាន់ភាជនៈភត្តនិងភាជនៈសម្លអំពីផ្ទះរបស់ខ្លួន ទៅកាន់ទីជាទីគង់នៃព្រះ-សាស្ដា ។ ក្នុងកាលការនិមន្តក្នុងទីដទៃមិនមាន ព្រះសាស្ដាតែងតែទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ ចំណែកព្រាហ្មណ៍ និងព្រាហ្មណី ថ្វាយទេយ្យធម៌ចំពោះព្រះតថាគត

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ស្ដាប់ធម្មកថាជានិច្ច ហើយបានសម្រេចអនាគាមិផល ។

## [ ព្រះសាស្ដាត្រាស់បុព្វប្រវត្តិរបស់ព្រាហ្មណ៍ ]

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ អ្នកមានអាយុទាំងឡាយ ព្រាហ្មណ៍និងព្រាហ្មណីឈ្មោះឯណោះ ដឹងថា ព្រះបាទសុទ្ធោទនៈជាព្រះបិតារបស់ព្រះតថាគត , ព្រះនាងមហាមាយាជាព្រះមាតាហើយ ប៉ុន្តែ នៅតែហៅព្រះអង្គ

ថា បុត្ររបស់យើង , ចំណែកព្រះសាស្តាក៏ទ្រង់ទទួលដោយប្រការដូច្នោះដែរ , តើមានហេតុដូចម្តេចហ្ន៎ ?

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវកថារបស់ភិក្ខុទាំង-នោះហើយ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ទាំង ២ នាក់ប្តីប្រពន្ធនោះ រមែងហៅបុត្ររបស់ខ្លួនប៉ុណ្ណោះថា “ បុត្រ ” ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមក ទ្រង់សម្តែងនូវភាវៈនៃព្រះអង្គ ជាបុត្ររបស់ព្រាហ្មណ៍ពីរនាក់ប្តីប្រពន្ធនោះ អស់ ៣០០០ ជាតិថា “ ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាលព្រាហ្មណ៍នេះជាបិតារបស់តថាគត ៥០០ ជាតិ ជាប់ៗ គ្នា ជាឪពុកមា ៥០០ ជាតិ , ជាឪពុកធំ ៥០០ ជាតិ , ចំណែក

កោធវគ្គវណ្ណនា រឿងបញ្ហាដែលភិក្ខុទូលសួរ

ព្រាហ្មណីនោះក៏បានមាតារបស់តថាគត ៥០០ ជាតិ ជាប់ៗ គ្នា , ជាម្តាយមីង ៥០០ ជាតិ , ជាម្តាយធំ ៥០០ ជាតិ តថាគតចម្រើនវ័យក្នុងដៃរបស់ព្រាហ្មណ៍នោះ ១៥០០ ជាតិ

ចម្រើនវ័យក្នុងដៃរបស់ព្រាហ្មណី ១៥០០ ជាតិយ៉ាងនេះ ” ។ ហើយទ្រង់បានភាសិតព្រះគាថាទាំងនេះថា :-

“ ហឫទ័យត្រជាក់យ៉ាងក្រៃលែង ទាំងចិត្តក៏ជ្រះថ្លា ក្នុងបុគ្គលណា , គេរមែងស្រឡាញ់ចំពោះបុគ្គលនោះ សូម្បីខ្ញុំនមិនដែលបានឃើញ ។

សេចក្តីស្រឡាញ់នោះ រមែងកើតដោយសារហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នា ក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុពីរយ៉ាង គឺទឹក ១ ភក់ ១ ។

## [ ព្រះសាស្តាស្តេចទៅកាន់ទីបូជាសពរបស់ព្រាហ្មណ៍ ]

ព្រះសាស្តា ទ្រង់អាស្រ័យត្រកូលនោះ អស់មួយត្រៃ-

មាស ។ ចំណែកព្រាហ្មណ៍ និងព្រាហ្មណីនោះ ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផលហើយ ក៏បរិនិព្វាន ។ គ្រានោះ ជនទាំងឡាយធ្វើសក្ការៈដ៏ធំដល់ព្រាហ្មណ៍ និងព្រាហ្មណីនោះ ហើយក៏លើកឡើងកាន់ផ្ទះកំពូលជាមួយគ្នា ហើយនាំទៅកាន់ទីប៉ាឆា ។

ចំណែកព្រះសាស្តា មានភិក្ខុ ៥០០ ជាបរិវា ស្តេចទៅកាន់ទីប៉ាឆាជាមួយនឹងជនទាំងនោះដែរ ។

មហាជនចេញទៅដោយគិតថា " បានឮថា ព្រះមាតា និងព្រះបិតារបស់ព្រះពុទ្ធធ្វើមរណកាលទៅហើយ ។ ព្រះ-សាស្តា ស្តេចចូលទៅប្រថាប់ឈរនៅក្នុងសាលាមួយខ្នងដែលនៅជិតទីប៉ាឆានោះ ។ មហាជនមកថ្វាយបង្គំព្រះសាស្តាហើយ ឈរនៅក្នុងទីដ៏សមគួរមួយ ធ្វើបដិសណ្ឋារៈនឹងព្រះសាស្តាដោយទូលថា " បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំទ្រង់មានព្រះចិន្តាថា " ព្រះមាតា និងព្រះបិតារបស់ព្រះអង្គធ្វើមរណកាលទៅហើយ " ។

# [ ព្រះសាស្តាទ្រង់ត្រាស់ជរាសូត្រ ]

ព្រះសាស្តា មិនទ្រង់ហាមឃាត់មនុស្សទាំងនោះដូច្នេះឡើយថា " អ្នកទាំងឡាយកុំពោលយ៉ាងនោះ " ទ្រង់រមិលមើលនូវអជ្ឈាស្រ័យរបស់បរិស័ទ ហើយកាលនឹងទ្រង់សម្តែងធម៌ឲ្យសមគួរដល់ខណៈនោះ ទើបទ្រង់ត្រាស់ជរាសូត្រនេះដោយន័យជាដើមថា :-

" ជីវិតនេះមានប្រមាណតិចហ្ន៎ សត្វតែងស្លាប់ថយអំពី ១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះតែងស្លាប់ដោយជរាជាប្រាកដ " ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យបានមានដល់សត្វ ៨ ម៉ឺន ៤ ពាន់ ។

ភិក្ខុទាំងឡាយ កាលមិនដឹងថាព្រាហ្មណ៍ និងព្រាហ្មណី បរិនិព្វានហើយ ក៏ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ភពខាងមុខរបស់ព្រាហ្មណ៍ និងព្រាហ្មណីយ៉ាងណាដែរ ?" ។

## [ ព្រះអសេក្ខមុនីទៅកាន់ទីដែលមិនចុតិ ]

ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

អភិសម្បរាយភព របស់ព្រះអសេក្ខមុនីទាំងឡាយបែបនោះ រមែងមិនមាន, ព្រោះថា ព្រះអសេក្ខមុនីបែបនោះ រមែងដល់មហានិព្វានដែលឥតចេះចុតិ ដែលមិនចេះស្លាប់ " ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :-

**អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**
**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ ( ជាដើម ) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏

មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មុនយោ** គឺព្រះអសេក្ខមុនីទាំងឡាយសម្រេចមគ្គ និងផលដោយមោនេយ្យបដិបទា ។

បទថា **កាយេន** ពាក្យនោះ ត្រឹមតែជាពាក្យប្រធាននៃធម៌ទេសនាប៉ុណ្ណោះ ។ អធិប្បាយថា សង្រួមហើយ



ដោយទ្វារទាំង ៣ ។

បទថា **អច្ចុតំ** បានដល់ ទៀង ។

បទថា **ឋានំ** បានដល់ ឋានដែលមិនកម្រើក គឺឋានដែលទៀងទាត់ឋិតថេរ ។

បទថា **យត្ថ** ជាដើម សេចក្ដីថា មុនីទាំងឡាយរមែងទៅកាន់ឋាន គឺព្រះនិព្វាន ជាទីដែលមនុស្សទាំងឡាយទៅហើយមិនសោកសៅ គឺមិនក្ដៅក្រហាយ ។

ក្នុងចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផល ទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងបញ្ហាដែលពួកភិក្ខុទូលសួរ ចប់ )

8888888888888888888888888888888888888888

## ៦ រឿងនាងបុណ្ណាទាសី

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅលើភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធ ទាសីរបស់សេដ្ឋីក្រុងរាជគ្រឹះឈ្មោះបុណ្ណា ត្រាស់ធម្មទេសនា នេះថា “ **សទា ជាគរមានានំ** ” មានបទដូច្នេះជាដើម ។

**[ នាងបុណ្ណាថ្វាយនំកន្ទក់ចំពោះព្រះពុទ្ធ ]**

បានឮថា ថ្ងៃមួយ សេដ្ឋីក្នុងនគររាជគ្រឹះបានឲ្យស្រូវ ជាច្រើនដល់នាងបុណ្ណា ដើម្បីឲ្យនាងបុក ។ នាងអុជប្រទីប ក្នុងពេលរាត្រីដើម្បីបុកស្រូវ មានខ្លួនជោកទៅដោយញើស ទើបចេញទៅឈរហាលខ្យល់ព្ធដ៏ខាងក្រៅ ដើម្បីប្រយោជន៍ ដល់ការសម្រាក ។

ក្នុងសម័យនោះ ព្រះទព្វមល្លបុត្ត ជាអ្នកចាត់ចែង សេនាសនៈដើម្បីភិក្ខុទាំងឡាយ ។

ព្រះថេរៈញ៉ាំងម្រាមដៃឲ្យភ្លឺដើម្បីភិក្ខុទាំងឡាយ ដែល ស្តាប់ធម៌ហើយ ទៅកាន់សេនាសនៈរបស់ខ្លួនៗ និមិត្តភិក្ខុទាំង-ឡាយអ្នកទៅខាងមុខៗដើម្បីប្រយោជន៍ដល់ការសម្តែងផ្លូវ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

នាងបុណ្ណាឃើញភិក្ខុទាំងឡាយ ដែលត្រាច់ទៅលើភ្នំ ដោយ ពន្លឺនោះ ទើបគិតថា “ យើងត្រូវទុក្ខបៀតបៀន ទើបមិនចូល ដល់ការលក់ស្កប់ស្កល់នៅពេលនេះ ។ ចុះហេតុអ្វី លោកម្ចាស់ ទាំងឡាយ “ មិនលក់ដែរ ” ដូច្នេះហើយ ក៏សម្គាល់ថា “ ការ

មិនសប្បាយនឹងមានដល់ភិក្ខុរូបខ្លះ, ឬឧបទ្រវហេតុដោយសារ
ពស់នឹងមានក្នុងទីនោះជាប្រាកដ ” កាន់យកកន្ទក់អំពីព្រលឹម
ផ្សើមឲ្យទទឹកដោយទឹកហើយ ផ្ញើនំលើបាតដៃ អាំងនៅលើ
រងើកភ្លើង ខ្ចប់ដាក់ក្នុងថ្នក់ គិតថា “ នឹងស៊ីនំនៅតាមផ្លូវទៅ
កាន់កំពង់ទឹក ” ទើបកាន់ក្អមទឹកដើរសំដៅទៅកាន់កំពង់ទឹក។

ចំណែកព្រះសាស្ដា ក៏ស្ដេចយាងទៅកាន់ផ្លូវនោះដែរ
ដើម្បីចូលកាន់ស្រុកបិណ្ឌបាត។ នាងបុណ្ណាឃើញព្រះសាស្ដា
ហើយ គិតថា “ ក្នុងថ្ងៃដទៃៗ កាលយើងជួបព្រះសាស្ដា ,
ទេយ្យធម៌របស់យើងមិនមាន , កាលទេយ្យធម៌មាន , យើង
មិនបានជួបព្រះសាស្ដា , ឥឡូវនេះ ទេយ្យធម៌ក៏មាន , ទាំង
ព្រះសាស្ដាក៏ប្រាកដនៅចំពោះមុខ , ប្រសិនបើព្រះអង្គ ទ្រង់
មិនគិតថា “ ទានរបស់យើងសៅហ្មង ឬក៏ប្រណីត ហើយ



គប្បីទទួលសោត , យើងថ្វាយនំនេះចំពោះព្រះអង្គ ” ដូច្នេះ
ហើយ ក៏ដាក់ក្អមទឹកក្នុងចំណែកម្ខាង ថ្វាយបង្គំព្រះសាស្ដា

ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលទានដ៏សៅហ្មងនេះដោយអនុគ្រោះចុះ ” ។

ព្រះសាស្តា ទ្រង់ទតមើលព្រះអានន្ទត្ថេរហើយ ទ្រង់បង្អោនបាត្រដែលមហារាជថ្វាយ ដែលព្រះអានន្ទត្ថេរនាំចេញថ្វាយ ទទួលនំ ។

ចំណែកនាងបុណ្ណា ដាក់នំនោះទៅក្នុងបាត្ររបស់ព្រះសម្មាសម្ពុទ្ធ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គទ្រង់ឃើញហើយនោះ សូមសម្រេចដល់ខ្ញុំព្រះអង្គចុះ ” ។ ព្រះ-សាស្តា ទាំងដែលទ្រង់ប្រថាប់ឈរនោះឯង ទ្រង់បានធ្វើអនុមោទនាថា “ ម្នាលនាងបុណ្ណា សេចក្តីប្រាថ្នាដែលនាងតាំងទុកហើយយ៉ាងនេះ ចូរសម្រេចចុះ ” ។

## [ ព្រះសាស្តាទ្រង់សោយនំរបស់នាងបុណ្ណា ]

នាងបុណ្ណាគិតថា “ ព្រះសាស្តា ទ្រង់ធ្វើការសង្គ្រោះ

យើងក៏ពិតមែនហើយ ។ ប៉ុន្តែ ព្រះអង្គនឹងទ្រង់មិនសោយនំនោះទេ , គង់នឹងឲ្យនំនោះដល់ក្អែក ឬក៏ឆ្កែខាងមុខ ស្តេចទៅកាន់ព្រះដំណាក់របស់ព្រះរាជា ឬក៏ទៅកាន់ផ្ទះរបស់មហាអាមាត្យ នឹងសោយនូវភោជនដ៏ប្រណីតដោយពិត ” ។

ចំណែកព្រះសាស្តា ទ្រង់ព្រះតម្រិះថា “ នាងបុណ្ណានោះគិតដូចម្តេច ” ជ្រាបនូវវារៈចិត្តរបស់នាងហើយ ទ្រង់ក៏រមិលមើលព្រះអានន្ទត្ថេរ ហើយទ្រង់សម្តែងអាការដើម្បីនឹងគង់ ។ ព្រះថេរៈបានក្រាលចីវរថ្វាយ ។ ព្រះសាស្តាទ្រង់គង់ធ្វើភត្តកិច្ចនៅខាងក្រៅព្រះនគរនោះឯង ។ ទេវតាក្នុងលំហចក្រវាឡទាំងអស់ បានគាបនូវឱជារស ដែលសមគួរដល់ទេវតា និងមនុស្សទាំងឡាយ ឲ្យដូចជាផ្ងិតនៃឃ្មុំ ហើយដាក់ចូលទៅក្នុងនំនោះ ។ ចំណែកនាងបុណ្ណា ក៏បានឈរមើលព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចនោះដែរ ។

ក្នុងវេលាស្រេចភត្តកិច្ច ព្រះអានន្ទបានថ្វាយទឹក ។ ព្រះសាស្ដាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ត្រាស់ហៅនាង បុណ្ណាមក សួរថា " ម្នាលនាងបុណ្ណា ព្រោះហេតុអ្វី ទើបនាងរិះគន់

*កោធវគ្គវណ្ណនា រឿងនាងបុណ្ណាទាសី*

សាវករបស់តថាគត ?" ។

នាងបុណ្ណា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានរិះគន់សាវករបស់ព្រះអង្គទេ ។

ព្រះសាស្ដា. កាលបើដូច្នោះ នាងសម្លឹងមើលសាវកទាំងឡាយរបស់តថាគតហើយ គិតយ៉ាងណា ?

នាងបុណ្ណា. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា យើងមិនចូលដល់ការលក់ ព្រោះឧបទ្រពដែលកើតអំពីទុក្ខ ចំណែកលោកម្ចាស់ទាំងឡាយមិនចូលដល់ការលក់ ព្រោះមានហេតុអ្វី ? ការមិនសប្បាយ ឬឧបទ្រពដោយសត្វសាហាវមានពស់ជាដើម នឹងមានដល់ភិក្ខុរូបណាមួយដោយពិត ។

# [ សាវករបស់ព្រះពុទ្ធភ្ញាក់ជានិច្ច ]

ព្រះសាស្តា ទ្រង់បានព្រះសណ្តាប់នូវពាក្យរបស់នាងបុណ្ណានោះហើយ ក៏ត្រាស់ថា " ម្នាលនាងបុណ្ណា នាងមិនចូលដល់ការលក់ ព្រោះឧបទ្រពដែលកើតអំពីទុក្ខរបស់ខ្លួន , ចំណែកសាវករបស់តថាគត មិនចូលដល់ការលក់ ព្រោះ

**ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ**

ភាពជាអ្នកប្រកបរឿយៗ នូវធម៌ជាគ្រឿងភ្ញាក់រឭកគ្រប់កាល " ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា :-

**សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ**
**និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។**

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **អហោរត្តានុ-សិក្ខិនំ** បានដល់ សិក្សាត្រៃសិក្ខាទាំងថ្ងៃទាំងយប់ ។

បាទព្រះគាថា **និព្វានំ អធិមុត្តានំ** បានដល់ អ្នកមានអធ្យាស្រ័យក្នុងព្រះនិព្វាន ។

ពីរបទថា **អត្ថំ គច្ឆន្តិ** សេចក្ដីថា អាសវៈទាំងឡាយសូម្បីទាំងអស់របស់បុគ្គលបែបនោះ រមែងដល់ការតាំងនៅមិនបាន គឺរមែងវិនាស បានដល់ មិនមាន ។

*កោធវគ្គវណ្ណនា រឿងនាងបុណ្ណាទាសី*

ក្នុងកាលចប់ទេសនា នាងបុណ្ណាឈរនៅទីនោះឯងបានសម្រេចសោតាបត្តិផល , ទេសនាបានមានប្រយោជន៍សូម្បីដល់បរិស័ទដែលមកប្រជុំគ្នានៅទីនោះ ។

## [ ពួកភិក្ខុនាំគ្នាសរសើរព្រះសាស្ដា ]

ព្រះសាស្ដា លុះទ្រង់ធ្វើភត្តកិច្ចដោយនំកន្ទក់ ដែលចំអិនដោយរងើកភ្លើងហើយ ស្ដេចយាងទៅកាន់វិហារវិញ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ អ្នកមាន អាយុទាំងឡាយ អំពើដ៏កម្រដែលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើ កត្តកិច្ចដោយទំកន្ទក់ចំអិនដោយរងើកភ្លើង ដែលនាងបុណ្ណា ថ្វាយ ទ្រង់បានធ្វើហើយ ” ។

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា “ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី ? កាលភិក្ខុទាំងឡាយ ក្រាបទូលថា “ ដោយកថាឈ្មោះនេះ ព្រះអង្គ ” ដូច្នេះហើយ ទើបត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ , សូម្បីក្នុងកាលពី មុន តថាគតក៏បរិភោគនំកន្ទក់ ដែលនាងបុណ្ណានេះឲ្យហើយ ដែរ ហើយទ្រង់នាំអតីតនិទានមក ទ្រង់ត្រាស់កុណ្ឌកសិន្ធវ-ពោតកជាតកនេះឲ្យពិស្ដារថា :-

ព្រះពោធិសត្វ កាលនឹងសាកល្បង ( សួរ ) សេះសិន្ធវ នោះ ទើបពោលគាថាទី ១ ថា “ អ្នក ធ្លាប់បរិភោគស្មៅដ៏សល់ ដែលធ្លាប់បរិភោគបាយ

ក្តាំង និងកន្ទក់ហើយ នេះជាភោជនរបស់អ្នក អ្នក ឥឡូវនេះ ហេតុអ្វីក៏អ្នកមិនបរិភោគ ” ។

សេះសិន្ធពស្តាប់ឮដូច្នោះហើយ ក៏បានពោល ២ គាថា ក្រោយនេះថា :-

“ បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វ ដែលគួរចិញ្ចឹមដោយជាតិ ឬដោយមារយាទដែលគួរ ទូន្មាន ក្នុងទីណា ក្នុងទីនោះ ថ្វីក៏ខ្ញុំមិនបរិភោគបាយ ក្តាំងនឹងកន្ទក់ច្រើន ។

ចំណែកខាងលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តម យ៉ាងណាៗ ខ្ញុំកាលដឹង ព្រោះអាស្រ័យអ្នកជាអ្នក ដឹង ទើបមិនបរិភោគនូវកន្ទក់របស់អ្នក ។៚

( រឿងនាងបុណ្ណាទាសី ចប់ )

8888888888888888888888888888888

## ៧ រឿងអតុលឧបាសក

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដល់ឧបាសកឈ្មោះ អតុលៈ ត្រាស់ព្រះធម្មទេសនានេះថា “ **បោរាណមេតំ** ” មានបទដូច្នេះជាដើម ។

## [ អតុលៈក្រោធព្រះរេវតៈ ព្រោះលោកមិននិយាយជាមួយ ]

សេចក្តីពិស្តារថា អតុលៈនោះជាឧបាសកអ្នកក្រុងសាវត្ថី មានឧបាសកជាបរិវារ ៥០០ នាក់ ថ្ងៃមួយ នាំពួកឧបាសកទាំងនោះទៅកាន់វិហារដើម្បីស្តាប់ ប្រាថ្នានឹងស្តាប់ក្នុងសម្នាក់ព្រះរេវតៈ ថ្វាយបង្គំព្រះរេវតៈហើយអង្គុយក្នុងទីសមគួរមួយ ។

លោកអ្នកមានអាយុអង្គនោះ ជាអ្នកត្រេកអរក្នុងការចេញចាកអារម្មណ៍ហើយពួនសម្ងំនៅក្នុងកម្មដ្ឋាន និងជាអ្នកត្រាច់ទៅតែម្នាក់ឯងដូចជារាជសីហ៍ , ព្រោះដូច្នោះ ទើបលោកមិនពោលពាក្យអ្វីៗ ជាមួយនឹងឧបាសកនោះ ឧបាសក

នោះក្រោធថា “ ព្រះថេរៈរូបនេះមិនពោលពាក្យអ្វីៗ ជាមួយនឹងខ្ញុំទេ ” ក្រោកឡើង ដើរទៅកាន់សម្នាក់ព្រះសារីបុត្តត្ថេរឈរនៅក្នុងទីដ៏សមគួរមួយ, កាលព្រះថេរៈពោលថា “ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយមកមានការអ្វី ?” ពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានាំឧបាសកទាំងនេះចូលទៅរកព្រះរេវតត្ថេរ ដើម្បីស្តាប់ព្រះធម៌ , ប៉ុន្តែព្រះថេរៈមិនបានពោលពាក្យអ្វីៗ ជាមួយនឹងពួកខ្ញុំព្រះករុណាឡើយ , ខ្ញុំខឹងលោកទើបមកកាន់ទីនេះ , សូមលោកម្ចាស់សម្តែងធម៌ដល់ពួកខ្ញុំព្រះករុណាចុះ ” ។

គ្រានោះ ព្រះថេរៈពោលថា “ ម្នាលឧបាសក បើដូច្នោះ អ្នកទាំងឡាយចូរអង្គុយចុះ ” ហើយសម្តែងអភិធម្មកថា យ៉ាងច្រើនសន្ធឹកសន្ធប់ ។

## [ អតុលៈខឹងអ្នកនិយាយច្រើន ]

ឧបាសកក្រោធថា “ ដែលឈ្មោះថាអភិធម្មកថា ជាធម៌ល្អិតក្រៃពេក សុខុមក្រៃពេក , ព្រះថេរៈសម្តែងអភិធម្មតែម្យ៉ាងយ៉ាងច្រើន, ពួកយើងមិនត្រូវការអភិធម្មទេ ” ដូច្នោះ

*កោធវគ្គវណ្ណនា រឿងអតុលឧបាសក*

ហើយ បាននាំបរិស័ទទៅកាន់សម្នាក់ព្រះអានន្ទត្ថេរ , កាលព្រះថេរៈសួរថា “មានការអ្វី ឧបាសក ?” ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាចូលទៅរកព្រះរេវតៈដើម្បីស្តាប់ព្រះធម៌ , មិនបានសូម្បីតែការរាក់ទាក់ និងការសំណេះសំណាលបន្តិចបន្តួច ក្នុងសម្នាក់របស់លោក ក្រោធខឹងហើយ ទើបទៅកាន់សម្នាក់ព្រះសារីបុត្រ, សូម្បីព្រះថេរៈរូបនោះ ក៏សម្តែងអភិធម្មតែម្យ៉ាង ល្អិតក្រៃពេក យ៉ាងច្រើនដល់ពួកខ្ញុំព្រះករុណា , ពួកខ្ញុំព្រះករុណាខឹងព្រះថេរៈរូបនោះថា ពួកយើងមិនត្រូវការអភិធម្មទេ ហើយទើបមកទីនេះ , សូមលោកម្ចាស់សម្តែងធម្មកថាដល់ពួកខ្ញុំព្រះករុណាចុះ ” ។

ព្រះថេរៈ. បើដូច្នោះ ពួកអ្នកចូរអង្គុយស្តាប់ចុះ ។

ព្រះថេរៈសម្តែងព្រះធម៌តែបន្តិចបន្តួច ដល់ពួកឧបាសក
ទាំងនោះ ធ្វើឲ្យឧបាសកទាំងនោះយល់បានងាយ ។

## [ អតុលៈខឹងអ្នកនិយាយតិច ]

ឧបាសកទាំងនោះខឹងព្រះថេរៈហើយ ទៅកាន់សម្នាក់
ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

គ្រានោះ ព្រះសាស្តា ត្រាស់សួរឧបាសកទាំងនោះថា
“ ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយមកកាន់ទីនេះមាន
ការអ្វី ?” ។

ពួកឧបាសក. បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ
មកដើម្បីស្តាប់ធម៌ ។

ព្រះសាស្តា ត្រាស់សួរឧបាសកទាំងនោះថា អ្នកទាំង
ឡាយបានស្តាប់ធម៌ហើយឬ ?

ពួកឧបាសក. បពិត្រព្រះអង្គដ៏ចម្រើន ដំបូង ពួកខ្ញុំ
ព្រះអង្គចូលទៅរកព្រះរេវតៈ , លោកមិនបានពោលពាក្យ

អ្វីៗ ជាមួយនឹងពួកខ្ញុំព្រះអង្គឡើយ , ពួកខ្ញុំព្រះអង្គខឹងលោក ហើយ ក៏ទៅរកព្រះសារីបុត្រ , ព្រះថេរៈនោះសម្តែងអភិធម្ម ដល់ពួកខ្ញុំព្រះអង្គយ៉ាងច្រើន , ពួកខ្ញុំព្រះអង្គកំណត់អភិធម្ម នោះមិនបាន ក៏ក្រោធខឹង ហើយចូលទៅរកព្រះអានន្ទ ព្រះ ថេរៈនោះសម្តែងធម៌ដល់ពួកខ្ញុំព្រះអង្គតិចពេក,ពួកខ្ញុំព្រះអង្គ ខឹងលោកហើយ មកកាន់ទីនេះ ។

*កោធវគ្គវណ្ណនា រឿងអតុលឧបាសក*

## [ ការនិន្ទា និងការសរសើរជារបស់ចាស់ ]

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ឧបាសក ទាំងនោះហើយ ក៏ត្រាស់ថា “ ម្នាលអតុលៈ ការនិន្ទា និង ការសរសើរនេះជារបស់បូរាណ , ( ព្រោះថា ) ជនទាំង- ឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គល អ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណ ក៏មាន ( អ្នកណាៗ ក៏ដោយ ) ក្នុងលោក ដែលមិនត្រូវគេ

និន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង រមែងមិនមាន , សូម្បីព្រះរាជាទាំងឡាយ ជនពួកខ្លះក៏និន្ទា ពួកខ្លះក៏សរសើរ , ផែនដីដ៏ធំក្តី ព្រះចន្ទនិងព្រះអាទិត្យក្តី , ធាតុ មានអាកាសជាដើមក្តី , បុគ្គលខ្លះនិន្ទា បុគ្គលខ្លះសរសើរ , សូម្បីព្រះសម្មាសម្ពុទ្ធ ដែលទ្រង់គង់សម្តែងធម៌កណ្តាលបរិស័ទទាំង ៤ ពួកខ្លះនិន្ទា ពួកខ្លះសរសើរ , ការនិន្ទា និងសរសើររបស់បុគ្គលពាល មិនជាប្រមាណទេ , ប៉ុន្តែ បុគ្គលដែលត្រូវបណ្ឌិតអ្នកមានបញ្ញានិន្ទាហើយ ទើបឈ្មោះថា ជាការនិន្ទាពិតៗ អ្នកដែលបណ្ឌិត



សរសើរហើយ ឈ្មោះថា ជាការសរសើរពិតៗ ” ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា :-

**បោរាណមេតំ អតុល នេតំ អជ្ជតនាមិវ**
**និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ**
**មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ។**

ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តិំ មេធាវឹ បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុលៈ ការតិះដៀល និងការសរសើរនេះ ជារបស់បុរាណ ការតិះដៀល និងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ ( ព្រោះថា ) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើន ក៏មាន



និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណ ក៏មាន ( អ្នកណាៗក៏ដោយ ) ក្នុងលោកដែលមិនត្រូវគេនិន្ទាគ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម៉្យាង ឬត្រូវ

គេសរសើរតែម្យ៉ាងគ្មានឡើយ មិនមែនមានមក ហើយតែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ៗ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្ត មិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ ក្នុងបញ្ញា និងសីល អ្នកណាគួរនឹងនិន្ទាបុគ្គលដែលដូចជាគ្រឿង នៃមាសជម្ពូនទនោះបាន សូម្បីទេវតា និងមនុស្ស ទាំងឡាយ ក៏សរសើរបុគ្គនោះ ទាំងព្រហ្មក៏សរសើរ ( ដូចគ្នា ) ។

## <u>អធិប្បាយគាថា</u>

បណ្តាបទទាំងនោះ បទថា **បោរាណមេតំ** ការនិន្ទា និងការសរសើរនុ៎ះ ជារបស់បុរាណ ។

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

ព្រះសម្ពុទ្ធ ត្រាស់ហៅឧបាសកនោះថា “ អតុលៈ ”។

បាទព្រះគាថាថា **នេតំ អជ្ជតនាមិវ** សេចក្តីថា ការនិន្ទា ឬការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ ។ អធិប្បាយថា ពិតណាស់ ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមថា “ ហេតុដូចម្តេច បុគ្គលនេះអង្គុយស្ងៀមដូចជាមនុស្សគ ដូចជាមនុស្សថ្លង់ ដូចជាមនុស្សមិនដឹងអ្វី ” ដូច្នេះក៏មាន , តែងនិន្ទាបុគ្គលអ្នកនិយាយច្រើនថា “ ហេតុដូចម្តេច បុគ្គលនេះក៏ចចាកអារាក ដូចជាស្លឹកត្នោតដែលត្រូវខ្យល់បក់ , ពាក្យសម្តីរបស់បុគ្គលនេះ មិនមានទីបំផុត ” ដូច្នេះក៏មាន , តែងនិន្ទាដល់បុគ្គលអ្នកនិយាយល្មមប្រមាណថា “ ហេតុដូចម្តេច បុគ្គលនេះសម្គាល់ពាក្យសម្តីដូចជាមាសប្រាក់ និយាយពីរបីមាត់ហើយអង្គុយស្ងៀម ” ដូច្នេះក៏មាន , បុគ្គលដែលមិនត្រូវគេនិន្ទា រមែងមិនមានក្នុងលោកនេះ ដោយប្រការទាំងពួង ដោយប្រការយ៉ាងនោះ ។

បទថា **ន ចាហុ** ជាដើម បានដល់ មិនមែនមានមកហើយតែក្នុងអតីតទេ , នឹងមានទៅក្នុងអនាគតក៏ទេ ។

ពីរបទថា **យោ ច វិញ្ញូ** សេចក្តីថា ការនិន្ទា ឬការ សរសើររបស់ជនពាល មិនជាប្រមាណ , ប៉ុន្តែ បណ្ឌិតទាំង ឡាយសង្កេតមើលហើយ គឺជ្រាបហេតុនៃការនិន្ទា ឬហេតុ នៃការសរសើរហើយរាល់ៗ ថ្ងៃ រមែងសរសើរបុគ្គលណា អ្នកដែលមានឈ្មោះថាប្រព្រឹត្តមិនដាច់ ព្រោះជាអ្នកប្រកប ព្រមដោយសិក្ខាទាំងបីមិនដាច់ ឬការប្រព្រឹត្តទៅនៃជីវិតមិន ដាច់ អ្នកដែលមានឈ្មោះថា មានបញ្ញា ព្រោះជាអ្នកប្រកប ព្រមដោយលោកិយបញ្ញា និងលោកុត្តរបញ្ញា និងដល់ព្រម ដោយបារិសុទ្ធិសីល ៤ , អ្នកណាគួរនឹងនិន្ទាបុគ្គលដែលដូច ជាគ្រឿងនៃមាសជម្ពូនទ: ដែលប្រាសចាកទោសនៃមាស ទាំងគួរដល់ការជំ និងការខាត់ ។

បទថា **ទេវាបិ** ជាដើម បានដល់ ទេព្តាក្តី មនុស្ស ជាបណ្ឌិតក្តី ក្រោកឡើងហើយ រមែងស្ញើច រមែងសរសើរ នូវភិក្ខុនោះ ។

បទថា **ព្រហ្មុនាបិ** សេចក្ដីថា មិនមែនត្រឹមតែទេវតា និងមនុស្សប៉ុណ្ណោះទេ ដែលសរសើរនោះ , សូម្បីមហាព្រហ្មក្នុងមុឺនចក្រវាឡ ក៏សរសើរបុគ្គលនោះដែរ ។

ក្នុងកាលចប់ទេសនា ឧបាសកទាំង ៥០០ នោះបានសម្រេចសោតាបត្តិផល ៕

( រឿងអតុលឧបាសក ចប់ )

8888888888888888888888888888

# ៨ រឿងឆព្វគ្គិយភិក្ខុ

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា " **កាយប្បកោបំ** " មានបទដូច្នេះជាដើម ។

## [ មូលបញ្ញត្តិការពាក់ទ្រនាប់ជើងឈើ ]

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវសំឡេង " **ខដៈ ខដៈ** " នៃភិក្ខុទាំងនោះ ដែលជាអ្នកកាន់ឈើប្រត់ដោយដៃទាំងពីរ ពាក់ទ្រនាប់ជើងចង្រ្កមលើថ្មដា ត្រាស់សួរថា " ម្នាលអានន្ទ នុ៎ះជាសំឡេងអ្វី ?" ទ្រង់ព្រះសណ្តាប់ថា "បពិត្រព្រះអង្គដ៏ចម្រើន នុ៎ះជាសំឡេងខដៈ ខដៈ នៃពួកឆព្វគ្គិយភិក្ខុ ដែលពាក់ទ្រនាប់ជើងឈើចង្រ្កម " ក៏ទ្រង់បញ្ញត្តិសិក្ខាបទ ហើយត្រាស់ថា " ម្នាលភិក្ខុ

ទាំងឡាយ ធម្មតាភិក្ខុ គួររក្សាទ្វារ មានកាយទ្វារជាដើម ”
ដូច្នេះហើយ កាលទឹងទ្រង់សម្ដែងធម៌ ទើបទ្រង់ភាសិត
ព្រះគាថាទាំងនេះថា :-

៨. កាយប្បកោបំ រក្ខេយ្យ កាយេន សំវុតោ សិយា

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ
វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ
កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា តេ វេ សុបរិសំវុតា ។

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួម
កាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្ត
សុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បី

សង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្ត វចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយបានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា

*កោធវគ្គវណ្ណនា រឿងឆព្វគ្គិយភិក្ខុ*

សង្រួមហើយដោយប្រពៃ ។

## <u>អធិប្បាយគាថា</u>

បណ្ដាបទទាំងនោះ បទថា **កាយប្បកោបំ** បានដល់គប្បីរក្សាកាយសុចរិតបីយ៉ាង ។

ពីរបទថា **កាយេន សំវុតោ** សេចក្ដីថា គប្បីហាមឃាត់ទុច្ចរិតកុំឲ្យចូលទៅក្នុងកាយទ្វារ សង្រួមហើយ គឺមានទ្វារបិទហើយ , ក៏ព្រោះបុគ្គលលះបង់កាយទុច្ចរិតប្រព្រឹត្តកាយសុចរិត ឈ្មោះថា រមែងធ្វើកម្មនោះ សូម្បីទាំងពីរ

យ៉ាង , ព្រោះដូច្នោះ ទើបព្រះអង្គត្រាស់ថា “ **កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ** ” សូម្បីក្នុងគាថាជាលំដាប់ទៅ ក៏ន័យនេះដូចគ្នា ។

បាទព្រះគាថា **កាយេន សំវុតា** សេចក្តីថា បណ្ឌិតទាំងឡាយណា កាលមិនប្រព្រឹត្តកាយទុច្ចរិតមានបាណាតិបាតជាដើម ឈ្មោះថា បានសង្រួមកាយហើយដែរ , កាលមិនប្រព្រឹត្តវចីទុច្ចរិត មានមុសាវាទជាដើម ឈ្មោះថា បានសង្រួមវាចាហើយដែរ , កាលមិនញ៉ាំងមនោទុច្ចរិត មាន



អភិជ្ឈាជាដើមឲ្យកើតឡើង ឈ្មោះថា បានសង្រួមចិត្តហើយ, បណ្ឌិតទាំងនោះ ឈ្មោះថា សង្រួមហើយដោយប្រពៃ ដោយសព្វគ្រប់ គឺរក្សាល្អហើយ គ្រប់គ្រងល្អហើយ មានទ្វារបិទល្អហើយក្នុងលោកនេះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិជាដើម ៕៚

( រឿងឆព្វគ្គិយភិក្ខុ ចប់ )

## កោធវគ្គវណ្ណនា ចប់

## វគ្គទី ១៧ ចប់

# ធម្មបទគាថា មលវគ្គទី ១៨

១ បណ្ឌុបលាសោវទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ បតិដ្ឋសិ

បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ ។
២ ឧបនីតវយោ វទានិសិ
សម្បយាតោសិ យមស្ស សន្តិកំ
វាសោបិ ច តេ នត្ថិ អន្តរា
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមសោ អនង្គណោ
ន បុន ជាតិជរំ ឧបេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជប្រាកដដល់អ្នកហើយ ខ្លួនអ្នក

តាំងនៅក្នុងមាត់នៃសេចក្ដីវិនាស សូម្បីស្បៀងគឺ
កុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។
អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យា-
យាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើ
យ៉ាងនេះហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិល
បាន មិនមានទីទួល គឺកិលេស នឹងដល់នូវភូមិ
របស់ព្រះអរិយៈ ដូចជាទិព្វបាន ។
ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នក
រៀបដំណើរទៅកាន់សម្នាក់យមរាជ មួយទៀត
ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បី
ស្បៀង ក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យ
ឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះ
ហើយ ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិន
មានទីទួល គឺកិលេស នឹងមិនត្រូវចូលទៅកាន់

ជាតិ ជរា ព្យាធិ មរណៈ ទៀតឡើយ ។

**៣ អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**

**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្ដងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជម្រះស្នឹម ឬច្រែះរបស់មាស ដូច្នោះ ។

**៤ អយសា វ មលំ សមុដ្ឋិតំ**

**តទុដ្ឋាយ តមេវ ខាទតិ**

**ឯវំ អតិធោនចារិនំ**

**សានិ កម្មានិ ន យន្តិ ទុគ្គតឹ ។**

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះដែរ ។

៥ អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។
មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច
តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាតិជាមន្ទិលដ៏លើសលប់ជាងមន្ទិលទាំងឡាយ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ

អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

**សុជីវំ អហិរិកេន កាកសូរេន ធំសិនា**
**បក្ខន្ទិនា បគព្ភេន សង្កិលិដ្ឋេន ជីវិតំ ។**
**ហិរីមតា ច ទុជ្ជីវំ និច្ចំ សុចិគវេសិនា**
**អលីនេនាបគព្ភេន សុទ្ធាជីវេន បស្សតា ។**

បុគ្គលអ្នកមិនមានសេចក្ដីអៀនខ្មាស ក្លៀវក្លាដូចសត្វក្អែក កម្ចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន ( យកមុខ ) ជាអ្នកឃ្នើសឃ្នង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្ដីអៀនខ្មាស ស្វែងរកអំពើល្អជានិច្ច មិនឡេះឡោះ មិនឃ្នើសឃ្នង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

**យោ បាណមតិមាបេតិ មុសាវាទញ្ច ភាសតិ**

លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ
សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា
មាតំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។

ជនណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត ។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយ មានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈ និងសភាពមិនមែនធម៌ គឺទោសៈ ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។

ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
ជន រមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គល
ណា ជាអ្នកអៀនខ្មាសក្នុងទឹក និងភោជនទាំង
ឡាយដទៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុង
វេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។
លុះតែសេចក្តីអៀនខ្មាសនោះ បុគ្គលណាបាន
ផ្តាច់ផ្តិលជកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ
បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុងវេលា
ថ្ងៃ ឬក្នុងវេលាយប់ ។
នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ
នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្តាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

**សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ**
**បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថាភុសំ**
**អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ ។**

ទោសរបស់ជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយ ចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថា រមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងអត្តភាព ដោយវត្ថុសម្រាប់បិទបាំង ( មានមែកឈើជាដើម ) ដូច្នោះ ។

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**
**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

កាលបុគ្គលគយឃ្លាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស ( អ្នកដទៃ ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយ របស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះឈ្មោះថា នៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

**អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ**
**បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។**
**អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ**
**សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។**

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយជារបស់ទៀង

មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

**មលវគ្គទី ១៨ ចប់**

# ១៨ មលវគ្គវណ្ណនា

## ១ រឿងបុត្ររបស់បុរសអ្នកសម្លាប់គោ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុត្ររបស់បុរសអ្នកសម្លាប់គោម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **បណ្ឌុបលាសោវទានិសិ** ” មានបទដូច្នេះជាដើម ។

### [ បុរសអ្នកសម្លាប់គោប្រើប្រពន្ធឲ្យអាំងសាច់ ]

បានឮថា នៅក្នុងក្រុងសាវត្ថីមានបុរសអ្នកសម្លាប់គោម្នាក់ សម្លាប់គោហើយ កាន់យកសាច់ដែលល្អៗ ប្រើប្រពន្ធឲ្យចំអិន ហើយអង្គុយបរិភោគជាមួយប្រពន្ធ និងកូននូវសាច់នោះ និងលក់យកតម្លៃ ។ បុរសអ្នកសម្លាប់គោនោះ ធ្វើការងាររបស់បុគ្គលអ្នកសម្លាប់យ៉ាងនេះអស់ ៥៥ ឆ្នាំ មិនបានថ្វាយយាគូ ឬក៏កត្ត សូម្បីមួយវែកចំពោះព្រះសាស្ដាដែលគង់នៅក្នុងវិហារដ៏ជិត ។ គាត់វៀរចាកសាច់ មិនអាច

បរិភោគកក្តបានឡើយ ។ ថ្ងៃមួយ គាត់លក់សាច់ក្នុងវេលាថ្ងៃហើយ បានឲ្យសាច់មួយដុំដល់ភរិយាយកទៅអាំងសម្រាប់ខ្លួន ហើយចេញទៅផ្លូតទឹក ។

គ្រានោះ សម្លាញ់របស់គាត់ មកកាន់ផ្ទះរបស់គាត់ ហើយនិយាយទៅកាន់ភរិយារបស់គាត់ថា " នៃនាងដ៏ចម្រើន នាងចូរឲ្យសាច់ដែលត្រូវលក់ដល់ខ្ញុំបានបន្តិច , ( ព្រោះ ) ខ្ញុំមានភ្ញៀវ " ។

ភរិយានាយគោឃាតកៈ. នៃអ្នកដ៏ចម្រើន សាច់ដែលត្រូវលក់មិនមានទេ , សម្លាញ់របស់អ្នកលក់សាច់អស់ហើយ ឥឡូវនេះគេទៅផ្លូតទឹក ។

សម្លាញ់. នៃនាងដ៏ចម្រើន នាងកុំធ្វើយ៉ាងនេះឡើយ , បើដុំសាច់មាន ចូរឲ្យមកចុះ ។

ភរិយារបស់នាយគោឃាតកៈ. វៀរដុំសាច់ដែលខ្ញុំទុកដើម្បីសម្លាញ់របស់អ្នកហើយ សាច់ដទៃមិនមាន ។

បុរសនោះគិតថា " សាច់ដទៃអំពីសាច់ដែលស្ត្រីនេះទុកដើម្បីប្រយោជន៍ដល់សម្លាញ់របស់អញ មិនមាន ហើយសម្លាញ់របស់អញនោះសោត វៀរចាកសាច់ រមែងមិនបរិ-



ភោគ , ស្ត្រីនេះនឹងមិនឲ្យ " ទើបកាន់យកសាច់នោះខ្លួនឯង ហើយចៀសចេញទៅ ។

ចំណែកបុរសអ្នកសម្លាប់គោនោះ ងូតទឹករួចហើយត្រឡប់មកវិញ , កាលភរិយាដួសបាយនាំចូលទៅ មួយអន្ទើដោយបន្លែផ្អិនដើម្បីខ្លួន , ក៏សួរថា " ឯណាសាច់ ?" ។

ភរិយា. បពិត្រនាយ សាច់មិនមាន ។

នាយគោឃាតកៈ. មុននឹងអញទៅងូតទឹក អញបានឲ្យសាច់មួយដុំដល់នាងដើម្បីយកទៅអាំងសម្រាប់អញ មិនមែនឬ ?

ភរិយា. សម្លាញ់របស់អ្នកមកប្រាប់ថា " ខ្ញុំមានភ្ញៀវ , នាងចូរឲ្យសាច់ដែលត្រូវលក់ដល់ខ្ញុំបន្តិច ", កាលខ្ញុំប្រាប់គេថា សាច់ដទៃអំពីសាច់ដែលទុកដើម្បីសម្លាញ់របស់អ្នកមិន

មាន , ម្យ៉ាងទៀត សម្លាញ់របស់អ្នកនោះសោត វៀរចាកសាច់ រមែងមិនបរិភោគ ", ក៏កាន់យកសាច់នោះខ្លួនឯងហើយចៀសចេញទៅ ។

នាយគោឃាតកៈ. គ្មានសាច់ យើងមិនបរិភោគទេ , នាងចូរនាំកត្តនោះទៅវិញចុះ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ករិយា. ឲ្យខ្ញុំធ្វើដូចម្តេច , ចូរបរិភោគចុះ នាយ ។

## [ នាយគោឃាតកៈ កាត់អណ្តាតគោមកអាំងបរិភោគ ]

នាយគោឃាតកៈនោះតបថា " យើងមិនបរិភោគទេ " ឲ្យករិយានាំកត្តនោះទៅហើយ , កាន់យកកាំបិតដើរទៅកាន់សម្នាក់គោដែលឈរនៅខាងក្រោយផ្ទះ ហើយលូកដៃចូលទៅក្នុងមាត់ទាញអណ្តាតចេញមក យកកាំបិតកាត់ត្រឹមគល់ ( អណ្តាត ) ហើយយកទៅឲ្យករិយាអាំងលើរងើកភ្លើងហើយដាក់លើកត្ត អង្គុយបរិភោគដុំកត្តមួយដុំ ដាក់ដុំសាច់មួយដុំទៅក្នុងមាត់ , ក្នុងខណៈនោះឯង អណ្តាតរបស់គាត់ដាច់

ធ្លាក់ចុះទៅក្នុងភាជនៈសម្រាប់ដាក់កត្ត ។ ក្នុងខណៈនោះឯង គាត់បានទទួលវិបាកដែលបុគ្គលគប្បីឃើញស្មើដោយកម្ម ។

បុរសអ្នកសម្លាប់គោនោះ មានខ្សែឈាមហូរចេញពីមាត់ ចូលទៅខាងក្នុងផ្ទះ ដើរដោយជង្គង់ ស្រែកដូចគោ ។

## ( បុត្ររបស់នាយគោឃាតកៈរត់ចេញអំពីផ្ទះ )

ក្នុងសម័យនោះ បុត្ររបស់គោឃាតកៈឈរមើលបិតា

មលវគ្គវណ្ណនា រឿងបុត្ររបស់បុរសអ្នកសម្លាប់គោ

ក្នុងទីជិត ។

គ្រានោះ ភរិយារបស់គាត់ពោលទៅកាន់បុត្ររបស់ខ្លួនថា " នែកូន កូនឯងចូរមើលបិតារបស់កូនឯងដែលដើរដោយជង្គង់ ស្រែកដូចគោចុះ សេចក្តីទុក្ខនេះនឹងធ្លាក់មកលើក្បាលរបស់កូនឯង , កូនឯងមិនចាំបាច់ព្រួយបារម្ភអំពីមាតា ចូរធ្វើសេចក្តីសួស្តីដល់ខ្លួន ហើយគេចចេញទៅចុះ " ។ បុត្ររបស់នាយគោឃាតកៈនោះ ត្រូវមរណភ័យគំរាម ថ្វាយបង្គំមាតាហើយរត់ចេញទៅ , លុះរត់ទៅហើយនោះ បានទៅកាន់នគរតក្កសិលា ។ ចំណែកនាយគោឃាតកៈ ដែលដើរដោយ

ជន្គន់ ស្រែកដូចគោនៅក្នុងផ្ទះនោះ ធ្វើកាលកិរិយា ហើយកើតក្នុងអវិចីនរក ។ ចំណែកគោក៏ងាប់ទៅដែរ ។ រីឯបុត្ររបស់នាយគោឃាតកនោះ ទៅដល់នគរតក្កសិលា រៀនការងាររបស់ជាងមាស ។ គ្រានោះ អាចារ្យរបស់គេ មុននឹងទៅផ្ទះបានប្រាប់គេថា " ឯងចូរធ្វើគ្រឿងប្រដាប់បែបនេះ " ហើយចៀសចេញទៅ ។ គេក៏បានធ្វើគ្រឿងប្រដាប់ តាមដែលអាចារ្យឲ្យធ្វើ ។ គ្រានោះ អាចារ្យរបស់គេមក ឃើញគ្រឿងប្រដាប់នោះហើយ ត្រិះរិះថា " បុរសនេះទៅកាន់ទី



ណា ក៏អាចចិញ្ចឹមជីវិតបានដែរ " ទើបបានឲ្យធីតាដែលពេញវ័យរបស់ខ្លួន ( ដល់គេ ) ។ ចាប់ពីពេលនោះមក គេក៏ចម្រើនដោយបុត្តធីតា ។

## [ កូនធ្វើបុណ្យឲ្យឪពុក ]

គ្រានោះ បុត្រទាំងឡាយរបស់គេ ចម្រើនវ័យហើយ រៀនសិល្បៈ , ក្រោយមក បានទៅកាន់ក្រុងសាវត្ថី រស់នៅក្នុងនគរនោះវិញ បានជាអ្នកមានសទ្ធាជ្រះថ្លា ។ ចំណែកបិតា

របស់ពួកគេមិនបានធ្វើកុសលអ្វីសោះឡើយ ដល់ការចាស់ជរានៅក្នុងនគរតក្កសិលានោះ ។ គ្រានោះ ពួកបុត្ររបស់គេប្រឹក្សាគ្នាថា “ បិតារបស់យើងចាស់ហើយ ” ហើយឲ្យគេទៅអញ្ជើញបិតាមកកាន់ផ្ទះរបស់ខ្លួនហើយពោលថា “ ពួកខ្ញុំនឹងថ្វាយទានដើម្បីប្រយោជន៍ដល់បិតា ” ហើយនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ថ្ងៃស្អែកឡើង ពួកគេនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធប្រធានឲ្យគង់ក្នុងផ្ទះហើយ អង្គាសដោយគោរព ។ ក្នុងវេលាស្រេចភត្តកិច្ច ក្រាបទូលព្រះសាស្ដាថា “ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គថ្វាយភត្តនេះឲ្យជាជីវភត្ត ( ភត្តសម្រាប់មនុស្សនៅរស់ ) ដើម្បីបិតារបស់ពួក



ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់ធ្វើអនុមោទនាដល់បិតារបស់ពួកខ្ញុំព្រះអង្គចុះ ” ។

## [ ព្រះសាស្ដាទ្រង់សម្ដែងធម៌ ]

ព្រះសាស្ដា ត្រាស់ហៅបិតារបស់ពួកគេមក ហើយត្រាស់ថា “ ម្នាលឧបាសក អ្នកជាមនុស្សចាស់ មានសរីរៈ

ចាស់ដោយជុំវិញ ប្រៀបដូចជាស្លឹកឈើទុំមានពណ៌លឿង ហើយស្លៀង គឺកុសលដើម្បីនឹងទៅកាន់បរលោករបស់អ្នក មិនទាន់មាន , អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនចុះ , ចូរជាបណ្ឌិត កុំជាមនុស្សពាលឡើយ ” ដូច្នេះហើយ កាលនឹងទ្រង់ធ្វើ អនុមោទនា ទើបបានត្រាស់ព្រះគាថាទាំងនេះថា :-

បណ្ឌុបលាសោវទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ បតិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ទិព្វំ អរិយភូមិមេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួក បុរសរបស់យមរាជប្រាកដដល់អ្នកហើយ ខ្លួនអ្នក

តាំងនៅក្នុងមាត់នៃសេចក្ដីវិនាស សូម្បីស្បៀង គឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក ( ធ្វើយ៉ាងនេះហើយ ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈដូចជាទិព្វបាន ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បណ្ឌុបលាសោវទានិសិ** សេចក្ដីថា នែឧបាសក ឥឡូវនេះ អ្នកដូចជាស្លឹកឈើទុំដែលដាច់ធ្លាក់ចុះលើផែនដី ។

ទូតរបស់យមរាជ ព្រះមានព្រះភាគ ត្រាស់ហៅថា **យមបុរិសា** ។ ក៏ប៉ុន្តែ ព្រះពុទ្ធតម្រាស់នេះ ព្រះអង្គត្រាស់សំដៅដល់សេចក្ដីស្លាប់នោះឯង ។ អធិប្បាយថា សេចក្ដី



ស្លាប់ប្រាកដដល់អ្នកហើយ ។

បទថា **ឧយ្យោគមុខេ** សេចក្ដីថា អ្នកជាបុគ្គលស្ថិតនៅក្នុងប្រធាននៃសេចក្ដីសាបសូន្យ គឺជិតមាត់នៃសេចក្ដីមិនចម្រើន ។

បទថា **បាថេយ្យំ** សេចក្ដីថា ស្បៀងស្បៀង គឺកុសលរបស់អ្នកសម្រាប់ទៅកាន់បរលោក ក៏មិនទាន់មាន ដូចជាស្បៀងសម្រាប់ដើរផ្លូវ មានអង្ករជាដើម របស់បុគ្គលអ្នកត្រៀមនឹងទៅ មិនទាន់មានដូច្នោះ ។

ពីរបទថា **សោ ករោហិ** សេចក្ដីថា អ្នកចូរធ្វើនូវទីពឹងគឺកុសលសម្រាប់ខ្លួនទៅ ប្រៀបដូចបុគ្គលកាលសំពៅបែកក្នុងសមុទ្រ ធ្វើទីពឹងពោលគឺកោះ ( សម្រាប់ខ្លួន ) ដូច្នោះ , ហើយកាលអ្នកធ្វើនូវទីពឹងសម្រាប់ខ្លួននោះ ចូរព្យាយាមយ៉ាងឆាប់ គឺចូរប្រារព្ធនូវសេចក្ដីព្យាយាម យ៉ាងប្រញាប់ប្រញាល់ ចូរជាបណ្ឌិត ដោយការធ្វើនូវទីពឹង ពោល គឺកុសលកម្មសម្រាប់ខ្លួន , ត្បិតថា បុគ្គលណាធ្វើកុសលក្នុងកាលដែលខ្លួនមិនទាន់ដល់មាត់នៃសេចក្ដីស្លាប់ ជាកាលដែលខ្លួនអាចធ្វើបាននោះ, បុគ្គលនោះឈ្មោះថាជាបណ្ឌិត អធិប្បាយ

ថា អ្នកចូរជាបុគ្គលដូច្នោះ កុំជាបុគ្គលពាលឡើយ ។

ពីរបទថា **ទិព្វំ អរិយភូមឹ** សេចក្តីថា បើអ្នកធ្វើយ៉ាង នេះហើយ នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបានហើយ ព្រោះ ជាអ្នកនាំមន្ទិល មានរាគៈជាដើមចេញបាន , ឈ្មោះថា មិន មានកិលេសដូចជាទីទួល គឺអស់កិលេស ព្រោះមិនមាន កិលេសដូចជាទីទួល ហើយនឹងដល់នូវសុទ្ធាវាសភូមិដែល ជាទីនៅនៃព្រះអរិយបុគ្គលអ្នកបរិសុទ្ធហើយ ៥ ភូមិ ។

កាលចប់ទេសនា ឧបាសកតាំងនៅក្នុងសោតាបត្តិផល ទេសនាជាគុណជាតិនាំនូវប្រយោជន៍ សូម្បីដល់មហាជន ដែលប្រជុំគ្នានៅទីនោះ ។

## [ ពួកបុត្រថ្វាយទានម្តងទៀត ]

បុត្រទាំងនោះ ទូលនិមន្តព្រះសាស្តាដើម្បីថ្វាយទាន ទៀត ស្អែកឡើង ថ្វាយទានហើយ ក្រាបទូលព្រះសាស្តា ក្នុងកាលដែលទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ក្នុងវេលាទ្រង់ អនុមោទនាថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីភត្តនេះពួកខ្ញុំ

ព្រះអង្គក៏ថ្វាយឲ្យជាជីវភត្ត ដើម្បីបិតារបស់ពួកខ្ញុំព្រះអង្គដែរ , សូមព្រះអង្គ ទ្រង់ធ្វើអនុមោទនាដល់បិតារបស់ពួកខ្ញុំ



ព្រះអង្គ ចុះ " ។

ព្រះសាស្តា កាលនឹងទ្រង់ធ្វើអនុមោទនាដល់ឧបាសកនោះ បានត្រាស់គាថា ២ គាថានេះថា :-

**ឧបនីតវយោ វទានិសិ**

**សម្បយាតោសិ យមស្ស សន្តិកំ**

**វាសោបិ ច តេ នត្ថិ អន្តរា**

**បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។**

**សោ ករោហិ ទីបមត្តនោ**

**ខិប្បំ វាយម បណ្ឌិតោ ភវ**

**និទ្ធន្តមលោ អនង្គណោ**

**ន បុន ជាតិជរំ ឧបេហិសិ ។**

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សម្នាក់យមរាជ មួយ

ទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ ស្បៀងក៏មិនមានដល់អ្នក ។ អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញ បើអ្នក ( ធ្វើយ៉ាងនេះហើយ )

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានមន្ទិល គឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈ ទៀតឡើយ ។

## អធិប្បាយគាថា

សព្ទថា **ឧប** ក្នុងបទថា **ឧបនីតវយោ** ក្នុងព្រះគាថានោះ ត្រឹមតែជានិបាត ។ អ្នកមានវ័យត្រូវជរានាំទៅហើយ បានដល់ មានវ័យកន្លងទៅហើយ ។ អធិប្បាយថា ឥឡូវនេះ អ្នកកន្លងវ័យទាំងបីហើយ ស្ថិតនៅក្នុងមាត់នៃមច្ចុរាជ ។

បាទព្រះគាថាថា **សម្បយាតោសិ យមស្ស សន្តិកំ** សេចក្តីថា អ្នកដំណើរទាំងឡាយ រមែងសំចតធ្វើកិច្ចនោះៗ ក្នុងចន្លោះផ្លូវយ៉ាងណា , អ្នកទៅកាន់បរលោក រមែងសំចត

នៅដូច្នោះមិនមាន ។ ព្រោះបុគ្គលអ្នកទៅកាន់បរលោកមិនអាចនឹងពោលពាក្យជាដើមថា “ អ្នកចូររង់ចាំពីរបីថ្ងៃសិន , ខ្ញុំឲ្យទានសិន ស្តាប់ធម៌សិន ” ។ បុគ្គលអ្នកទៅកាន់បរលោកចុតិចាកលោកនេះហើយ រមែងកើតក្នុងបរលោកភ្លាម, ពាក្យនោះ ព្រះសាស្តាត្រាស់សំដៅយកសេចក្តីនេះ ។

បទថា **បាថេយ្យំ** បទនេះ ជាបទដែលព្រះមានព្រះភាគ



ទ្រង់ត្រាស់ទុកខាងដើមហើយ ក៏ពិតមែន ប៉ុន្តែ ព្រះមានព្រះភាគទ្រង់កាន់យកក្នុងគាថាសូម្បីនេះ ក៏ដើម្បីទ្រង់ធ្វើឲ្យមាំរឿយៗ ដល់ឧបាសក , សូម្បីព្យាធិ និងមរណៈ ក៏ព្រះមានព្រះភាគទ្រង់កាន់យកក្នុងបទថា **ជាតិជរំ** នេះដែរ ។

ព្រះមានព្រះភាគ ត្រាស់អនាគាមិមគ្គដោយព្រះគាថាមុន , ត្រាស់ព្រះអរហត្តមគ្គដោយព្រះគាថានេះ ។ សូម្បីដូច្នោះក៏ដោយ ឧបាសកនោះ ទោះបីព្រះសាស្តាទ្រង់សម្តែងធម៌ដោយអំណាចនៃមគ្គខាងលើ ក៏សម្រេចសោតាបត្តិផលជាខាងក្រោម ហើយទើបសម្រេចអនាគាមិផលក្នុងវេលាចប់

អនុមោទនានេះ តាមកម្លាំងឧបនិស្ស័យរបស់ខ្លួន ដូចកាល ព្រះរាជាទ្រង់ពូតព្រះក្រយាហារ ប៉ុនព្រះឱស្ឋរបស់ព្រះអង្គ ហើយទ្រង់បង្អោនចូលទៅជិតព្រះរាជបុត្រ , ព្រះរាជកុមារ ទ្រង់ទទួលដោយប្រមាណព្រះឱស្ឋរបស់ខ្លួនប៉ុណ្ណោះដូច្នោះ ។

ព្រះធម្មទេសនា បានមានប្រយោជន៍ សូម្បីដល់បរិស័ទដ៏សេស ។l១៩៩

( រឿងបុត្ររបស់បុរសអ្នកសម្លាប់គោ ចប់ )

8888888888888888888888888888888888888

## ២ រឿងព្រាហ្មណ៍ម្នាក់

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **អនុបុព្វេន មេធាវី** ” មានបទដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយ ព្រាហ្មណ៍នោះចេញអំពីផ្ទះពីព្រលឹម, បានឈរមើលពួកភិក្ខុឃុំចីវរ ក្នុងទីជាទីឃុំរបស់ភិក្ខុទាំង-

ឡាយ ។ ក៏ទីនោះមានស្មៅដុះ ។ ក្រោយមកភិក្ខុមួយរូប ឃ្លុំចីវរ , ដាយចីវរប្រមៀលលើស្មៅ ទទឹកដោយដំណក់ទឹកសន្សើម ។ ព្រាហ្មណ៍ឃើញហេតុនោះហើយគិតថា “ យើងគួរធ្វើទីនេះឲ្យប្រាសចាកស្មៅ ” ស្អែកឡើង កាន់ចបទៅចូកចាំងទីនោះ បានធ្វើទីនោះឲ្យទៅជាទីប្រាកដស្មើដោយមណ្ឌលនៃលាន ។

ក្នុងថ្ងៃមួយទៀត កាលភិក្ខុមកកាន់ទីនោះឃ្លុំចីវរ , ព្រាហ្មណ៍ឃើញជាយចីវរ របស់ភិក្ខុមួយរូបធ្លាក់ទៅលើផែនដី ហើយប្រមៀលទៅលើអាចម៍ដី ទើបគិតថា “ ការដែល



យើងនាំខ្សាច់មករោយទីនេះគួរ ” ហើយនាំខ្សាច់មករោយទីនោះ ។

## [ ព្រាហ្មណ៍កសាងមណ្ឌប និងសាលា ]

ក្រោយមក នៅថ្ងៃមួយ ក្នុងវេលាមុនកត្ត មានកម្តៅថ្ងៃដ៏ខ្លាំង ។ ក្នុងពេលនោះ ព្រាហ្មណ៍ឃើញញើសហូរចេញ

អំពីកាយរបស់ពួកភិក្ខុដែលកំពុងឃ្លុំចីវរ ក៏គិតថា “ យើងគួរតែឲ្យគេសាងមណ្ឌបនៅទីនេះ ទើបត្រឹមត្រូវ ” លុះគិតដូច្នោះហើយ ក៏ប្រើគេឲ្យសាងមណ្ឌបនៅទីនោះ ។

ក្នុងថ្ងៃមួយទៀត មានភ្លៀងរំលោ ( ភ្លៀងព្រិល ) អំពីព្រលឹម ។ សូម្បីក្នុងកាលនោះ ព្រាហ្មណ៍ក៏ឈរមើលពួកភិក្ខុ , ឃើញចីវររបស់ពួកភិក្ខុទទឹកជោក ក៏គិតថា “ យើងគួរតែឲ្យគេកសាងសាលានៅទីនេះ ទើបត្រឹមត្រូវ ” លុះគិតដូច្នោះហើយ ក៏ប្រើគេឲ្យកសាងសាលានៅទីនោះ ហើយគិតថា “ ឥឡូវនេះ យើងនឹងធ្វើបុណ្យឆ្លងសាលានេះ ”, ទើបនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យភិក្ខុទាំងឡាយគង់ទាំងខាងក្នុង ទាំងខាងក្រៅ ហើយថ្វាយទាន , ក្នុងពេល

មលវគ្គវណ្ណនា រឿងព្រាហ្មណ៍ម្នាក់

ស្រេចភត្តកិច្ច ទទួលបាត្រព្រះសាស្តា ដើម្បីប្រយោជន៍ដល់ការទ្រង់អនុមោទនា ហើយក្រាបទូលរឿងនោះទាំងអស់តាំងអំពីដើមថា “ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឈរមើលទី

នេះ ក្នុងវេលាដែលពួកភិក្ខុឃ្មុំចីវរ ,ឃើញហេតុការណ៍យ៉ាង នេះៗ ទើបឲ្យគេកសាងវត្ថុនេះៗ ឡើង ” ។

## [ ព្រះសាស្ដាទ្រង់សម្ដែងធម៌ ]

ព្រះសាស្ដា ទ្រង់បានព្រះសណ្ដាប់នូវកាប្រព្រឹត្តរបស់ព្រាហ្មណ៍នោះហើយ ត្រាស់ថា “ ម្នាលព្រាហ្មណ៍ ធម្មតាបណ្ឌិតទាំងឡាយ ធ្វើកុសលបន្តិចម្ដងៗ គ្រប់ៗ ខណៈ, រមែងនាំមន្ទិល គឺអកុសលរបស់ខ្លួនចេញដោយលំដាប់ ” ដូច្នេះហើយ ទើបត្រាស់ ព្រះគាថានេះថា :-

**២ អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**
**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិច
ម្ដងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាង
មាស ជម្រះស្នឹម ឬច្រែះរបស់មាស ដូច្នោះ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អនុបុព្វេន** គឺដោយលំដាប់ , អ្នកប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថា មេធាវី ។

ពីរបទថា **ខណេ ខណេ** ធ្វើកុសលរាល់ៗ ឱកាស ។

បាទព្រះគាថាថា **កម្មារោ រជតស្សេវ** សេចក្ដីថា បណ្ឌិតធ្វើកុសលរឿយៗ ឈ្មោះថា កម្ចាត់បង់នូវមន្ទិល គឺកិលេស មានរាគៈជាដើមរបស់ខ្លួន , កាលបើដូច្នោះ បណ្ឌិតរមែងជាអ្នកឈ្មោះថា មានមន្ទិលខ្ចាត់ចេញហើយ គឺមិនមានកិលេស ដូចជាងមាសដុតហើយដំមាសនោះអស់វារៈតែម្ដង រមែងមិនអាចនាំចេញនូវស្នឹម ឬច្រែះ ហើយធ្វើគ្រឿងប្រដាប់ផ្សេងៗ បាន , ប៉ុន្តែ កាលជាងនោះដុត ហើយដំមាសនោះញយៗ រមែងនាំស្នឹម ឬច្រែះចេញបាន , ខាងក្រោយ រមែងធ្វើឲ្យទៅជាគ្រឿងប្រដាប់ផ្សេងៗ ច្រើនយ៉ាងបានដូច្នោះ ។

*មលវគ្គវណ្ណនា រឿងព្រាហ្មណ៍ម្នាក់*

ក្នុងកាលចប់ធម៌ទេសនា ព្រាហ្មណ៍នោះបានសម្រេចសោតាបត្តិផល , ទេសនាបានមានប្រយោជន៍ ដល់មហាជនដោយប្រការដូច្នេះឯង ។៚

( រឿងព្រាហ្មណ៍ម្នាក់ ចប់ )

# ៣ រឿងព្រះតិស្សត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលមាននាមថា តិស្សៈ ត្រាស់ព្រះធម្មទេសនានេះថា “ **អយសា វ មលំ សមុដ្ឋិតំ** ” ដូច្នេះជាដើម ។

## [ ព្រះតិស្សៈប្រគល់សំពត់សាដក សាច់គ្រោតគ្រាតឲ្យបងស្រី ]

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ បានបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថា “ ព្រះតិស្សត្ថេរ ” ។

ក្នុងកាលតមក ព្រះតិស្សត្ថេរនោះ ចូលចាំវស្សាក្នុងវិហារនៅជនបទ , បានសំពត់សាដក សាច់គ្រោតគ្រាតប្រមាណ ៨ ហត្ថ ចាំវស្សានៅទីនោះ លុះបវារណាចេញវស្សាហើយ ក៏កាន់សំពត់សាដកនោះទៅដាក់ជិតដៃបងស្រី , បងស្រីរបស់លោកគិតថា “ សំពត់សាដកមួយផ្ទាំងនេះមិនសម

គួរនឹងប្អូនប្រុសរបស់យើងទេ ” ហើយកាត់សំពត់សាដកនោះ ដោយកាំបិតដ៏មុត ធ្វើឲ្យជាចម្រៀកតូចចម្រៀកធំ , ដាក់ក្នុង



ត្បាល់ហើយបុក ហើយត្រដោះ ថ្ពួច រវៃ ការឲ្យទៅជាអំបោះមានសរសៃដ៏ល្អិត ហើយឲ្យជាងត្បាញជាសំពត់សាដក ។

## [ ព្រះថេរៈត្រៀមនឹងកាត់ចីវរ ]

ចំណែកព្រះថេរៈ ក៏ចាត់ចែងចេសនិងម្ជុល, និមន្តភិក្ខុកំលោះ និងសាមណេរអ្នកធ្វើចីវរឲ្យប្រជុំគ្នាហើយ ទៅកាន់សម្នាក់បងស្រី ហើយនិយាយថា “ បងស្រី ចូរឲ្យសំពត់សាដកមួយផ្ទាំងនោះដល់អាត្មាៗ នឹងធ្វើចីវរ ” ។

បងស្រីនោះ យកសំពត់សាដកប្រមាណ ៩ ហត្ថចេញមកដាក់ជិតដៃប្អូនប្រុស , ព្រះថេរៈទទួលយកសំពត់សាដកនោះមកពិចារណាហើយ ពោលទៅកាន់បងស្រីថា “បងស្រី សំពត់សាដករបស់អាត្មាសាច់គ្រោតគ្រោតប្រមាណ

៨ ហត្ថ , មួយផ្ទាំងនេះសាច់ល្អិត ហើយមានប្រមាណ ៩ ហត្ថ , សំពត់មួយផ្ទាំងនេះ មិនមែនសំពត់សាដករបស់អាត្មាទេ , នេះជាសំពត់សាដករបស់បង , អាត្មាភាពមិនត្រូវការសំពត់ផ្ទាំងនេះទេ, បងចូរឲ្យសំពត់សាដកផ្ទាំងនោះដល់អាត្មា



វិញ ” ។ បងស្រីតបថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាសំពត់របស់លោកម្ចាស់ហើយ , សូមលោកម្ចាស់ ទទួលយកចុះ ” ។ ព្រះថេរៈមិនព្រមទទួលយក ។

គ្រានោះ បងស្រីប្រាប់កិច្ចដែលខ្លួនធ្វើគ្រប់យ៉ាងដល់ព្រះថេរៈនោះហើយ បានប្រគេនព្រះថេរៈថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន នោះជាសំពត់របស់លោកម្ចាស់ហើយ, សូមលោកម្ចាស់ទទួលយកសំពត់នោះចុះ ” ។ លោកកាន់យកសំពត់នោះទៅកាន់វិហារ ផ្តើមចីវរកម្ម ។

## [ ព្រះថេរៈហួងហែងចីវរអនិច្ចធម្មទៅកើតជាចៃ ]

គ្រានោះ បងស្រីរបស់លោកចាត់ចែងវត្ថុទាំងឡាយ មានយាគូ និងភត្តជាដើម សម្រាប់ភិក្ខុសាមណេរដែលជួយធ្វើចីវររបស់លោកនោះ ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្នុងថ្ងៃដែលចីវរសម្រេចនោះ បងស្រីរបស់លោកឲ្យគេធ្វើសក្ការៈដ៏ក្រៃលែង ។ ព្រះថេរៈនោះសម្លឹងមើលចីវរហើយ កើតសេចក្តីស្រឡាញ់ចីវរនោះ ហើយគិតថា " ស្អែកនេះ អញនឹងដណ្តប់ចីវរនេះ " បត់ ( អង្កាញ់ ) ហើយទុកលើស្នូចីវរ,

**ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ**

ក្នុងរាត្រីនោះ មិនអាចញុំាងអាហារដែលខ្លួនធាន់ហើយនោះឲ្យរលួយបាន ក៏ធ្វើមរណភាព ទៅកើតជាមេចៃក្នុងចីវរនោះឯង ។

## [ ព្រះសាស្តាមិនឲ្យចែកចីវរ ]

ចំណែកបងស្រីរបស់លោក បានឮថា លោកអនិច្ចធម្ម ភាម ក៏ទួញយំបម្រះនទៀលទៅមក នៅជិតជើងភិក្ខុទាំងឡាយ ។ ពួកភិក្ខុធ្វើសរីរកិច្ច ( បូជាសព ) របស់លោក

ហើយ ក៏ប្រឹក្សាគ្នាថា “ ចីវរនោះជារបស់សង្ឃ ព្រោះមិនមានគិលានុបដ្ឋាក , ពួកយើងនឹងចែងចែកចីវរនោះ ” ហើយឲ្យនាំចីវរនោះចេញមក ។ ចំណែកឯចៃនោះ វត់ស្រែកទៅខាងនោះទៅនេះថា “ ភិក្ខុទាំងនេះចែកចីវររបស់យើង ” ។

ព្រះសាស្តា ទ្រង់គង់នៅក្នុងព្រះគន្ធកុដិ ទ្រង់ព្រះសណ្តាប់នូវសំឡេងនោះ ដោយសោតធាតុដ៏ជាទិព្វ ត្រាស់ថា “ ម្នាលអានន្ទ អ្នកចូរទៅប្រាប់ពួកភិក្ខុកុំអាលចែកចីវររបស់តិស្សៈ ចាំ ៧ ថ្ងៃទៀត សឹមចែក ” ។ ព្រះថេរៈក៏ឲ្យភិក្ខុទាំងឡាយធ្វើយ៉ាងនោះ ។

មលវគ្គវណ្ណនា រឿងព្រះតិស្សត្ថេរ

# [ ព្រះសាស្តាឲ្យចែកចីវររបស់ព្រះតិស្សៈ ]

ចំណែកចៃនោះងាប់ក្នុងថ្ងៃទី ៧ កើតក្នុងវិមានតុសិត, ក្នុងថ្ងៃទី ៨ ព្រះសាស្តាត្រាស់បញ្ជាថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចែកចីវររបស់តិស្សៈ ហើយកាន់យកចុះ ” ។ ភិក្ខុទាំងឡាយក៏បានធ្វើយ៉ាងនោះ ។

ពួកភិក្ខុសន្ទនាក្នុងធម្មសភាថា “ ហេតុដូចម្ដេចហ្ន៎ ? ទើបព្រះសាស្ដាឲ្យរក្សាចីវររបស់ព្រះតិស្សៈទុកអស់ ៧ ថ្ងៃ ហើយឲ្យកាន់យកក្នុងថ្ងៃទី ៨ ” ។

## [ តណ្ហាធ្វើឲ្យសត្វដល់នូវសេចក្ដីវិនាស ]

ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា “ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ?” កាលភិក្ខុទាំងនោះក្រាបទូលថា “ បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ” ទើបត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ តិស្សៈកើតជាចៃនៅក្នុងចីវររបស់ខ្លួន , កាលអ្នកទាំងឡាយចែកចីវរនោះ ចៃនោះ រត់ស្រែកទៅខាងនេះខាងនោះថា ភិក្ខុទាំងនេះចែកចីវររបស់អញ , កាលអ្នកទាំង

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ឡាយកាន់យកចីវរនោះ , ចៃនោះប្រទូស្តនឹងអ្នកទាំងឡាយហើយ គប្បីកើតក្នុងនរក , ព្រោះហេតុនោះ ទើបតថាគតឲ្យរក្សាចីវរនោះទុក ៧ ថ្ងៃសិន , ក៏ឥឡូវនេះ ចៃនោះកើតក្នុង

វិមានទៅឋានតុសិតហើយ ។ ព្រោះហេតុនោះ ទើបតថាគត អនុញ្ញាតការកាន់យកចីវរដល់អ្នកទាំងឡាយ ” ។ កាលភិក្ខុទាំងនោះក្រាបទូលទៀតថា “ បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា តណ្ហានេះ គ្រោតគ្រាតណាស់ហ្ន៎ ” ក៏ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ ដែលឈ្មោះថា តណ្ហារបស់សត្វទាំងនេះ គ្រោតគ្រាតណាស់ , ប្រែះកើតពីដែក រមែងកាត់ដែកនោះ រមែងធ្វើដែកនោះឲ្យវិនាស ធ្វើឲ្យជារបស់ប្រើប្រាស់មិនបាន យ៉ាងណា , តណ្ហានេះ ( ក៏ ) ដូច្នោះដែរ កើតឡើងក្នុងសន្តានចិត្តរបស់សត្វទាំងឡាយ ហើយរមែងញ៉ាំងសត្វទាំងនោះ ឲ្យកើតក្នុងអបាយ មាននរកជាដើម ឲ្យដល់នូវសេចក្តីវិនាស ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :-

## ៣ អយសា វ មលំ សមុដ្ឋិតំ

*មលវគ្គវណ្ណនា រឿងព្រះតិស្សត្ថេរ*

## តទុដ្ឋាយ តមេវ ខាទតិ

## ៦៧ អតិធោនចារិនំ

**សានិ កម្មានិ នយន្តិ ទុគ្គតី**

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះដែរ ។

## <u>អធិប្បាយគាថា</u>

បណ្ដាបទទាំងនោះ បទថា **អយសា** គឺអំពីដែក ។ បទថា **សមុដ្ឋិតំ** គឺកើតឡើងហើយ ។ បទថា **តទុដ្ឋាយ** លុះកើតឡើងអំពីដែកនោះ ។

ក្នុងបទថា **អតិធោនចារិនំ** បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យដូច្នេះ :-

បញ្ញាជាគ្រឿងពិចារណាបច្ច័យ ៤ ថា " ការបរិភោគនេះ ជាសេចក្ដីត្រូវការដោយបច្ច័យទាំងនុ៎ះ " ហើយបរិភោគ

ព្រះមានព្រះភាគត្រាស់ថា **ចោនា** , បុគ្គលប្រព្រឹត្តកន្លងបញ្ញា ដែលមានឈ្មោះថា **ចោនា** នោះ ឈ្មោះថា **អតិចោនចារី** ។

ព្រះមានព្រះភាគ ត្រាស់ជាពាក្យអធិប្បាយទុកដូច្នេះ ថា “ ច្រេះកើតឡើងអំពីដែក តាំងឡើងអំពីដែក រមែងស៊ីដែកនោះ យ៉ាងណាមិញ , កម្មទាំងឡាយរបស់ខ្លួន គឺកម្មទាំងនោះ ឈ្មោះថា ជារបស់ខ្លួននោះឯង ព្រោះកើតឡើងក្នុងខ្លួន រមែងនាំបុគ្គលអ្នកមិនពិចារណាបច្ច័យ ៤ ហើយបរិភោគ ឈ្មោះថា អ្នកប្រព្រឹត្តកន្លងបញ្ញាដែលមាន ឈ្មោះថា **ចោនា** ទៅកាន់ទុគ្គតិ ដូច្នោះដែរ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ល។

( រឿងព្រះតិស្សត្ថេរ ចប់ )

8888888888888888888888888

# ៤ រឿងព្រះលោឡុទាយី

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលោឡុទាយី ត្រាស់ព្រះធម្មទេសនានេះថា “ **អសជ្ឈាយ-មលា មន្តា** ” ជាដើម ។

បានឮថា ពួកអរិយសាវកប្រមាណ ៥ កោដិក្នុងនគរសាវត្ថី ថ្វាយទានក្នុងវេលាមុនភត្ត ក្នុងវេលាក្រោយភត្តកាន់វត្ថុទាំងឡាយ មានទឹកដោះថ្លា ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ជាដើម ទៅកាន់វិហារហើយស្តាប់ធម្មកថា , ក្នុងវេលាស្តាប់ធម្មកថាហើយដើរទៅផ្ទះវិញ តែងពោលគុណរបស់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ។

ព្រះឧទាយិត្ថេរ ស្តាប់ពាក្យរបស់អរិយសាវកទាំង-នោះហើយ ក៏ពោលថា “ពួកអ្នកស្តាប់ធម្មកថារបស់ព្រះថេរៈទាំងពីររូបនោះ រមែងពោលយ៉ាងនេះទៅហើយ , បើបានស្តាប់ធម្មកថារបស់អញទៀត នឹងពោលយ៉ាងណាទៅហ្ន៎ ។

ពួកមនុស្សស្តាប់ពាក្យរបស់លោកហើយ គិតថា “ព្រះ



ថេរៈរូបនេះ នឹងជាព្រះធម្មកថិកឯកមួយរូប , ពួកយើងគួរតែស្តាប់ធម្មកថារបស់ព្រះថេរៈរូបនេះ ” ថ្ងៃមួយ ពួកមនុស្សទាំងនោះអារាធនាលោកថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះ ជាថ្ងៃស្តាប់ធម៌របស់ខ្ញុំព្រះករុណា ”, ថ្វាយទានចំពោះព្រះសង្ឃ ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ពោលធម្មកថាក្នុងថ្ងៃនេះចុះ ” ។ ចំណែកព្រះថេរៈរូបនោះ ក៏ទទួលនិមន្តរបស់មនុស្សទាំងនោះ ។

## [ ព្រះថេរៈមិនអាចសម្តែងធម៌បាន ]

កាលមនុស្សទាំងនោះ មកក្នុងវេលាស្ដាប់ធម៌ ហើយពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្ដែងធម៌ដល់ពួកខ្ញុំព្រះករុណាចុះ ”, ព្រះលោឡុទាយីគង់លើអាសនៈហើយ កាន់ផ្លិតដ៏វិចិត្រញ៉ាំងផ្លិតឲ្យកម្រើក(បក់), មិនឃើញបទធម៌សូម្បីតែមួយបទ ក៏ពោលថា “ អាត្មាភាពនឹងសូត្រសរភញ្ញ, ទុកឲ្យភិក្ខុដទៃសម្ដែងធម្មកថាចុះ ” ដូច្នេះហើយ ក៏ចុះចាកអាសនៈ ។ មនុស្សទាំងនោះ និមន្តភិក្ខុដទៃឲ្យសម្ដែងធម្មកថាហើយនិមន្តព្រះលោឡុទាយីឡើងកាន់អាសនៈ

មលវគ្គវណ្ណនា រឿងព្រះលោឡុទាយី

ម្ដងទៀត ដើម្បីសូត្រសរភញ្ញ , ព្រះលោឡុទាយីនោះ មិនឃើញបទធម៌ណាៗ ទៀត ក៏ពោលថា “ អាត្មានឹងពោលក្នុងវេលាយប់, ទុកឲ្យភិក្ខុដទៃសូត្រសរភញ្ញចុះ ” ហើយចុះចាកអាសនៈ មនុស្សទាំងនោះ និមន្តភិក្ខុដទៃឲ្យសូត្រសរភញ្ញហើយនិមន្តព្រះថេរៈក្នុងវេលាយប់ទៀត , ព្រះថេរៈនោះក៏នៅតែមិនឃើញបទធម៌ណាៗ សូម្បីក្នុងវេលាយប់ហើយក៏ពោល

ថា “ អាត្មានឹងពោលក្នុងវេលាជិតភ្លឺ , ទុកឲ្យភិក្ខុដទៃពោលក្នុងវេលាយប់ចុះ ” ហើយក៏ចុះចាកអាសនៈ ។ មនុស្សទាំងនោះ និមន្តភិក្ខុរូបដទៃឲ្យពោលធម្មកថា ក្នុងវេលាយប់ ហើយក្នុងវេលាជិតភ្លឺ បានទៅនិមន្តព្រះថេរៈនោះមកទៀត ។ ព្រះថេរៈនោះ សូម្បីជិតភ្លឺ ក៏មិនបានឃើញបទណាៗ ដែលខ្លួនត្រូវលើកយកមកសម្ដែង ។

## [ ព្រះថេរៈត្រូវមហាជនដេញធ្លាក់រណ្ដៅលាមក ]

មហាជន កាន់វត្ថុទាំងឡាយមានដុំដី និងដំបងជាដើម ហើយគំរាមថា “ នែ ភិក្ខុអន្ធពាល កាលពួកយើងពោលសរសើរគុណរបស់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន លោក



តែងពោលយ៉ាងនេះផង យ៉ាងនេះផង , ឥឡូវនេះ ព្រោះហេតុអ្វី ទើបលោកមិនពោល ?” ដូច្នេះហើយ ក៏ដេញតាមព្រះថេរៈដែលរត់គេចទៅនោះ ។ ព្រះថេរៈរូបនោះរត់ទៅធ្លាក់ក្នុងវច្ចកុដិ ។

មហាជនសន្ទនាគ្នាថា “ ព្រះលោឡុទាយីនោះ កាលពាក្យសរសើរគុណព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានកំពុងតែប្រព្រឹត្តទៅនោះ ប្រណែន ហើយអួតអាង ប្រកាសខ្លួនថា ជាធម្មកថិក , កាលមហាជនធ្វើសក្ការៈហើយ ពោលថា ពួកខ្ញុំនឹងស្តាប់ធម៌ , អង្គុយលើអាសនៈអស់វារៈ ៤ ដង មិនឃើញបទធម៌ណាៗ ដែលខ្លួនគប្បីលើកឡើងមកសម្តែង ត្រូវមហាជនកាន់វត្ថុទាំងឡាយ មានដុំដី និងដំបងជាដើម ហើយគំរាមថា លោកកាន់យកនូវការកាន់យកដោយភារៈជាគូ មួយអន្ទើដោយព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ដែលជាម្ចាស់របស់ពួកយើង , ហើយដេញឲ្យធ្លាក់រច្ចកុដិ ។

## [ បុព្វកម្មរបស់ព្រះលោឡុទាយី ]

ព្រះសាស្តា ស្តេចមកហើយ ត្រាស់សួរថា “ ម្នាល



ភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី ?” កាលភិក្ខុទាំងនោះក្រាបទូលថា “ ដោយរឿងឈ្មោះនេះ ព្រះ

អគ្គ ” ទើបត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ , សូម្បីក្នុងកាលមុន លោឡុទាយីនេះ ក៏ធ្លាប់ធ្លាក់ក្នុងរណ្តៅលាមកដែរ ” ដូច្នេះហើយ ទ្រង់នាំអតីតទានមក ត្រាស់ជាតកនេះឲ្យពិស្តារថា :-

ម្នាលសម្លាញ់ អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសម្លាញ់ អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសម្លាញ់ អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ចេញ ?

ម្នាលសូករៈ អ្នកមានកាយមិនស្អាត មានរោមប្រឡាក់ដោយវត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងគ្នាម្នាលសម្លាញ់ យើងឲ្យជ័យដល់អ្នកឯង ។

ដូច្នេះហើយ ត្រាស់ថា “ រាជសីហ៍ក្នុងកាលនោះបានមកជាសារីបុត្រ , សូករៈបានមកជាលោឡុទាយី ” ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ លោឡុទាយី រៀនធម៌បាន

បន្តិចបន្តួច ហើយមិនបានធ្វើការស្វាធ្យាយន៍ផង , ការរៀនបរិយត្តិយ៉ាងណាមួយហើយ មិនធ្វើការស្វាធ្យាយនូវបរិយត្តិនោះ ជាមន្ទិលមែនពិត " ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :-

៤ អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

មន្តទាំងឡាយមានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល សេចក្ដីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្ដីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អសជ្ឈាយមលា** ជាដើម សេចក្ដីថា ព្រោះបរិយត្តិ ឬសិល្បៈយ៉ាងណាមួយ កាលបុគ្គលមិនស្វាធ្យាយ មិនប្រកបរឿយៗ រមែងវិនាសទៅ ឬមិន

ប្រាកដជាប់តគ្នា ហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា " **អសជ្ឈាយមលា មន្តា** " ។

មលវគ្គវណ្ណនា រឿងព្រះលោឡុទាយី

ម្យ៉ាងទៀត ឈ្មោះថា ផ្ទះរបស់បុគ្គលអ្នកនៅគ្រប់គ្រង ក្រោកឡើងហើយមិនធ្វើកិច្ច មានការជួសជុលសម្ភារៈដែលគ្រាំគ្រាជាដើម រមែងវិនាស ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា " **អនុដ្ឋានមលា ឃរា** " ។

ព្រោះកាយរបស់គ្រហស្ថ ឬថាជាបព្វជិត កាលមិនធ្វើការជម្រះសរីរៈ ឬការជម្រះបរិក្ខារ ដោយអំណាចនៃសេចក្ដីខ្ជិល រមែងមានពណ៌សម្បុរសៅហ្មង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា " **មលំ វណ្ណស្ស កោសជ្ជំ** "។

ម្យ៉ាងទៀត ព្រោះកាលបុគ្គលរក្សាគោ ដេកលក់ ឬលេងដោយអំណាចនៃសេចក្ដីប្រមាទ , គោទាំងនោះ រមែងដល់នូវសេចក្ដីវិនាស ដោយហេតុទាំងឡាយ មានរត់ទៅកាន់ទីដែលមិនមែនជាកំពង់ទឹកជាដើមខ្លះ ដោយអន្តរាយ មាន

ពាលម្រឹគ និងចោរជាដើមខ្លះ ដោយអំណាចនៃការចុះកាន់ទីទាំងឡាយ មានស្រែស្រូវសាលីជាដើមរបស់ជនដទៃខ្លះ , សម្បត្តិខ្លួនឯង ក៏រមែងដល់នូវអាជ្ញា និងការបរិភាសជាដើម ។

ម្យ៉ាងទៀត កិលេសទាំងឡាយ រួបរឹតដោយអំណាច



នៃសេចក្តីប្រមាទ រមែងញ៉ាំងបព្វជិតអ្នកមិនរក្សាទ្វារទាំង ៦ ឲ្យឃ្លាតចាកសាសនា , ហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា “ **បមាទោ រក្ខតោ មលំ** ” អធិប្បាយថា ក៏សេចក្តីប្រមាទនោះ ឈ្មោះថា ជាមន្ទិល ព្រោះសេចក្តីប្រមាទជាទីតាំងនៃមន្ទិល ដោយការនាំមកនូវសេចក្តីវិនាស ។

លុះចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ល។

( រឿងព្រះលោឡុទាយិត្ថេរ ចប់ )

888888888888888888888888888888

# ៥ រឿងកុលបុត្រម្នាក់

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធកុលបុត្រម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា " **មលិត្ថិយា ទុច្ចរិតំ** " ជាដើម ។

## [ ស្វាមីខ្មាសព្រោះភរិយាក្បត់ ]

សេចក្ដីពិស្ដារថា មាតា និងបិតាបាននាំកុលធីតាអ្នកមានជាតិស្មើគ្នាមកដើម្បីកុលបុត្រនោះ ។ នាងជាស្ត្រីប្រព្រឹត្ត

ក្បត់ចិត្ត ( ស្វាមី ) ចាប់តាំងអំពីថ្ងៃដែលនាំមកនោះ កុលបុត្រខ្មាស ព្រោះការប្រព្រឹត្តក្បត់របស់នាង មិនអាចកាន់យកនូវភារៈជាអ្នកមានមុខចំរកអ្នកណាម្នាក់បាន ផ្តាច់ចោលនូវបុញ្ញ-កិរិយាវត្ថុទាំងឡាយ មានការបម្រើព្រះពុទ្ធជាដើម ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ កាលព្រះសាស្តាត្រាស់ថា " នែឧបាសក ព្រោះហេតុអ្វី អ្នកបាត់មុខយូរម្ល៉េះ ?" ទើបក្រាបទូលរឿងនោះចំពោះព្រះសាស្តា ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

## [ ស្ត្រីប្រៀបដូចវត្ថុ ៥ យ៉ាង ]

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់កុលបុត្រនោះថា " នែឧបាសក សូម្បីកាលពីមុន តថាគតក៏បានពោលហើយថា ឈ្មោះថា ស្ត្រីទាំងឡាយ ប្រៀបដូចជាសាធារណវត្ថុទាំងឡាយ មានស្ទឹងជាដើម បណ្ឌិតមិនគួរខឹងក្រោធនឹងស្ត្រីទាំងនោះទេ , ប៉ុន្តែឧបាសកឯងចាំមិនបាន ព្រោះត្រូវភពបិទបាំង "

កាលកុលបុត្រនោះអារាធនា ក៏ទ្រង់ត្រាស់ជាតកឲ្យពិស្តារថា "ធម្មតាស្ត្រីក្នុងលោក ប្រៀនដូចជាស្ទឹង ផ្លូវ រោងសុរា រោងសម្រាប់ប្រជុំ និងអណ្តូងទឹក , វេលាវម៉េងមិនមានដល់ស្ត្រីទាំងនោះ ។

ដូច្នេះហើយ ត្រាស់ថា " ម្នាលឧបាសក ការប្រព្រឹត្តក្បត់ ជាមន្ទិលរបស់ស្ត្រី , សេចក្តីកំណាញ់ ជាមន្ទិលនៃអ្នកឲ្យទាន , អកុសលកម្ម ជាមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះ និងលោកខាងមុខ ព្រោះអត្ថថា ជាគ្រឿងញុំាងសត្វឲ្យវិនាស, ប៉ុន្តែអវិជ្ជាជាមន្ទិលយ៉ាងក្រៃលែងជាងមន្ទិលទាំងពួង " ដូច្នេះហើយ ទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

មលវគ្គវណ្ណនា រឿងកុលបុត្រម្នាក់

៥ មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច
តតោ មលា មលតរំ អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។

ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាតិ ជាមន្ទិលដ៏លើសលុបជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

## អធិប្បាយគាថា

ការប្រព្រឹត្តក្បត់ចិត្តប្តី ឈ្មោះថា ការប្រព្រឹត្តអាក្រក់ក្នុងព្រះគាថានោះ ។ ស្វាមីរមែងបណ្តេញស្ត្រីអ្នកប្រព្រឹត្តក្បត់ចិត្តចេញចាកផ្ទះ , ស្ត្រីនោះទៅកាន់សម្នាក់មាតាបិតា ( ត្រូវ ) មាតាបិតាបណ្តេញដោយពាក្យថា " នាងឯងមិនគោរពត្រកូល

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

យើងមិនចង់ឃើញនាងឯង ដោយក្អែកទាំងពីររបស់យើងទេ " ស្ត្រីនោះអស់ទីពឹង រមែងដល់នូវសេចក្តីលំបាក , ព្រោះ

ហេតុនោះ ទើបព្រះសាស្តា ត្រាស់ការប្រព្រឹត្តក្បត់ចិត្តប្តីថា " ជាមន្ទិល " ។

បទថា **ទទតោ** ប្រែថា របស់អ្នកឲ្យ ។ ក៏បុគ្គលណា ក្នុងវេលាភ្ជួរស្រែ គិតថា " កាលសន្ទូងនេះសម្រេចហើយ , យើង និងថ្វាយភត្តទាំងឡាយ មានសលាកភត្តជាដើម ", កាលសន្ទូងនោះសម្រេចផលហើយ , សេចក្តីកំណាញ់កើតឡើងហាមឃាត់ចិត្តដែលសម្បយុត្តដោយចាគៈ, បុគ្គលនោះ កាលចិត្តសម្បយុត្តជាមួយនឹងចាគៈ មិនដុះដាលឡើងដោយអំណាចនៃសេចក្តីកំណាញ់ រមែងមិនបាននូវសម្បត្តិបីយ៉ាង គឺសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វាន , ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា " សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ" ។ សូម្បីក្នុងបទដទៃៗ ដែលមានគំរូយ៉ាងនេះ ក៏មានន័យដូច្នោះដែរ ។

ពីរបទថា **បាបកា ធម្មា** សេចក្តីថា ក៏អកុសលធម៌

ទាំងឡាយជាមន្ទិលទាំងនោះ ជាមន្ទិលទាំងលោកនេះ ទាំងលោកខាងមុខ ។

បទថា **តតោ** សេចក្ដីថា ជាងមន្ទិលដែលត្រាស់ហើយក្នុងខាងដើម ។

បទថា **មលតរំ** សេចក្ដីថា តថាគតនឹងប្រាប់នូវមន្ទិលដ៏ក្រៃលែង ដល់អ្នកទាំងឡាយ ។

បទថា **អវិជ្ជា** សេចក្ដីថា ការមិនដឹងនូវវត្ថុ ៨ យ៉ាងនោះ ជាមន្ទិលយ៉ាងក្រៃលែង ។

បទថា **បហន្ត្វាន** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយលះមន្ទិលនោះបានហើយ រមែងជាអ្នកមិនមានមន្ទិល ។

កាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ៕ល៚

( រឿងកុលបុត្រម្នាក់ ចប់ )

8888888888888888888888

# ៦ រឿងភិក្ខុឈ្មោះចូឡសារី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ឈ្មោះចូឡសារី ទើបត្រាស់ព្រះធម្មទេសនានេះថា “ **សុជីវំ អហិរិកេន** ” ជាដើម ។

## [ ព្រះចូឡសារីបានភោជនព្រោះធ្វើវេជ្ជកម្ម ]

បានឮថា ថ្ងៃមួយ ព្រះចូឡសារីនោះធ្វើវេជ្ជកម្មហើយបានភោជនដ៏ប្រណីត ហើយកាន់ចេញទៅជួបព្រះថេរៈតាមផ្លូវ ក៏ប្រាប់ថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោជននេះ ខ្ញុំព្រះករុណាបានដោយការធ្វើពេទ្យ , លោកម្ចាស់នឹងមិនបានភោជនបែបនេះក្នុងទីដទៃទេ , ដូច្នោះ សូមលោកម្ចាស់និមន្តឆាន់ភោជននេះចុះ , ខ្ញុំព្រះករុណានឹងធ្វើពេទ្យ ហើយនាំយកអាហារបែបនេះមក ដើម្បីលោកម្ចាស់អស់កាលជានិច្ច ” ។

ព្រះថេរៈស្តាប់ពាក្យរបស់ព្រះចូឡសារីនោះហើយ ក៏ស្ងៀម ហើយនិមន្តចេញទៅ ។ ភិក្ខុទាំងឡាយ មកកាន់វិហារហើយ ក្រាបទូលសេចក្តីនោះចំពោះព្រះសាស្តា ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

## [ អ្នកតាំងនៅក្នុងអនេសនកម្មរស់នៅស្រួល ]

ព្រះសាស្តា ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លាដូចជាសត្វក្អែកតាំងនៅក្នុងអនេសនៈ ២១ រមែងរស់នៅដោយស្រួល, ចំណែកបុគ្គលអ្នកសម្បូរដោយហិរិ និងឱត្តប្បៈ រមែងរស់នៅដោយលំបាក ” ដូច្នេះហើយ ទ្រង់ភាសិតព្រះគាថាទាំងនេះថា :-

៦ សុជីវំ អហិរិកេន　　កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន　　សង្កិលិដ្ឋេន ជីវិតំ ។
ហិរីមតា ច ទុជ្ជីវំ　　និច្ចំ សុចិគវេសិនា
អលីនេនាបគព្ភេន　　សុទ្ធាជីវេន បស្សតា ។

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លា

ដូចជា សត្វក្អែក កម្ចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន ( យកមុខ ) ជាអ្នកឃ្នើសឃ្នង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្ដីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនទ្បេះទ្បោះមិនឃ្នើសឃ្នង រស់នៅ

មលវគ្គវណ្ណនា រឿងភិក្ខុឈ្មោះចូឡសារី

ដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អហិរិកេន** អ្នកមិនមានហិរិ និងឱត្តប្បៈ អធិប្បាយថា បុគ្គលបែបនោះអាចហៅស្ត្រីដែលមិនមែនជាមាតារបស់ខ្លួនថា “ មាតារបស់យើង ” ហៅបុរសទាំងទ្បាយដែលមិនមែនបិតាជាដើមនោះ ដោយន័យជាដើមថា “ បិតារបស់យើង ” តាំងនៅក្នុងអនេសនៈ ២១ រស់នៅដោយងាយ ។

បទថា **កាកសូរេន** បានដល់ ក្លៀវក្លាដូចជាសត្វក្អែកៗ អធិប្បាយថា ដូចយ៉ាងថា ក្អែកដ៏ក្លៀវក្លា ប្រាថ្នានឹងចឹកវត្ថុទាំងឡាយ មានបបរជាដើម ក្នុងផ្ទះនៃត្រកូលទាំងឡាយ ទំនៅក្នុងទីទាំងឡាយ មានជញ្ជាំងផ្ទះជាដើម ដឹងថា ម្ចាស់ផ្ទះសម្លឹងមើលខ្លួន ក៏ធ្វើដូចជាមិនសម្លឹងមើល ដូចជាបញ្ជូនចិត្តទៅកាន់ទីដទៃ ហើយធ្វើដូចជាដេកលក់ ដឹងថា ម្ចាស់ផ្ទះទាំងឡាយមានសេចក្តីធ្វេសប្រហែសក៏រំកិលចុះ , កាលម្ចាស់ផ្ទះ



ដេញថា " **សុ សុ** " ក៏ចឹកយកអាហារអំពីភាជនៈពេញមាត់ ហើយហើរចេញទៅ យ៉ាងណាមិញ , បុគ្គលអ្នកមិនមានហិរិ គឺសេចក្តីអៀនខ្មាសក៏ដូច្នោះដែរ ចូលទៅកាន់ស្រុកជាមួយនឹងភិក្ខុទាំងឡាយហើយ រមែងកំណត់នូវទីទាំងឡាយ មានទីនៃបបរ និងទីនៃភត្តជាដើម , ភិក្ខុទាំងឡាយត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ ទទួលយកអាហារគ្រាន់តែញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ហើយទៅកាន់រោងឆាន់ពិចារណា ឆាន់

យាគូហើយ ធ្វើទុកក្នុងចិត្តចំពោះកម្មដ្ឋាន ហើយស្វាធ្យាយ បោសសំអាតរោងឆាន់ , ចំណែកបុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាសមិនធ្វើវត្តអ្វីៗ ទាំងអស់ ជាអ្នកមានមុខព្រោះទៅកាន់ស្រុកតែម្យ៉ាង , បុគ្គលនោះសូម្បីភិក្ខុទាំងឡាយប្រាប់ថា “ អ្នកចូរមើលបុគ្គលនេះ ” ហើយសម្លឹងមើល ធ្វើដូចជាមិនសម្លឹងមើល ធ្វើហាក់ដូចជាបញ្ជូនចិត្តទៅកាន់ទីដទៃ ដូចជាដេកលក់ ដូចជាដោះក្ដុំចីវរ ដូចជាកំពុងធ្វើចីវរ ហើយនិយាយថា “ ការងាររបស់យើងឯណោះមានច្រើន ” ក្រោកចាកអាសនៈចូលទៅស្រុក ចូលទៅកាន់ផ្ទះមួយក្នុងចំណោម

មលវគ្គវណ្ណនា រឿងភិក្ខុឈ្មោះចូឡសារី

ផ្ទះដែលខ្លួនកំណត់ទុកហើយអំពីព្រឹក , កាលពួកមនុស្សក្នុងផ្ទះនោះ សូម្បីបិទសន្ទឹកទ្វារបន្តិចហើយ អង្គុយខារអំបោះក្បែរទ្វារ , ប្រានសន្ទឹកទ្វារដោយដៃម្ខាង ហើយចូលទៅក្នុងផ្ទះ ។ ពេលនោះ មនុស្សទាំងនោះឃើញបុគ្គលនោះហើយសូម្បីមិនប្រាថ្នានឹងឲ្យ ក៏និមន្តឲ្យគង់លើអាសនៈ ហើយ

ប្រគេនវត្ថុទាំងឡាយ មានយាគូជាដើមដែលមាននៅក្នុងផ្ទះ , ភិក្ខុអ្នកមិនមានហិរិនោះ បរិភោគតាមសេចក្ដីត្រូវការហើយ កាន់យកវត្ថុដែលសេសសល់នោះដោយបាត្រ ហើយចៀសចេញទៅ , បុគ្គលនេះ ឈ្មោះថា អ្នកក្អៀវក្លាដូចជាសត្វក្អែក , បុគ្គលអ្នកមិនមានហិរិឱត្តប្បៈបែបនេះ រមែងរស់នៅដោយស្រួល ។

បទថា **ធំសិនា** សេចក្ដីថា ឈ្មោះថា អ្នកមានប្រក្រតីកម្ចាត់បង់គុណរបស់អ្នកដទៃ ព្រោះកាលមនុស្សទាំងឡាយពោលពាក្យជាដើមថា “ព្រះថេរៈឯណោះ ជាអ្នកមានសេចក្ដីប្រាថ្នាតិច ”, កម្ចាត់បង់នូវគុណរបស់បុគ្គលទាំងនោះចេញដោយពាក្យជាដើមថា “ពួកយើងមិនមែនជាអ្នកប្រាថ្នាតិចទេ



ឬ ?” មនុស្សទាំងឡាយ ស្ដាប់ពាក្យរបស់បុគ្គលបែបនោះហើយ កាលសម្គាល់ថា “ សូម្បីបុគ្គលនេះក៏ជាអ្នកប្រកបដោយគុណ មានភាពប្រាថ្នាជាដើម ” រមែងសម្គាល់នូវវត្ថុ

ដែលខ្លួនគួរឲ្យ ។ ប៉ុន្តែថា ចាប់ផ្តើមអំពីកាលនោះទៅ បុគ្គលអ្នកបាត់គុណនោះ មិនអាចញ៉ាំងចិត្តរបស់វិញ្ញូបុរសទាំងឡាយឲ្យត្រេកអរបាន ថែមទាំងសាបសូន្យបាកលាភនោះទៀត ។ បុគ្គលអ្នកកម្ចាត់គុណយ៉ាងនេះ រមែងញ៉ាំងលាភទាំងឡាយរបស់ខ្លួន និងរបស់អ្នកដទៃឲ្យវិនាសដោយពិត ”។

បទថា **បក្ខន្ទិនា** សេចក្តីថា អ្នកឈ្លានពានយកមុខ គឺជាអ្នកសម្តែងនូវកិច្ចរបស់ជនដទៃ ឲ្យដូចជាកិច្ចរបស់ខ្លួន ។ កាលភិក្ខុទាំងឡាយ ធ្វើវត្តក្នុងទីទាំងឡាយ មានលានព្រះចេតិយជាដើមអំពីព្រលឹម អង្គុយដោយការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានបន្តិចហើយក្រោកឡើង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត , ភិក្ខុអ្នកប្រព្រឹត្តឡេបឡប ឈ្លានពានយកមុខនោះលាងមុខហើយ ស្លៀកស្បង់អត្តភាពដោយសំពត់កាសាវៈមានពណ៌លឿងខ្ចី បន្តក់ភ្នែក និងលាបសីសៈជាដើមហើយ

*មលវគ្គវណ្ណនា រឿងភិក្ខុឈ្មោះចូឡសារី*

ឲ្យនូវការប្រហារដោយអម្បោសពីរបីអម្បោស ធ្វើដូចជាបោសលានព្រះចេតិយ ជាអ្នកមានមុខឆ្ពោះទៅកាន់ខ្លោងទ្វារ, មនុស្សទាំងឡាយ មកកាន់លានព្រះចេតិយ ដោយគិតថា " នឹងថ្វាយបង្គំព្រះចេតិយ នឹងធ្វើការបូជាដោយកម្រងផ្កា " ឃើញភិក្ខុអ្នកប្រព្រឹត្តឡែបឡប់នោះហើយ ក៏និយាយគ្នាថា " វិហារនេះ អាស្រ័យភិក្ខុកំលោះរូបនេះ ជាអ្នកបោសសម្អាតថែរក្សា , អ្នកទាំងឡាយកុំប្រមាទចំពោះភិក្ខុរូបនេះឡើយ " ដូច្នេះហើយ រមែងសម្គាល់នូវវត្ថុទាំងឡាយ ដែលខ្ញុំគប្បីប្រគេនចំពោះភិក្ខុរូបនោះ ។ បុគ្គលអ្នកប្រព្រឹត្តឡែបឡប់ឈ្លានពានយកមុខដូច្នេះ រមែងរស់នៅដោយស្រួល ។

បទថា **បគព្ភេន** សេចក្តីថា ជាអ្នកឃ្នើសឃ្នងដោយកាយជាដើម ។ ពីរបទថា **សង្កិលិដ្ឋេន ជីវិតំ** សេចក្តីថា បុគ្គលណាសម្រេចការចិញ្ចឹមជីវិតយ៉ាងនេះ ឈ្មោះថា ជាអ្នកសៅហ្មងហើយរស់នៅ ។ ការរស់ដូច្នោះ ឈ្មោះថា រស់នៅដ៏អាក្រក់ គឺរស់នៅដ៏លាមកដោយពិត ។

បទថា **ហិរិមតា ច** សេចក្តីថា បុគ្គលអ្នកបរិបូណ៌



ដោយហិរិ និងឱត្តប្បៈ រស់នៅបានដោយលំបាក ។ ព្រោះបុគ្គលនោះ រមែងមិនពោលពាក្យថា “ មាតារបស់យើង ” ជាដើមចំពោះស្ត្រី ដែលមិនមែនជាមាតាជាដើម ខ្ពើមរអើមបច្ច័យដែលកើតឡើង មិនប្រកបដោយធម៌ ដូចជាលាមកស្វែងរកបច្ច័យប្រកបដោយធម៌ ត្រាច់បិណ្ឌបាតតាមលំដាប់ផ្ទះ សម្រេចការចិញ្ចឹមជីវិត រមែងរស់នៅដ៏សៅហ្មង ( រស់នៅទាំងត្រដាបត្រដួស ) ។

បទថា **សុចិគវេសិនា** សេចក្តីថា ស្វែងរកកម្មទាំងឡាយ មានកាយកម្មជាដើមដ៏ស្អាតបរិសុទ្ធ ។ បទថា **អលីនេន** សេចក្តីថា មិនរួញរា មិនធុញទ្រាន់ក្នុងកិរិយាប្រព្រឹត្តទៅដើម្បីការរស់នៅ ។

ពីរបទថា **សុទ្ធាជីវេន បស្សតា** សេចក្តីថា ក៏បុគ្គលបែបនេះ ឈ្មោះថា ជាអ្នកមានអាជីវៈដ៏បរិសុទ្ធ , បុគ្គលអ្នក

មានអាជីវៈដ៏បរិសុទ្ធនេះនោះ ឃើញអាជីវៈដ៏បរិសុទ្ធនោះ ដោយភាពជាសារៈ រមែងរស់នៅដោយលំបាកដោយអំណាចនៃការរស់នៅដ៏សៅហ្មងនោះ ។

*មលវគ្គវណ្ណនា រឿងភិក្ខុឈ្មោះចូឡសារី*

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងភិក្ខុឈ្មោះចូឡសារី ចប់ )

8888888888888888888888

# ៧ រឿងឧបាសក ៥ នាក់

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **យោ បាណមតិមាបេតិ** ” មានបទដូច្នេះជាដើម ។

## [ ឧបាសកជជែកគ្នារឿងសីល ]

បានឮថា បណ្តាឧបាសកទាំងនោះ ឧបាសកម្នាក់តែងតែរក្សាសិក្ខាបទ គឺចេតនាវៀរចាកការសម្លាប់សត្វតែមួយ , ( ចំណែក ) ឧបាសកទាំងឡាយក្រៅនេះ រក្សាសិក្ខាបទទាំងឡាយក្រៅនេះ ។ ថ្ងៃមួយ ឧបាសកទាំងនោះជជែកគ្នាថា

“ យើងរមែងធ្វើកម្មដែលគេធ្វើបានដោយលំបាក ” ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលរឿងនោះ ។

## [ ព្រះសាស្តាទ្រង់កាត់ក្តី ]

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ឧបាសកទាំងនោះហើយ មិនបានទ្រង់ធ្វើសីលតែមួយឲ្យថោកទាបឡើយ ត្រាស់ថា “ ម្នាលឧបាសកទាំងឡាយ សីលទាំងអស់

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ជារបស់រក្សាបានដោយកម្រទាំងអស់ ” ដូច្នេះហើយ ក៏ទ្រង់ភាសិតព្រះគាថាទាំងនោះថា :-

៧ យោ បាណមតិមាបេតិ   មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ   បរទារញ្ច គច្ឆតិ
សុរាមេរយបានញ្ច   យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ   បាបធម្មា អសញ្ញតា
មា តំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។

ជនណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឲ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណា ផឹកទឹកសុរា និងមេរ័យផង ជននោះឯង ឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួនក្នុងលោក នេះដោយពិត។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួម ដូច្នេះ លោភៈ និងសភាពមិនមែនធម៌ គឺទោស

*មលវគ្គវណ្ណនា រឿងឧបាសក ៥ នាក់*

ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា **យោ បាណមតិ-មាបេតិ** សេចក្តីថា បណ្តាប្រយោគទាំង ៦ មានសាហត្ថិក-

ប្បយោគជាដើម នរជនណាចូលទៅកាត់ផ្តាច់ឥន្ទ្រិយ គឺជីវិតរបស់អ្នកដទៃ សូម្បីដោយប្រយោគណាមួយ ។

បទថា **មុសាវាទំ** សេចក្តីថា ហើយរមែងពោលមុសា-វាទ ដែលធ្វើប្រយោជន៍របស់អ្នកដទៃឲ្យវិនាស ។

បាទព្រះគាថាថា **លោកេ អទិន្នំ អាទិយតិ** សេចក្តីថា រមែងកាន់យកទ្រព្យដែលអ្នកដទៃហួងហែង ដោយអវហារទាំងឡាយមានថេយ្យាវហារ ( ការនាំយកទៅដោយលួច ) ជាដើម អវហារសូម្បីតែមួយក្នុងសត្វលោកនេះ ។

បាទព្រះគាថាថា **បរទារញ្ច គច្ឆតិ** សេចក្តីថា នរជនកាលឈ្លានពានកណ្ឌៈទាំងឡាយ ដែលអ្នកដទៃរក្សា និងគ្រប់គ្រងនោះ ឈ្មោះថា ប្រព្រឹត្តខុសផ្លូវ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

បទថា **សុរាមេរយបានំ** បានដល់ ការផឹកសុរា និងមេរ័យយ៉ាងណាមួយនោះ ។ បទថា **អនុយុញ្ជតិ** គឺរមែងសេព បានដល់ រមែងធ្វើឲ្យច្រើន ។

ពីរបទថា **មូលំ ខណតិ** សេចក្ដីថា បរលោកចូរលើក ទុក ក៏ក្នុងលោកនេះ នរជនទុំះបញ្ចាំ ឬលក់ផ្ដាច់សូម្បីនូវទ្រព្យដែលជាដើមទុន មានស្រែ និងចម្ការជាដើម ដែលជាគ្រឿងញ៉ាំងខ្លួនឲ្យតាំងនៅក្នុងលោកនេះបាន យកទៅផឹកសុរាឈ្មោះថា គាស់រំលើងនូវឫសគល់របស់ខ្លួន គឺជាមនុស្សឥតទីពឹង ជាមនុស្សកំព្រាត្រាច់ទៅ ។

ព្រះសាស្ដា តែងតែត្រាស់ហៅបុគ្គលអ្នកធ្វើកម្ម គឺទ្រុស្តសីល ៥ ដោយព្រះតម្រាស់ថា **ឯវំ ភោ** ។

បទថា **បាបធម្មា** បានដល់ អ្នកមានធម៌ដ៏លាមក ។

បទថា **អសញ្ញតា** បានដល់ អ្នកវៀរចាកការសង្រួម មានការសង្រួមតាមទ្វារកាយជាដើម ។ បាលីថា **អចេតសា** ដូច្នេះក៏មាន ប្រែថា អ្នកមិនមានចិត្ត ។

ពីរបទថា **លោភោ អធម្មោ ច** បានដល់ លោភៈ និង

ទោសៈ ។ ពិតណាស់ កិលេសជាតិសូម្បីទាំងពីរនេះ ជាអកុសលដោយពិត ។

បាទព្រះគាថាថា **ចិរំ ទុក្ខាយ វន្ធយុំ** ធម៌ទាំងនេះ ចូរកុំសម្លាប់ ចូរកុំបៀតបៀន កុំញាំញី ( អ្នកទាំងឡាយ ) ដើម្បីឲ្យដល់នូវសេចក្ដីទុក្ខទាំងឡាយ មានទុក្ខក្នុងនរកជាដើមអស់កាលយូរឡើយ ។

ក្នុងកាលចប់ទេសនា ឧបាសកទាំង ៥ នាក់នោះបានសម្រេចសោតាបត្តិផល ព្រះធម្មទេសនាបានមានប្រយោជន៍សូម្បីដល់មហាជនដែលមកប្រជុំនៅទីនោះ ដូច្នេះឯង ៕៚

( រឿងឧបាសក ៥ រូប ចប់ )

## ៨ រឿងភិក្ខុកំលោះឈ្មោះតិស្សៈ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះ ឈ្មោះថា តិស្សៈ ត្រាស់ព្រះធម្មទេសនានេះថា " **ទទាតិ វេ យថាសទ្ធំ** " ជាដើម ។

### [ ព្រះតិស្សៈនិន្ទាជនដទៃ តែសរសើរញាតិរបស់ខ្លួន ]

បានឮថា ព្រះតិស្សៈនោះ តែងតែតិះដៀលទានរបស់ព្រះអរិយសាវកទាំង ៥ កោដិ គឺអនាថបិណ្ឌិកគហបតី នាងវិសាខាឧបាសិកា ( ជាដើម ) ។ សូម្បីតែអសទិសទានក៏តិះដៀលដែរ , បានវត្ថុត្រជាក់ក្នុងរោងទានរបស់អរិយសាវកទាំងនោះហើយ ក៏តិះដៀលថា " ត្រជាក់ " បានវត្ថុក្ដៅ ក៏តិះដៀលថា " ក្ដៅ " កាលគេឲ្យតិច ក៏តិះដៀលថា " ព្រោះហេតុអ្វី ទើបជនទាំងនោះ ឲ្យវត្ថុតែបន្តិចបន្តួចយ៉ាងនេះ "

កាលគេឲ្យច្រើន ក៏តិះដៀលថា “ ក្នុងផ្ទះរបស់ជនទាំងនេះ ប្រហែលជាមិនមានកន្លែងដាក់ទេដឹង , ធម្មតាបុគ្គលគួរឲ្យវត្ថុ

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ដែលល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដល់ភិក្ខុទាំងឡាយ មិនមែនឬ ។ យាគូ និងភត្តប្រមាណប៉ុណ្ណោះ រមែងវិនាសទៅឥតប្រយោជន៍ ” ប៉ុន្តែពោលប្រារព្ធពួកញាតិរបស់ខ្លួនជាដើមថា “ ឱ ! ផ្ទះនៃពួកញាតិរបស់យើង គួរឲ្យសរសើរពិតមែនជាកំពង់ ជាទីចុះផឹកនៃភិក្ខុទាំងឡាយ ដែលមកអំពីទិសទាំងបួន ” ដូច្នេះហើយ ក៏ញុំាងពាក្យសរសើរឲ្យប្រព្រឹត្តទៅ ។

## [ ពួកភិក្ខុសាកសួរឋានៈរបស់ព្រះតិស្សៈ ]

ក៏ព្រះតិស្សនោះ ជាបុត្ររបស់អ្នករក្សាទ្វារ ( ឆ្មាំទ្វារ ) ម្នាក់ ត្រាច់ទៅជាមួយពួកជាងឈើ អ្នកត្រាច់ទៅកាន់ជនបទទៅដល់ព្រះនគរសាវត្ថី ក៏បួសទៅ ។

គ្រានោះ ភិក្ខុទាំងឡាយឃើញលោកដែល ( ត្រាច់ ) តិះដៀលទានរបស់មនុស្សទាំងឡាយយ៉ាងនោះ គិតថា “ ពួក

យើងនឹងសាកសួរភិក្ខុនោះ” ទើបសួរថា “ អ្នកមានអាយុពួកញាតិរបស់លោកនៅទីណា ?” បានស្តាប់ថា “ នៅក្នុងស្រុកឯណោះ” ទើបបញ្ជូនភិក្ខុកំលោះពីរបីរូបទៅកាន់ស្រុកនោះ ។

ភិក្ខុកំលោះទាំងនោះទៅកាន់ស្រុកនោះ កាលអ្នកស្រុក



នោះនិមន្តឲ្យគង់ក្នុងរោងទានហើយធ្វើសក្ការៈ ក៏សាកសួរថា “ ក្មេងកំលោះឈ្មោះតិស្សៈ ចេញចាកស្រុកនេះ ទៅបួសហើយ មែនឬ ? ជនណាជាញាតិរបស់តិស្សៈនោះ ” ។ មនុស្សទាំងនោះ ( ម្នាក់ៗ ) ក៏គិតថា “ ក្នុងស្រុកនេះ ក្មេងដែលចេញចាកផ្ទះនៃត្រកូលហើយទៅបួស មិនមាន , ភិក្ខុទាំងនេះ និយាយអំពីអ្នកណាហ្ន៎ ?” ហើយក៏ប្រាប់ថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយបានឮថា បុត្ររបស់អ្នករក្សាទ្វារម្នាក់ ដែលត្រាច់ទៅជាមួយនឹងជាងឈើនោះ ឥឡូវនេះបួសហើយ , លោកម្ចាស់ទាំងឡាយប្រហែលជាពោលសំដៅយកអ្នកនោះទេដឹង ?” ។

## [ ចាប់ការនិយាយកុហកបាន ]

ភិក្ខុកំលោះទាំងនោះដឹងថា ពួកញាតិដ៏ធំជុំរបស់តិស្សៈ ភិក្ខុកំលោះនោះមិនមាននៅក្នុងស្រុកនោះហើយ ( ទើបនាំគ្នា ) ត្រឡប់ទៅកាន់ក្រុងសាវត្ថី ប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយ ថា " បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះតិស្សៈរមែងដើរនិយាយ ពាក្យដែលឥតហេតុផល " ។ ចំណែកភិក្ខុទាំងឡាយក៏ក្រាប



ទូល ( រឿងនោះ ) ចំពោះព្រះតថាគត ។

## [ បុព្វកម្មរបស់ព្រះតិស្សៈ ]

ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះ តិស្សៈនោះ ជាមនុស្សអួតអាងតែក្នុងជាតិនេះក៏ទេ, សូម្បីក្នុង កាលមុន ក៏ជាអ្នកអួតអាងដែរ " កាលភិក្ខុទាំងឡាយអារាធនា ព្រះសម្មាសម្ពុទ្ធទ្រង់នាំអតីតនិទានមកហើយ ទ្រង់ក៏ញ៉ាំង កដាហកជាតកឲ្យពិស្ដារថា :-

( ធីតានៃសេដ្ឋីពោលថា ) ទាសៈឈ្មោះកដាហកៈនោះ

ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម ( ម្តងទៀត ) គប្បីប្រទូស្តមិនខាន ម្នាលកដាហក: អ្នកចូរបរិភោគ នូវភោគ:ទាំងឡាយ ។

ដូច្នេះហើយ ត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាកាលជនដទៃឲ្យវត្ថុតិចក្តី ច្រើនក្តី សៅហ្មងក្តី ប្រណីតក្តី ឬឲ្យវត្ថុដល់ជនដទៃ ( ប៉ុន្តែ ) មិនឲ្យដល់ខ្លួន ជាអ្នកអៀនខ្មាស , ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនកើតឡើងដល់បុគ្គលនោះ ” ដូច្នេះហើយ កាលទ្រង់សម្តែង

*មលវគ្គវណ្ណនា រឿងភិក្ខុកំលោះឈ្មោះតិស្ស:*

ធម៌ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា :-

៨ ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។

ជនរមែងឲ្យតាមសទ្ធា តាមសេចក្ដីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាសក្នុងទឹក និងភោជនរបស់ជនទាំងឡាយដទៃ ជននោះ រមែងមិនបានសមាធិចិត្តក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។

លុះតែសេចក្ដីអៀនខ្មាសនោះ បុគ្គលណាបានផ្ដាច់ផ្ដិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្តក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **ទទាតិ វេ យថា-**

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

**សទ្ធំ** សេចក្ដីថា បុគ្គល កាលឲ្យវត្ថុទាំងឡាយ មានរបស់សៅហ្មង និងប្រណីតជាដើម យ៉ាងណាមួយ ឈ្មោះថា រមែងឲ្យតាមសទ្ធា គឺតាមសមគួរដល់សទ្ធារបស់ខ្លួននោះឯង ។

បទថា **យថាបសាទនំ** សេចក្ដីថា ក៏បណ្ដាភិក្ខុជាថេរៈ និងភិក្ខុថ្មីជាដើម សេចក្ដីជ្រះថ្លាក្នុងភិក្ខុណាៗ រមែងកើតឡើង ចំពោះបុគ្គលនោះ , កាលថ្វាយ ( ទាន ) ចំពោះភិក្ខុនោះ ឈ្មោះថា រមែងថ្វាយតាមសេចក្ដីជ្រះថ្លា គឺតាមសមគួរដល់ សេចក្ដីជ្រះថ្លារបស់ខ្លួននោះឯង ។

បទថា **តត្ថ** ជាដើម សេចក្ដីថា រមែងជាអ្នកមាន សេចក្ដីអៀនខ្មាសនឹងទានរបស់ជនដទៃនោះថា “ យើងបាន វត្ថុតិចតួច , យើងបានវត្ថុសៅហ្មង ” ។

បទថា **សមាធឹ** ជាដើម សេចក្ដីថា បុគ្គលនោះរមែង មិនបានសមាធិដោយអំណាចនៃឧបចារសមាធិ និងអប្បនា សមាធិ ឬក៏ដោយអំណាចនៃមគ្គ និងផល ក្នុងពេលថ្ងៃ ឬពេលយប់ ។

ពីរបទថា **យស្ស ចេតំ** សេចក្ដីថា អកុសលកម្មនោះ

ពោល គឺភាពជាអ្នកអៀនខ្មាសក្នុងឋានៈទាំងនេះ បុគ្គលណា កាត់ផ្តាច់ហើយ ដកឡើងហើយ ធ្វើឲ្យមានឫសគល់ដាច់ ហើយ ដោយអរហត្តមគ្គញ្ញាណ , បុគ្គលនោះ រមែងបាន សមាធិ មានប្រការដូចពោលហើយនោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងភិក្ខុកំលោះឈ្មោះតិស្សៈ ចប់ )

## ៩ រឿងឧបាសក ៥ នាក់

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ត្រាស់ព្រះធម្មទេសនានេះថា “ **នត្ថិ រាគសមោ អគ្គិ** ” មានបទដូច្នេះជាដើម ។

បានឮថា ឧបាសកទាំងនោះ ប្រាថ្នានឹងស្តាប់ព្រះធម៌ ទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះតម្រិះដូច្នេះថា “ បុគ្គលនេះជាក្សត្រិយ៍ បុគ្គលនេះជាព្រាហ្មណ៍ បុគ្គលនេះជាអ្នកស្តុកស្តម្ភ , បុគ្គលនេះជាស្មូមយាចក , តថាគតនឹងសម្តែងធម៌ឲ្យក្រៃលែងដល់បុគ្គលនេះ , នឹងមិនសម្តែងធម៌ឲ្យក្រៃលែងដល់បុគ្គលនេះ ” រមែងមិនកើតឡើងចំពោះព្រះសម្ពុទ្ធទាំងឡាយឡើយ ។

ព្រះសាស្តា កាលនឹងទ្រង់សម្តែងព្រះធម៌ប្រារព្ធបុគ្គលណាម្នាក់ ទ្រង់រមែងធ្វើសេចក្តីគោរពព្រះធម៌ទុកខាងដើមហើយ ទើបសម្តែង ដូចជាទេវតាអ្នកមានសក្តិ ញុំាងទឹកព្ធដ៏អាកាសឲ្យហូរចុះមកដូច្នោះ ។ បណ្តាឧបាសកទាំងនោះដែល

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

មកអង្គុយក្នុងសម្នាក់ព្រះតថាគត ដែលទ្រង់សម្តែងធម៌យ៉ាងនោះ ឧបាសកម្នាក់អង្គុយលក់ , ម្នាក់អង្គុយគូសវាសផែនដីដោយម្រាមដៃ , ម្នាក់អង្គុយអង្រួនដើមឈើ , ម្នាក់អង្គុយងើយមើលអាកាស , ប៉ុន្តែ ម្នាក់បានអង្គុយស្តាប់ធម៌ ដោយគោរព ។

ឯព្រះអានន្ទត្ថេរ ដែលកំពុងបក់ផ្លិតថ្វាយព្រះសាស្តានោះ ឃើញអាការរបស់ឧបាសកទាំងនោះហើយ ក្រាបទូលព្រះសាស្តាថា “ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់បន្លឺព្រះសូរសៀងដូចជាការរំពងនៃមហាមេឃ ទ្រង់សម្តែងធម៌

ដល់ឧបាសកទាំងនេះ , ប៉ុន្តែឧបាសកទាំងនោះ កាលព្រះអង្គកំពុងសម្តែងព្រះធម៌ , អង្គុយធ្វើកម្មនេះ និងនេះ ” ។

ព្រះសាស្តា. ម្នាលអានន្ទ អ្នកមិនស្គាល់ឧបាសកទាំងនោះទេឬ ?

អានន្ទ. បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនស្គាល់ទេ ។

## [ ប្រវត្តិរបស់ឧបាសកទាំង ៥ នាក់ ]

ព្រះសាស្តា. ក៏បណ្តាឧបាសកទាំងនោះ ឧបាសកម្នាក់

*មលវគ្គវណ្ណនា រឿងឧបាសក ៥ នាក់*

ដែលអង្គុយលក់នោះ កើតក្នុងកំណើតពស់អស់ ៥០០ ជាតិ ដាក់ក្បាលលើភ្នែនទាំងឡាយហើយលក់, សូម្បីក្នុងកាលនេះ ការផ្អែតក្នុងការលក់របស់គេរមែងមិនមាន , សំឡេងរបស់តថាគតរមែងមិនចូលទៅកាន់ត្រចៀករបស់គេទេ ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ដោយលំដាប់ជាប់តគ្នា ឬក៏ត្រាស់ជាចន្លោះៗ ?

ព្រះសាស្តា. ម្នាលអានន្ទ សូម្បីព្រះសព្វញ្ញុតញ្ញាណ ក៏ទ្រង់មិនអាចកំណត់ នូវការកើតឡើងរបស់ឧបាសកនោះ អ្នកកើតជាចន្លោះៗ យ៉ាងនេះ គឺភាពជាមនុស្សតាមកាល , ជាទេវតាតាមកាល , ជានាគតាមកាល , ប៉ុន្តែឧបាសកនោះ កើតក្នុងកំណើតនាគអស់ ៥០០ ជាតិដោយលំដាប់ សូម្បី លក់ក្នុងកំណើតនាគអស់ ៥០០ ជាតិហើយ ( ក៏ ) នៅតែ មិនឆ្អែតក្នុងការលក់ទៀត ។

ចំណែកបុរសអ្នកអង្គុយគូសវាសផែនដី ដោយម្រាម ដៃនោះ កើតក្នុងកំណើតសត្វជន្លេនអស់ ៥០០ ជាតិដោយ លំដាប់ , ធ្លាប់ជីកផែនដីអស់កាលយូរមកហើយ , ដល់មក



ឥឡូវនេះ ក៏នៅតែគូសវាសផែនដីទៀត ដោយអំណាចនៃ វាសនា ដែលខ្លួនបានសន្សំហើយ ដោយច្រើនក្នុងកាលមុន រមែងមិនឮសំឡេងរបស់តថាគតឡើយ ។

ចំណែកបុរសដែលអង្គុយអង្រួនដើមឈើនោះ កើតក្នុងកំណើតស្វាអស់ ៥០០ ជាតិដោយលំដាប់ , ដល់ឥឡូវនេះក៏អង្រួនដើមឈើ ដោយអំណាចនៃវាសនាដែលខ្លួនបានសន្សំមកហើយដោយច្រើនក្នុងកាលពីមុន ។ សំឡេងរបស់តថាគតមិនចូលត្រចៀករបស់គេឡើយ ។

ចំណែកព្រាហ្មណ៍ ដែលអង្គុយងើយមើលអាកាសនោះ ធ្លាប់កើតជាអ្នកទាយនក្ខត្តឫក្សអស់ ៥០០ ជាតិដោយលំដាប់ , ដល់ឥឡូវនេះ សូម្បីក្នុងថ្ងៃនេះក៏នៅតែងើយមើលអាកាស ដោយអំណាចនៃវាសនាដែលខ្លួនសន្សំមកហើយដោយច្រើនក្នុងជាតិមុន , សំឡេងរបស់តថាគត ក៏មិនចូលត្រចៀករបស់គេទេ ។

ចំណែកព្រាហ្មណ៍ ដែលអង្គុយស្តាប់ដោយគោរពនោះ ធ្លាប់កើតជាព្រាហ្មណ៍អ្នករៀនមន្ត ដល់ត្រើយនៃវេទ ៣ អស់

៥០០ ជាតិដោយលំដាប់ , ដល់ឥឡូវនេះ ក៏នៅតែស្តាប់ដោយគោរព ហាក់ដូចជាការប្រៀបធៀបនូវមន្ត ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ព្រះធម្មទេសនារបស់ព្រះអង្គ រមែងកាត់នូវសរីរាវយវៈទាំងមានសម្បុរស្បែកជាដើម (ចូល) ទៅតាំងនៅទល់ខួរក្នុងឆ្អឹង, ព្រោះហេតុអ្វី កាលព្រះអង្គទ្រង់សម្តែងធម៌ ទើបមិនស្តាប់ដោយគោរព ?

ព្រះសាស្តា. ម្នាលអានន្ទ អ្នកប្រហែលជាសម្គាល់ថា "ធម៌របស់តថាគតបុគ្គលគប្បីស្តាប់បានដោយងាយទេដឹង"។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ព្រះអង្គបុគ្គលគប្បីស្តាប់បានដោយលំបាកឬ ?

ព្រះសាស្តា. ត្រឹមត្រូវហើយ អានន្ទ ។

អានន្ទ. ព្រោះហេតុអ្វី ព្រះអង្គ ?

ព្រះសាស្តា. ម្នាលអានន្ទ បទថា ពុទ្ធោត្តិ ធម្មោត្តិ សង្ឃោត្តិ ដែលសត្វទាំងនេះមិនធ្លាប់បានស្តាប់ក្នុងសែនកប្ប

ជាអនេក, ព្រោះហេតុដូច្នោះ ទើបសត្វទាំងនេះមិនអាចស្ដាប់ធម៌នេះបាន ប៉ុន្តែសង្សារវដ្តមានទីបំផុតដែលនរណាៗ តាម

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ដឹងមិនបាននោះ សត្វទាំងនេះស្ដាប់តិរច្ឆានកថា មានប្រការផ្សេងៗ មកហើយ , ព្រោះហេតុដូច្នោះ ទើបសត្វទាំងនេះ ប្រៀនរាំ ត្រាច់ទៅកាន់ទីទាំងឡាយ មានរោងសុរា និងមណ្ឌលនៃកីឡាជាដើម , ទើបមិនអាចស្ដាប់ធម៌បាន ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកទាំងនោះអាស្រ័យអ្វី ទើបមិនអាចស្ដាប់ធម៌បាន ?

គ្រានោះ ព្រះសាស្ដា បានត្រាស់ទៅកាន់ព្រះអានន្ទថា " ម្នាលអានន្ទ ឧបាសកទាំងនោះ អាស្រ័យរាគៈ អាស្រ័យទោសៈ អាស្រ័យមោហៈ ទើបមិនអាចស្ដាប់ធម៌បាន , ដែលឈ្មោះថា ភ្លើង ដូចជាភ្លើង គឺរាគៈមិនមាន , ភ្លើងឯណាមិនសម្ដែងនូវផេះ រមែងឆេះសត្វទាំងឡាយ ប្រាកដស្មើដោយរាគៈ រមែងមិនមាន, ពិតណាស់ សូម្បីភ្លើងដែលញ៉ាំងកប្ប

ឲ្យវិនាស ដែលអាស្រ័យការប្រាកដឡើងនៃព្រះអាទិត្យ ៧ ដួង រមែងញ៉ាំងលោកឲ្យឆេះ មិនឲ្យវត្ថុណាៗ នៅសល់ឡើយ ក៏ពិតមែនហើយ , ក៏ប៉ុន្តែភ្លើងនោះ រមែងឆេះតែក្នុងគ្រាខ្លះប៉ុណ្ណោះ , ឈ្មោះថា កាលនៃភ្លើង គឺរាគៈ មិនឆេះ រមែងមិន



មាន ព្រោះហេតុដូច្នោះ ឈ្មោះថាភ្លើងប្រាកដស្មើដោយរាគៈក្តី ឈ្មោះថា អ្នកចាប់ប្រាកដស្មើដោយទោសៈក្តី ឈ្មោះថា សំណាញ់ប្រាកដស្មើដោយមោហៈក្តី ឈ្មោះថា ស្ទឹងប្រាកដស្មើ ដោយតណ្ហាក្តី រមែងមិនមាន" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :-

**៩ នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្តាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **រាគសមោ** សេចក្ដីថា ឈ្មោះថា ភ្លើង ស្មើដោយរាគៈ រមែងមិនមាន ដោយអំណាចនៃការផ្ដួចឆេះឡើងតែខាងក្នុង មិនសម្ដែងអាការទាំងឡាយមានផ្សែងជាដើមនោះឯង ។ បទថា **ទោសសមោ** សេចក្ដីថា អ្នកចាប់ទាំងឡាយ មានអ្នកចាប់ គឺយក្ខ អ្នកចាប់ គឺ



ពស់ថ្លាន់ និងអ្នកចាប់ គឺក្រពើជាដើម រមែងអាចចាប់បានតែក្នុងអត្តភាពមួយប៉ុណ្ណោះ, ប៉ុន្តែ អ្នកចាប់ គឺទោសៈ រមែងចាប់គ្រប់ៗ ជាតិ ព្រោះហេតុដូច្នោះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អ្នកចាប់ស្មើដោយទោសៈ មិនមាន ។

ពីរបទថា **មោហសមំ ជាលំ** សេចក្ដីថា ឈ្មោះថា សំណាញ់ ស្មើដោយមោហៈ រមែងមិនមាន ដោយអត្ថថា រួបរឹត និងរួបរឹតដោយជុំវិញ ។

បទថា **តណ្ហាសមា** សេចក្តីថា វេលាពេញក្តី វេលាខ្វះក្តី វេលារីងស្ងួតក្តី នៃស្ទឹងទាំងឡាយ មានស្ទឹងគង្គាជាដើម រមែងប្រាកដ , ចំណែកវេលាពេញ ឬវេលារីងស្ងួតនៃតណ្ហា រមែងមិនមាន , ការខ្វះខាតតែម្យ៉ាងប៉ុណ្ណោះ រមែងប្រាកដជានិច្ច ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ស្ទឹងស្មើដោយតណ្ហា រមែងមិនមាន ព្រោះអត្ថថា ឲ្យពេញបានដោយកម្រ ឲ្យពេញបានដោយលំបាក ។

ក្នុងកាលចប់ទេសនា ឧបាសកអ្នកស្តាប់ធម៌ដោយគោរពនោះ បានសម្រេចសោតាបត្តិផល ព្រះធម្មទេសនា

*មលវគ្គវណ្ណនា រឿងឧបាសក ៥ នាក់*

បានមានប្រយោជន៍ សូម្បីដល់មហាជនដែលប្រជុំគ្នានៅទីនោះ ដូច្នេះឯង ៕

**( រឿងឧបាសក ៥ នាក់ ចប់ )**

88888888888888888888888888888

# ១០ រឿងមេណ្ឌកសេដ្ឋី

## សេចក្តីខាងដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យភទ្ទិយនគរ ទ្រង់គង់នៅក្នុងព្រៃជាតិយៈ ទ្រង់ប្រារព្ធមេណ្ឌកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា " **សុទស្សំ វជ្ជមញ្ញេសំ** " ជាដើម ។

## [ ព្រះសាស្តាស្តេចទៅកាន់ភទ្ទិយនគរ ]

បានឮថា ព្រះសាស្តាកាលស្តេចត្រាច់ទៅកាន់ទីចារិកក្នុងអង្គុត្តរាបថជនបទទាំងឡាយ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់មនុស្សទាំងនេះ គឺមេណ្ឌកសេដ្ឋី ១ , ភរិយារបស់សេដ្ឋីនោះ ឈ្មោះនាងចន្ទបទុមា ១ , បុត្រឈ្មោះធនញ្ជយសេដ្ឋី ១ , កូនប្រសាស្រីឈ្មោះសុមនាទេវី ១ , ចៅស្រីឈ្មោះវិសាខា ១ , ទាសឈ្មោះបុណ្ណៈ ១ , ទើបស្តេចទៅកាន់ភទ្ទិយនគរ ទ្រង់គង់នៅក្នុងព្រៃជាតិយៈ ។ មេណ្ឌកសេដ្ឋីបានដឹងថា ព្រះសាស្តាស្តេចមកកាន់ភទ្ទិយនគរ ។

## [ ហេតុដែលបាននាមថាមេណ្ឌកសេដ្ឋី ]

សួរថា " ព្រោះហេតុអ្វី ទើបសេដ្ឋីនោះ មានឈ្មោះថា

មេណ្ឌកសេដ្ឋី ?” ឆ្លើយថា បានឮថា ពពែមាសទាំងឡាយ ប្រមាណប៉ុនដំរី សេះ និងគោឧសភៈ ទម្លាយផែនដីយកខ្នង ទល់ខ្នងផុសឡើងប្រមាណ ៨ ករីសនៅខាងក្រោយផ្ទះរបស់ សេដ្ឋីនោះ ។ បុញ្ញកម្មបានដាក់ដុំអំបោះ ៥ ពណ៌ក្នុងមាត់ របស់ពពែទាំងនោះ ។ កាលត្រូវការកេសជ្ជមានទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ឬត្រូវការវត្ថុទាំងឡាយ មានសំពត់ និងគ្រឿងបិទបាំង មាស និងប្រាក់ជាដើម ជន ទាំងឡាយ រមែងនាំដុំអំបោះចេញអំពីមាត់ពពែទាំងនោះ ។ ទឹកដោះថ្លា ប្រេង ទឹកឃ្មុំ ទឹកអំពៅ សំពត់ និងគ្រឿងបិទ បាំង មាស និងប្រាក់ រមែងហូរចេញអំពីមាត់ពពែតែមួយ ក៏គ្រប់គ្រាន់ដល់មនុស្សជម្ពូទ្វីប ។ ចាប់តាំងពីពេលនោះមក សេដ្ឋីនោះ ក៏មានឈ្មោះថា មេណ្ឌកសេដ្ឋី ។

## [ បុព្វកម្មរបស់សេដ្ឋី ]

សួរថា ក៏បុព្វកម្មរបស់សេដ្ឋីនោះជាយ៉ាងណា ? ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមវិបស្សី សេដ្ឋីនោះជាក្មួយនៃកុដុម្ពិកឈ្មោះអវរោជៈ មានឈ្មោះថា អវរោជៈ



មានឈ្មោះដូចឪពុកធំ ។ គ្រានោះ ឪពុករបស់គេ ផ្ដើមកសាងព្រះគន្ធកុដិដើម្បីថ្វាយព្រះសាស្ដា ។ គេទៅកាន់សម្នាក់របស់ឪពុកធំហើយ ពោលថា “ អ៊ំ យើងទាំងពីរនាក់នឹងកសាងរួមគ្នាទៅ ” ក្នុងវេលាដែលឪពុកធំនោះឃាត់ថា “ យើងតែម្នាក់ឯងប៉ុណ្ណោះនឹងកសាង មិនឲ្យសាធារណៈ ដល់ជនដទៃទេ ” ទើបគិតថា “ កាលអ៊ំរបស់យើងកសាងព្រះគន្ធកុដិនៅទីនេះហើយ, យើងគួរបានសាលារាយក្នុងទីនេះ ” លុះគិតដូច្នោះហើយ ក៏ប្រើមនុស្សឲ្យទៅនាំឈើអំពីព្រៃមក ហើយឲ្យជាងធ្វើសសរទាំងឡាយយ៉ាងនេះ គឺ “ សសរមួយដើមរំលេចដោយមាស , មួយដើមរំលេចដោយប្រាក់ , មួយដើមរំលេចដោយកែវមណី ” ឲ្យគេធ្វើធ្នឹម សន្ទឹកទ្វារ និងបង្អួច ជើងគក

( ផន្ទុល់របៀង ) និងក្បឿងទាំងឡាយគ្រប់ទាំងអស់ សុទ្ធតែរំលេចដោយរតនៈ មានមាសជាដើម ឲ្យកសាងសាលារាយដោយរតនៈ ៧ ប្រការ ថ្វាយចំពោះព្រះសាស្ដា ខាងមុខព្រះគន្ធកុដិ ខាងលើសាលារាយនោះ មានកំពូល ៣ ដែលសម្រេចដោយមាសតាន់ មានពណ៌ក្រហមឆ្អិន និងកែវផ្ទេក



និងកែវប្រពាឡ, ឲ្យគេសាងមណ្ឌបប្រដាប់ដោយកែវ ត្រង់កណ្ដាលសាលារាយនោះ, ឲ្យគេធ្វើធម្មាសនៈនៅក្នុងមណ្ឌបនោះ ។ ជើងធម្មាសនៈនោះសម្រេចអំពីមាសតាន់ មានពណ៌ក្រហមឆ្អិន , មេគ្រែទាំង ៤ ក៏ដូចគ្នា , ឲ្យគេធ្វើពពែមាស ២ តាំងទុកខាងក្រោមតាំងសម្រាប់រងជើង , ឲ្យគេធ្វើពពែមាស ៦ ហ៊ុមព័ទ្ធជុំវិញមណ្ឌបនោះ , ឲ្យគេប៉ាក់ធម្មាសនៈដោយខ្សែទាំងឡាយ ដែលសម្រេចដោយដុំសូត្រ ហើយទើបឲ្យគេប៉ាក់ដោយខ្សែ ដែលសម្រេចដោយមាស ត្រង់កណ្ដាល ហើយឲ្យគេប៉ាក់ដោយខ្សែ ដែលសម្រេចដោយកែវមុក្ដាខាង

លើ , ភ្នាក់ដៃនៃធម្មាសនៈនោះធ្វើអំពីឈើខ្លឹមចន្ទន៍ ។ លុះធ្វើសាលាពាយនោះសម្រេចយ៉ាងនេះហើយ កាលនឹងធ្វើបុណ្យឆ្លងសាលានោះ ក៏និមន្តព្រះសាស្តា ព្រមទាំងភិក្ខុប្រមាណ ៦ លាន ៨ សែន បានថ្វាយទានរហូត ៤ ខែ , ក្នុងថ្ងៃចុងក្រោយបានថ្វាយត្រៃចីវរ ។ បណ្តាភិក្ខុទាំងនោះ ចីវរមានតម្លៃមួយពាន់ ដល់ភិក្ខុអ្នកបួសថ្មីក្នុងសង្ឃ ។

អវភោជៈនោះ ធ្វើបុញ្ញកម្មក្នុងកាលនៃព្រះពុទ្ធវិបស្សី

*មលវគ្គវណ្ណនា រឿងមេណ្ឌកសេដ្ឋី*

យ៉ាងនេះហើយ ចុតិចាកអត្តភាពនោះហើយ អន្ទោលទៅក្នុងទេវលោក និងមនុស្សទាំងឡាយ ក្នុងកទ្ទកប្បនេះ កើតក្នុងត្រកូលសេដ្ឋី ដែលមានភោគសម្បត្តិច្រើន នៅក្នុងក្រុងពារាណសី មាននាមថា ពារាណសីសេដ្ឋី ។

## [ សេដ្ឋីជួបគ្រោះរាំងស្ងួត ]

ថ្ងៃមួយ សេដ្ឋីនោះទៅកាន់ទីជាទីបម្រើព្រះរាជា ជួបបុរោហិត ក៏សួរថា " បពិត្រលោកអាចារ្យ លោកពិនិត្យមើលយាមនៃនក្ខត្តឫក្សហើយឬ ? " ។

បុរោហិត. អើសេដ្ឋី ខ្ញុំពិនិត្យមើលហើយ, យើងទាំងឡាយ នឹងមានកិច្ចការអ្វីដទៃ ?

សេដ្ឋី. បើដូច្នោះ ការប្រព្រឹត្តទៅនៃជនបទដូចម្តេច ?

បុរោហិត. ភ័យម្យ៉ាង នឹងមាន ។

សេដ្ឋី. ភ័យនោះ ឈ្មោះអ្វី ?

បុរោហិត. ម្នាលសេដ្ឋី ភ័យ គឺការអត់ឃ្លាន ។

សេដ្ឋី. នឹងមានក្នុងកាលណា ?

បុរោហិត. នៅបីឆ្នាំទៀត ។

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

សេដ្ឋីស្តាប់ឮពាក្យនោះហើយ ឲ្យកម្មករធ្វើកសិកម្មជាច្រើន មិនត្រឹមតែប៉ុណ្ណោះ បានឲ្យទទួលទិញស្រូវតែម្យ៉ាងដោយទ្រព្យដែលមាននៅក្នុងផ្ទះ ឲ្យគេធ្វើជង្រុក ១,២៥០

ជង្រុក ញុំាងជង្រុកទាំងអស់នោះឲ្យពេញដោយស្រូវ , កាល ជង្រុកទាំងអស់នោះពេញអស់ហើយ ក៏ញុំាងភាជនៈ មាន ពាងជាដើមឲ្យពេញ ហើយជីករណ្ដៅកប់ស្រូវដែលនៅសល់ នោះក្រោមដី ។ ប្រើកម្មករឲ្យប្រាប់ស្រូវដែលនៅសល់អំពី ការកប់នោះជាមួយនឹងដីស្អិត ហើយបូកនឹងជញ្ជាំង ។

ក្រោយមក កាលភ័យគឺសេចក្ដីអត់ឃ្លានចូលមកដល់ សេដ្ឋីនោះក៏បរិភោគស្រូវតាមដែលខ្លួនកប់ទុក , កាលស្រូវ ដែលកប់ទុកក្នុងជង្រុក និងក្នុងពាងជាដើមអស់ហើយ , ក៏ឲ្យ ហៅជនជាបរិវារមកហើយ ពោលថា “ នែ អ្នកទាំងឡាយ អ្នកទាំងឡាយចូរទៅ ចូរចូលទៅកាន់ភ្នំហើយរស់នៅទីនោះ ចុះ បើប្រាថ្នានឹងមកកាន់សម្នាក់របស់យើង ក៏ចូរមកក្នុង កាលដែលមានកិច្ចការកបានដោយងាយចុះ, ប្រសិនបើមិនចង់ មក , ក៏ចូររស់នៅទីនោះចុះ ” ។ ជនទាំងនោះក៏បានធ្វើតាម

ពាក្យរបស់សេដ្ឋីនោះ ។ ចំណែកទាសៈម្នាក់ឈ្មោះថា បុណ្ណៈ ក្រាញនៅក្នុងសម្នាក់របស់សេដ្ឋីនោះ ។ រួមជាមនុស្ស ៥ នាក់ ប៉ុណ្ណោះ គឺសេដ្ឋី ភរិយារបស់សេដ្ឋី បុត្ររបស់សេដ្ឋី កូនប្រសារបស់សេដ្ឋី និងនាយបុណ្ណៈនោះ ។

ជនទាំងនោះ កាលស្រូវដែលកប់ទុកក្នុងរណ្តៅក្រោមផែនដីអស់ហើយ , បំបែកជីស្អិតឮដ៏ជញ្ជាំង ( បាយអជញ្ជាំង ) យកមកត្រាំទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយស្រូវដែលបានមកអំពីជីស្អិតនោះ ។

គ្រានោះ ភរិយារបស់សេដ្ឋីនោះ កាលសេចក្តីស្រេកឃ្លានគ្របសង្កត់ កាលជីស្អិតអស់ទៅ ញុំាងជីស្អិតដ៏សេសសល់ឮដ៏ជញ្ជាំងទាំងឡាយឲ្យធ្លាក់ចុះមកហើយ យកទៅត្រាំទឹក បានស្រូវប្រមាណពីរនាឡិ បុកហើយ បានអង្ករប្រមាណមួយនាឡិ ដាក់ចូលទៅក្នុងក្អមមួយបិទហើយកប់ទុកក្នុងផែនដី ដោយខ្វាចថា “ ក្នុងវេលាកើតឆាតកភ័យយ៉ាងនេះ មាន

ចោរច្រើន ” ។ លំដាប់នោះ សេដ្ឋីត្រឡប់មកអំពីទីបម្រើព្រះរាជា ហើយពោលទៅកាន់កិរិយាថា “ម្នាលនាងដ៏ចម្រើន



ខ្ញុំឃ្លានណាស់ , អ្វីៗ មានទេ ? ពេលនោះកិរិយារបស់គាត់មិនបានពោលដល់វត្ថុដែលមានថា “ មិនមានទេ ” ពោលថា “ បពិត្រនាយ អង្ករមានមួយនាឡិ ” ។

សេដ្ឋី. អង្ករមួយនាឡិនោះ នៅឯណា ?

កិរិយា. ខ្ញុំកប់ទុកក្រោមដី ព្រោះខ្លាចចោរ ។

សេដ្ឋី. បើដូច្នោះ ចូរគាស់វាឡើងមក ហើយចំអិនបបរចុះ ។

កិរិយា. ប្រសិនបើយើងនឹងដាំបបរ អាចបានពីរដង, ប៉ុន្តែបើយើងដាំបាយ បានតែម្តងប៉ុណ្ណោះ, បពិត្រនាយ ឲ្យខ្ញុំចំអិនអ្វី បាយ ឬក៏បបរ ?

បច្ច័យដទៃរបស់ពួកយើង មិនមាន, ពួកយើងបរិភោគបាយប៉ុណ្ណឹងហើយក៏នឹងស្លាប់, នាងចូរចំអិនបាយតែម្តងចុះ ។

កិរិយារបស់សេដ្ឋីនោះ ចំអិនបាយហើយ បែងជា ៥ ចំណែក ដោះបាយមួយចំណែកតម្កល់ទុកខាងមុខសេដ្ឋី ។

## [ សេដ្ឋីថ្វាយភត្តចំពោះព្រះបច្ចេកពុទ្ធ ]

ខណៈនោះ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ នៅឯភ្នំគន្ធ-



មាទន៍ ចេញចាកសមាបត្តិ ។ បានឮថា ខាងក្នុងសមាបត្តិនោះ សេចក្តីស្រេកឃ្លានរមែងមិនអាចបៀតបៀន ព្រោះផលនៃសមាបត្តិ , ប៉ុន្តែថា កាលព្រះបច្ចេកពុទ្ធទាំងឡាយចេញចាកសមាបត្តិហើយ សេចក្តីស្រេកឃ្លានដ៏មានកម្លាំងរមែងកើតឡើងដុតសាច់ក្រពះ , ព្រោះហេតុដូច្នោះ ព្រះ-បច្ចេកពុទ្ធទាំងនោះ ពិចារណាមើលនូវទីជាទីបាន ( អាហារ ) ហើយ ទើបទៅ ។

ក៏ក្នុងថ្ងៃនោះ ជនទាំងឡាយ ថ្វាយទានចំពោះព្រះ-បច្ចេកពុទ្ធទាំងនោះហើយ រមែងបានសម្បត្តិ បណ្តាសម្បត្តិមានតំណែងជាសេនាបតីជាដើមយ៉ាងណាមួយ , ព្រោះហេតុ

នោះ ព្រះបច្ចេកពុទ្ធសូម្បីនោះ ពិចារណាមើលដោយទិព្វចក្ខុថា ធាតុកក្ខ័យកើតឡើងហើយក្នុងជម្ពូទ្វីបទាំងមូល , ហើយក្នុងផ្ទះសេដ្ឋីគេចំអិនបាយដោយអង្ករមួយនាឡិ ដើម្បីមនុស្ស ៥ នាក់ , ជនទាំងនោះមានសទ្ធា ឬអាចនឹងធ្វើការសង្គ្រោះយើងដែរឬហ្ន៎ ” ដឹងថា ជនទាំងនោះជាអ្នកមានសទ្ធា ទាំងអាចធ្វើការសង្គ្រោះទៀតផង ទើបកាន់យកបាត្រ និងចីវរ



និមន្តទៅសម្តែងខ្លួននៅក្បែរទ្វារផ្ទះខាងមុខសេដ្ឋី ។

សេដ្ឋីនោះ ឃើញព្រះបច្ចេកពុទ្ធក៏មានចិត្តជ្រះថ្លា គិតថា “ យើងជួបប្រសព្វធាតុកក្ខ័យបែបនេះ ព្រោះយើងមិនបានឲ្យទានក្នុងកាលមុន ។ ក៏ភត្តនេះគប្បីរក្សាយើងបានមួយថ្ងៃប៉ុណ្ណោះ , ចំណែកភត្តដែលយើងថ្វាយចំពោះព្រះបច្ចេក-ពុទ្ធ នឹងនាំមកនូវប្រយោជន៍ដល់យើងច្រើនកោដិកប្ប ” លុះគិតដូច្នោះហើយ ក៏នាំថាសភត្តនោះចេញមក ចូលទៅរកព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយ និមន្តឲ្យ

ចូលកាន់ផ្ទះ កាលព្រះបច្ចេកពុទ្ធគង់លើអាសនៈហើយ ក៏លាងព្រះបាទរបស់ព្រះបច្ចេកពុទ្ធ ដាក់ (ថាសភត្ត) លើតាំងមាស ហើយយកថាសភត្តនោះមកដាក់បាត្ររបស់ព្រះបច្ចេកពុទ្ធ ។ កាលភត្តនៅសល់ពាក់កណ្ដាល ព្រះបច្ចេកពុទ្ធក៏យកព្រះហស្ដបិទបាត្រ ។

គ្រានោះសេដ្ឋីពោលនឹងព្រះបច្ចេកពុទ្ធនោះថា “បពិត្រលោកម្ចាស់ដ៏ចំរើន នេះជាចំណែកមួយនៃភត្តដែលគេចំអិនដើម្បីមនុស្ស ៥ នាក់ ដោយអង្ករមួយនាឡិ , ខ្ញុំព្រះករុណា



មិនអាចនឹងបែងភត្តនេះឲ្យជាពីរចំណែកបានទេ , សូមលោកម្ចាស់កុំធ្វើការសង្គ្រោះខ្ញុំព្រះករុណាក្នុងលោកនេះអី , ខ្ញុំព្រះ-ករុណា ប្រាថ្នានឹងប្រគេនមិនឲ្យមានចំណែកសេសសល់ ” ហើយបានប្រគេនភត្តទាំងអស់, លុះប្រគេនភត្តរួចរាល់ហើយបានតាំងសេចក្ដីប្រាថ្នាថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមកុំឲ្យខ្ញុំព្រះករុណាជួបប្រសព្វឆាតកភ័យបែបនេះ ក្នុងទីដែល

ខ្ញុំព្រះករុណាកើតទៀតឡើយ , ចាប់ពីពេលនេះទៅ សូមឲ្យខ្ញុំព្រះករុណាអាចឲ្យកត្ត ដែលជាពូជដល់អ្នកជម្ពូទ្វីបទាំងមូល , មិនបាច់ធ្វើការងារចិញ្ចឹមជីវិតដោយដៃរបស់ខ្លួនឯង , ក្នុងខណៈដែលខ្ញុំព្រះករុណា ប្រើឲ្យមនុស្សសំអាតជង្រុក ១,២៥០ ជង្រុក ហើយកក់ក្បាល អង្គុយក្បែរទ្វារជង្រុកទាំងនោះងើយមើលទៅខាងលើប៉ុណ្ណោះ ធារនៃស្រូវសាលីក្រហមគប្បីធ្លាក់ចុះមក ញ៉ាំងជង្រុកទាំងអស់ឲ្យពេញ ដើម្បីខ្ញុំព្រះ-ករុណា , មួយវិញទៀត ភរិយារបស់ខ្ញុំព្រះករុណានេះ សូមជាភរិយារបស់ខ្ញុំព្រះករុណា បុត្រនេះសូមជាបុត្រ , កូនប្រសានេះសូមជាកូនប្រសា , ទាសៈនេះសូមជាទាសៈរបស់

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ខ្ញុំព្រះករុណាក្នុងទីដែលខ្ញុំព្រះករុណាកើតហើយទៀតចុះៗ ”។

## [ ទាំង ៥ នាក់ប្រាថ្នាឲ្យបានទៅរួមគ្នា ]

ចំណែកភរិយារបស់សេដ្ឋីនោះ ក៏គិតថា “ កាលស្វាមីរបស់យើងត្រូវសេចក្តីស្រេកឃ្លានបៀតបៀន យើងក៏មិនអាច

បរិភោគបាន " ទើបថ្វាយភត្តដែលជាចំណែករបស់ខ្លួនចំពោះព្រះបច្ចេកពុទ្ធហើយប្រាថ្នាថា " បពិត្រលោកម្ចាស់ដ៏ចម្រើន ចាប់ពីពេលនេះទៅ សូមកុំឲ្យខ្ញុំព្រះករុណាជួបប្រសព្វនូវឆាតកភ័យបែបនេះ ក្នុងទីដែលខ្ញុំព្រះករុណាកើតហើយ, មួយវិញទៀត កាលខ្ញុំព្រះករុណា ដាក់ថាសភត្តទុកខាងមុខ ហើយឲ្យនូវភត្តដល់អ្នកជម្ពូទ្វីបទាំងអស់ , បើខ្ញុំព្រះករុណាមិនទាន់ក្រោកឡើងដរាបណា , ទីនៃភត្តដែលខ្ញុំព្រះករុណាកាន់យកហើយៗ សូមជារបស់បរិបូណ៌ដូចដើមដរាបនោះចុះ, អ្នកនេះសូមជាស្វាមី, អ្នកនេះសូមជាបុត្រ, អ្នកនេះសូមជាកូនប្រសា, អ្នកនេះសូមជាទាសៈ ( របស់ខ្ញុំព្រះករុណា )", សូម្បីបុត្ររបស់សេដ្ឋីនោះ ក៏ថ្វាយចំណែករបស់ខ្លួនចំពោះព្រះបច្ចេក-ពុទ្ធ ហើយប្រាថ្នាថា " ចាប់ពីពេលនេះទៅ សូមកុំឲ្យខ្ញុំព្រះ



ករុណាជួបប្រសព្វនូវឆាតកភ័យ បែបនេះទៀតឡើយ , មួយវិញទៀត កាលខ្ញុំព្រះករុណា កាន់ថង់ចំណុះទ្រព្យមួយពាន់

កហាបណៈ សូម្បីឲ្យកហាបណៈដល់អ្នកជម្ពូទ្វីបទាំងមូល ជង់នេះ សូមពេញដូចដើម, លោកទាំងពីរនេះ សូមជាមាតាបិតា , ស្ត្រីនេះ សូមជាភរិយា , អ្នកនេះចូរជាទាសៈរបស់ខ្ញុំព្រះករុណា ” ។ សូម្បីកូនប្រសារបស់សេដ្ឋីនោះ ក៏ថ្វាយចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយប្រាថ្នាថា “ ចាប់ពីពេលនេះទៅ សូមកុំឲ្យខ្ញុំព្រះករុណា បានជួបប្រសព្វនូវធាតកកភ័យបែបនេះទៀត ម្យ៉ាងទៀត កាលខ្ញុំព្រះករុណាដាក់កញ្ជើស្រូវមួយខាងមុខ សូម្បីឲ្យនូវភត្តដែលជាពូជដល់អ្នកជម្ពូទ្វីបទាំងមូល ការអស់ទៅនៃភត្តដែលជាពូជនោះ កុំប្រាកដឡើយ, ម្តាយក្មេក និងឪពុកក្មេកនេះ សូមជាម្តាយក្មេកឪពុកក្មេក , ស្វាមីនេះសូមជាស្វាមី , ទាសៈនេះចូរជាទាសៈរបស់ខ្ញុំព្រះករុណាទៀតចុះ ” ។ សូម្បីទាសៈរបស់សេដ្ឋីនោះ ក៏ថ្វាយចំណែករបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយប្រាថ្នាថា “ ចាប់ពីពេលនេះទៅ សូមកុំឲ្យខ្ញុំព្រះករុណា បានជួបប្រសព្វនូវ

ធាតកកភ័យបែបនេះទៀត , មនុស្សទាំងអស់នេះ សូមជាចៅហ្វាយនាយរបស់ខ្ញុំព្រះករុណា ក្នុងទីដែលខ្ញុំព្រះករុណាកើតហើយទៀតចុះ, ហើយកាលខ្ញុំព្រះករុណាក្ខួរស្រែ, អាចម៍បំណះ ៧ បំណះ ប្រមាណប៉ុនទូកកម្រោល គឺខាងនេះ ៣ បំណះ ខាងនោះ ៣ បំណះ ត្រង់កណ្តាលមួយបំណះ , សូមប្រព្រឹត្តទៅ " ។ នាយបុណ្ណៈនោះ ប្រាថ្នាជាសេនាបតីក៏អាចនឹងបានក្នុងថ្ងៃនោះ ។ ប៉ុន្តែដោយអំណាចនៃសេចក្តីស្រឡាញ់ចំពោះចៅហ្វាយនាយ គេក៏ប្រាថ្នាថា " មនុស្សទាំងនោះចូរជាចៅហ្វាយនាយរបស់ខ្ញុំព្រះករុណាទៀតចុះ , ក្នុងទីបំផុតនៃពាក្យរបស់ជនទាំងអស់នោះ ព្រះបច្ចេកពុទ្ធពោលថា " ការប្រាថ្នាដែលអ្នកទាំងឡាយ តាំងទុកហើយយ៉ាងនោះ ចូរសម្រេចតាមសេចក្តីប្រាថ្នាចុះ " ហើយធ្វើអនុមោទនាដោយគាថារបស់ព្រះបច្ចេកពុទ្ធ ហើយគិតថា " ការដែលយើងញុំាងចិត្តរបស់ជនទាំងនេះឲ្យជ្រះថ្លា រមែងគួរ " ទើបអធិដ្ឋានថា

“ ជនទាំងនេះ ចូរឃើញយើង រហូតដល់ភ្នំគន្ធមាទន៍ចុះ ” ដូច្នេះហើយ ក៏ចៀសចេញទៅ, សូម្បីជនទាំងនោះក៏បានឈរ

មលវគ្គវណ្ណនា រឿងមេណ្ឌកសេដ្ឋី

សម្លឹងមើល ។ ព្រះបច្ចេកពុទ្ធអង្គនោះ និមន្តទៅដល់ភ្នំគន្ធ-មាទន៍ ហើយបែងចែកកត្តនោះ ប្រគេនព្រះបច្ចេកពុទ្ធ ៥០០ អង្គផង , ដោយអានុភាពរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ភត្ត នោះគ្រប់គ្រាន់ដល់ព្រះបច្ចេកពុទ្ធទាំងអស់ , ជនទាំងនោះបាន ឈរមើលនូវការចែកភត្តរបស់ព្រះបច្ចេកពុទ្ធ ។

## [ អានិសង្សនៃការថ្វាយទាន ]

កាលវេលាថ្ងៃត្រង់កន្លងទៅហើយ ភរិយារបស់សេដ្ឋី លាងឆ្នាំងហើយបិទគ្របតម្កល់ទុក, ចំណែកសេដ្ឋីត្រូវសេចក្ដី ឃ្លានបៀតបៀន ដេកហើយលក់ទៅ ។ សេដ្ឋីនោះ ភ្ញាក់ ឡើងក្នុងសាយណ្ហសម័យ ពោលទៅកាន់ភរិយាថា “នែនាង ដ៏ចម្រើន ខ្ញុំឃ្លានក្រៃលែងណាស់ , មាននៅសល់បាយក្ដាំង ខ្លះទេ ?” ភរិយារបស់សេដ្ឋី សូម្បីដឹងថា ខ្លួនលាងឆ្នាំងទុក

ហើយក៏ដោយ ក៏មិនពោលថា “ មិនមាន ” “ បានគិតថា យើងបើកឆ្នាំងបាយហើយសឹមប្រាប់ ” ដូច្នេះហើយ ទើបក្រោកឡើងទៅកាន់ទីជិតឆ្នាំងបាយហើយបើកឆ្នាំង ។

ក្នុងខណៈនោះឯង ឆ្នាំងបាយនោះ ពេញដោយភត្ត

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

មានពណ៌ដូចផ្កាម្ទិះក្រពុំ ទូលគម្របឆ្នាំងតាំងនៅ ។ ភរិយារបស់សេដ្ឋីឃើញភត្តនោះហើយ ជាអ្នកមានសរីរៈដែលបីតិពាល់ត្រូវហើយ ពោលទៅកាន់សេដ្ឋីថា “ បពិត្រនាយ សូមក្រោកឡើងចុះ ខ្ញុំលាងឆ្នាំងហើយបិទគ្របតម្កល់ទុក , ប៉ុន្តែឆ្នាំងបាយនោះពេញទៅដោយភត្ត, ដែលឈ្មោះថាបុណ្យទាំងឡាយ បុគ្គលគួរធ្វើពិតៗ , ឈ្មោះថា ទាន បុគ្គលគួរតែឲ្យ , សូមលោកក្រោកឡើងចុះ, សូមបរិភោគចុះ ”។ ភរិយារបស់សេដ្ឋីរៀបចំភត្តជូនសេដ្ឋី និងបុត្រទាំងពីរ កាលសេដ្ឋី និងបុត្រទាំងពីរបរិភោគហើយ នាងអង្គុយបរិភោគជាមួយនឹងកូនប្រសា ហើយបានឲ្យភត្តដល់នាយបុណ្ណៈ ទីនៃភត្តដែល

ជនទាំងនោះកាន់យកហើយៗ រមែងមិនអស់ទៅ , ប្រាកដត្រង់កន្ទែងដែលកាន់យកដោយវែកមួយវែកប៉ុណ្ណោះ ។

ក្នុងថ្ងៃនោះឯង ជង្រុកជាដើម ក៏ត្រឡប់ពេញដូចដើមនោះឯង ។ ភរិយារបស់សេដ្ឋីឲ្យគេដើរឃោសនាក្នុងក្រុងថា " ភត្តកើតឡើងក្នុងផ្ទះរបស់សេដ្ឋីហើយ , អ្នកណា ត្រូវការភត្តដែលជាពូជ ចូរមកទទួលយកចុះ " មនុស្សទាំងឡាយ

មលវគ្គវណ្ណនា រឿងមេណ្ឌកសេដ្ឋី

ក៏កាន់យកភត្ត ដែលជាពូជអំពីផ្ទះរបស់សេដ្ឋីនោះ ។ សូម្បីអ្នកជម្ពូទ្វីបទាំងមូល ញុំាងជីវិតឲ្យប្រព្រឹត្តទៅ អាស្រ័យសេដ្ឋីនោះ ។

## [ សេដ្ឋី និងគណៈទៅកើតឯភទ្ទិយនគរ ]

សេដ្ឋីនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ ក្នុងត្រកូលសេដ្ឋីក្នុងភទ្ទិយនគរ ។ រីឯភរិយារបស់គាត់កើតក្នុងត្រកូលស្តុកស្តម្ភមួយ ចម្រើនវ័យ

ហើយ ក៏បានទៅកាន់ត្រកូលសេដ្ឋីនោះ , ពពែទាំងឡាយមានប្រការដូចពោលហើយ អាស្រ័យកម្មរបស់សេដ្ឋីក្នុងកាលមុនផុសឡើងហើយខាងក្រោយផ្ទះ, សូម្បីបុត្រក៏បានមកជាបុត្ររបស់លោកទាំងនោះ, ស្ត្រីដែលជាកូនប្រសាក្នុងកាលមុនក៏បានមកជាកូនប្រសាទៀត , ទាសៈក៏បានជាទាសៈ ។

ក្រោយមក សេដ្ឋីប្រាថ្នានឹងសាកល្បងមើលបុណ្យរបស់ខ្លួន ក៏ឲ្យមនុស្សជម្រះជង្រុក ១,២៥០ ជង្រុក កក់សីសៈហើយ អង្គុយមាត់ទ្វារ សម្លឹងមើលទៅខាងលើ ជង្រុក



ស្រូវទាំងអស់ ពេញទៅដោយស្រូវសាលីពណ៌ក្រហម មានប្រការដូចពោលហើយ ។ សេដ្ឋីនោះ ប្រាថ្នានឹងសាកល្បងបុណ្យសូម្បីជនដ៏សេស ទើបពោលទៅកាន់ភរិយា និងបុត្រជាដើមថា " អ្នកទាំងឡាយ ចូរសាកល្បងបុណ្យរបស់អ្នកទាំងឡាយចុះ " លំដាប់នោះ ភរិយារបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង, កាលមហាជនកំពុងមើលនោះ

ឯង , ប្រើមនុស្សឲ្យវាល់អង្ករទាំងឡាយ ឲ្យចំអិនដោយអង្ករទាំងនោះ , អង្គុយលើអាសនៈដែលគេក្រាលហើយ ក្បែរខ្លោងទ្វារ កាន់យកវែកជាវិការៈនៃមាស ហើយឲ្យគេដើរប្រកាសថា “ អ្នកមានសេចក្តីត្រូវការភត្តចូរមក ” ហើយបានឲ្យរហូតទាល់តែពេញភាជនៈ ដែលជនអ្នកមកហើយៗ កាន់យក ។ កាលភរិយារបស់សេដ្ឋីឲ្យ រហូតអស់មួយថ្ងៃ ទីនៃភត្តដែលបុគ្គលកាន់យកហើយដោយវែកមួយប៉ុណ្ណោះ រមែងប្រាកដ ។ ក៏បទុមលក្ខណៈកើតពេញបាតដៃខាងឆ្វេង , ចន្ទ-លក្ខណកើតពេញបាតដៃខាងស្តាំ , ព្រោះនាងចាប់កាន់ផ្ទាំងបាយដោយដៃឆ្វេង កាន់វែកដោយដៃខាងស្តាំ ហើយថ្វាយ



ភត្តរហូតបាត្រទាំងឡាយរបស់ព្រះពុទ្ធជំនាន់មុនផង របស់ភិក្ខុសង្ឃផង ដោយអាការយ៉ាងនេះ ។ ព្រោះនាងកាន់យកធម្មក្រកត្រងទឹកប្រគេនភិក្ខុសង្ឃ អ្នកត្រាច់ទៅមកៗ , ព្រោះហេតុដូច្នោះ ទើបចន្ទលក្ខណៈ កើតពេញបាតដៃខាងស្តាំ

របស់នាង , បទុមលក្ខណៈ កើតពេញបាតដៃខាងឆ្វេងរបស់នាង ។ ព្រោះហេតុនេះ ទើបញាតិទាំងឡាយដាក់ឈ្មោះឲ្យនាងថា " ចន្ទបទុមា ( មានន័យថា មានលក្ខណៈដូចព្រះចន្ទ និងដូចផ្កាបទុម )" ។

ចំណែកបុត្ររបស់សេដ្ឋីនោះ កក់សីសៈហើយ កាន់យកថង់ចំណុះទ្រព្យមួយពាន់កហាបណៈពោលថា "អ្នកមានសេចក្ដីត្រូវការកហាបណៈទាំងឡាយ ចូរមក" ហើយបានឲ្យរហូតពេញភាជនៈរបស់ជនអ្នកមកហើយៗ ទទួលយក ។ កហាបណៈពាន់ក្នុងថង់នៅដដែល ។ សូម្បីកូនប្រសាររបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង កាន់យកកញ្ជើស្រូវហើយ អង្គុយលើទីទួលដ៏ខ្ពស់ ( ទីទួលពួដ៏អាកាស ) ពោលថា " អ្នកមានសេចក្ដីត្រូវការភត្តដែលជា



ពូជ ចូរមក " ហើយបានឲ្យរហូតពេញភាជនៈ ដល់ជនអ្នកមកហើយៗ ទទួលយក ។ កញ្ជើ ( ស្រូវ ) ជារបស់នៅពេញ

ដូចដើម ។ ចំណែកទាសៈរបស់សេដ្ឋីនោះ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ទឹមគោទាំងឡាយនឹងនឹមមាស ដោយខ្សែជាវិការៈនៃមាស កាន់យកជង្គជន្ទញមាស ឲ្យនូវកម្មដែលបុគ្គលគប្បីធ្វើ ដោយម្រាមប្រាំ ដោយវត្ថុមានក្លិនក្រអូប ( ព្រោះទឹកអប់ ) ដល់គោទាំងឡាយ បំពាក់ស្រោមជាវិការៈនៃមាសព្ធដ៏ស្នែងទាំងឡាយ រួចហើយបរទៅកាន់ស្រែ ។ អាចម៍បំណះ ៧ បំណះ គឺ " ខាងនេះ ៣ បំណះ ខាងនោះ ៣ បំណះ ត្រង់កណ្ដាល ១ បំណះ " បានបែកខ្វែកគ្នាទៅ ។ អ្នកជម្ពូទ្វីបកាន់យកវត្ថុទាំងឡាយ មានកត្តពូជមាសប្រាក់ជាដើម តាមដែលខ្លួនពេញចិត្តអំពីផ្ទះរបស់សេដ្ឋីប៉ុណ្ណោះ ។

សេដ្ឋីអ្នកមានអានុភាពច្រើនយ៉ាងនេះ បានឮថា " ព្រះសាស្ដាស្ដេចមកហើយ " ទើបគិតថា " យើងនឹងធ្វើការទទួលព្រះសាស្ដា " ចេញទៅជួបពួកតិរ្ថិយតាមផ្លូវ , សួម្បីត្រូវពួក

តិរ្ថិយទាំងនោះហាមឃាត់ថា “នែគហបតី លោកជាកិរិយាវាទ នឹងទៅកាន់សម្នាក់របស់សមណគោតម អ្នកជាអកិរិយវាទ ធ្វើអ្វី ? យ៉ាងនេះក៏ដោយ ក៏មិនជឿពាក្យរបស់ពួកតិរ្ថិយទាំងនោះដែរ ទៅហើយ ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

## [ ទោសរបស់អ្នកដទៃឃើញបានងាយ ]

គ្រានោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់សេដ្ឋីនោះ ក្នុងវេលាចប់ទេសនា សេដ្ឋីនោះបានសម្រេចសោតាបត្តិផល ហើយក្រាបទូលព្រះសាស្តាថា ខ្ញុំនត្រូវពួកតិរ្ថិយពោលទោស ហើយហាមឃាត់មិនឲ្យទៅកាន់សម្នាក់ព្រះសាស្តា , គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់សេដ្ឋីនោះថា “ ម្នាលគហបតី ឈ្មោះសត្វទាំងនេះ រមែងមិនឃើញទោសរបស់ខ្លួន សូម្បីច្រើន , រមែងបាចទោសរបស់ជនដទៃសូម្បីមិនមាន ធ្វើឲ្យមាន ដូចបុគ្គលបាចអង្កាមក្នុងទីនោះៗ ដូច្នោះ ” ដូច្នេះហើយ ក៏ត្រាស់ព្រះគាថានេះថា :-

## ១០ សុទស្សំ វជ្ជមញ្ញេសំ  អត្តនោ បន ទុទ្ទសំ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

**បរេសំ ហិ សោ វជ្ជានិ  ឱបុនាតិ យថាភុសំ**
**អត្តនោ បន ឆាទេតិ  កលឹវ កិតវា សឋោ ។**

ទោសរបស់ជនពួកដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយចំពោះពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែរមែងបិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សី បិទបាំងអត្តភាពដោយវត្ថុសម្រាប់បិទបាំង ( មានមែកឈើជាដើម ) ដូច្នោះ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សុទស្សំ** សេចក្តីថា ទោស គឺសេចក្តីភ្លាំងភ្លាត់របស់បុគ្គលដទៃ សូម្បីមានប្រមាណតិច បុគ្គលឃើញបានដោយងាយ គឺអាចនឹងឃើញបានដោយ

នាយ , ចំណែកទោសរបស់ខ្លួនសូម្បីធំក្រៃលែង ឃើញបាន ដោយលំបាក ។

បទថា **បរេសំ ហិ** សេចក្តីថា ព្រោះហេតុនោះ បុគ្គល



នោះ រមែងរោយទោសទាំងឡាយរបស់ជនពួកដទៃ ក្នុងកណ្តាលជំនុំសង្ឃជាដើម ដូចបុគ្គលឈរនៅលើទីខ្ពស់ហើយ បាចអង្កាមដាក់អ្នកដទៃដូច្នោះ ។

អត្តភាព ឈ្មោះថា **កលិ** ដោយអំណាចការប្រព្រឹត្តខុសក្នុងបក្សីទាំងឡាយ ក្នុងពាក្យថា **កលឹវ កិតវា សឋោ** នេះ ។

គ្រឿងបិទបាំង មានមែកឈើដែលអាចកាច់បានជាដើម ឈ្មោះថា **កិតវា** ( ក្នុងពាក្យថា " **កិតវា** " នេះ ) ។

នាយព្រាន ឈ្មោះថា **សឋោ** (ក្នុងពាក្យថា "**សឋោ** ") អធិប្បាយថា ព្រានបក្សីប្រាថ្នានឹងចាប់បក្សីសម្លាប់ រមែង

បិទបាំងអត្តភាពដោយគ្រឿងបិទបាំង យ៉ាងណា, បុគ្គលរមែង បិទបាំងទោសរបស់ខ្លួនក៏ដូច្នោះដែរ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងមេណ្ឌកសេដ្ឋី ចប់ )

8888888888888888888888888

## ១១ រឿងឧជ្ឈានសញ្ញិត្ថេរ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រះថេរៈមួយរូបឈ្មោះ ឧជ្ឈានសញ្ញី ត្រាស់ព្រះធម្មទេសនា នេះថា “ **បរវជ្ជានុបស្សិស្ស** ” មានបទដូច្នេះជាដើម ។

## [ គុណវិសេសមិនកើតដល់អ្នក សម្លឹងទោសអ្នកដទៃ ]

បានឮថា ព្រះថេរៈរូបនោះ ចាំតែគយគន់ឃ្លាំមើល ទោសរបស់ពួកភិក្ខុប៉ុណ្ណោះថា “ ភិក្ខុនេះ រមែងស្លៀកយ៉ាងនេះ , ភិក្ខុនេះ រមែងដណ្តប់យ៉ាងនេះ ” ។ ពួកភិក្ខុក្រាបទូលរឿងនោះចំពោះព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះថេរៈឈ្មោះឯណោះ រមែងធ្វើយ៉ាងនេះ ” ។

ព្រះសាស្តាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ ភិក្ខុតាំងនៅក្នុងធម៌ជាប្រធាននៃវត្តទូន្មានយ៉ាងនេះ បុគ្គលណាៗ មិនគួរតិះដៀល, ចំណែកភិក្ខុណា គយគន់ឃ្លាំមើលទោសរបស់ជនពួកដទៃ ព្រោះប្រាថ្នាក្នុងការលើកទោស ពោលយ៉ាងនេះ



ហើយ ត្រាច់ទៅ , បណ្តាគុណវិសេស មានឈានជាដើម គុណវិសេសសូម្បីតែមួយ រមែងមិនកើតឡើងដល់ភិក្ខុនោះ , អាសវៈទាំងឡាយប៉ុណ្ណោះ រមែងចម្រើន ” ដូច្នេះហើយ ក៏ត្រាស់ព្រះគាថានេះថា :-

**១១ បរវជ្ជានុបស្សិស្ស  និច្ចំ ឧជ្ឈានសញ្ញិនោ**

អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។

កាលបុគ្គល គយឃ្លាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស ( អ្នកដទៃ ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះឈ្មោះថាឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឧជ្ឈានសញ្ញិនោ** សេចក្ដីថា គុណវិសេសទាំងឡាយមានឈានជាដើម គុណវិសេសសូម្បីតែមួយ រមែងមិនចម្រើនដល់បុគ្គលអ្នកច្រើនទៅដោយការលើកទោស ព្រោះអ្នកគយគន់ឃ្លាំមើលទោសរបស់ជន



ពួកដទៃថា “ គួរស្លៀកយ៉ាងនេះ , គួរដណ្ដប់យ៉ាងនេះ ” ជាដើម ទើបឈ្មោះថាជាអ្នកឋិតនៅឆ្ងាយ គឺឆ្ងាយសែនឆ្ងាយ អំពីធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ពោល គឺអរហត្ត ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងព្រះឧជ្ឈាសញ្ញិត្ថេរ ចប់ )

88888888888888888888888888888888

## ១២ រឿងសុភទ្ទបរិព្វាជក

### សេចក្តីខាងដើម

ព្រះសាស្តា ទ្រង់ផ្ទំលើគ្រែតូច ជាទីបរិនិព្វាន ក្នុងសាលវ័នរបស់មល្លក្សត្រទាំងឡាយ ជិតព្រះនគរកុសិនារា ទ្រង់ប្រារព្ធបរិព្វាជកឈ្មោះសុភទ្ទ ត្រាស់ព្រះធម្មទេសនានេះថា " **អាកាសេវ បទំ នត្ថិ** " ជាដើម ។

## [ បុព្វកម្មរបស់សុភទ្ទ ]

បានឮថា ក្នុងអតីតកាល សុភទ្ទបរិព្វាជកនោះ កាលប្អូនប្រុសឲ្យទានថ្នោង ( ទានដំបូង ) អស់វារៈ ៩ ដងក្នុងសន្ទូងមួយរដូវ , មិនប្រាថ្នានឹងឲ្យ ដំអក់នៅរហូតដល់ទីបំផុតនៃសន្ទូងទើបឲ្យ ។

ព្រោះហេតុដូច្នោះ ទើបមិនបានគាល់ព្រះសាស្តា ទាំងក្នុងបឋមពោធិកាល ទាំងក្នុងមជ្ឈិមពោធិកាល ។ ប៉ុន្តែក្នុងបច្ឆិមពោធិកាល ក្នុងវេលាជាទីបរិនិព្វានរបស់ព្រះសាស្តា គិតថា " យើងសួរនូវសេចក្តីសង្ស័យរបស់ខ្លួនក្នុងបញ្ហា ៣ ចំណុច នឹងបរិព្វាជកទាំងឡាយដែលជាមនុស្សចាស់ មិនសួរ

ព្រះសមណគោតម ដោយសេចក្ដីសម្គាល់ថា ជាមនុស្សក្មេង, ក៏ឥឡូវនេះ ជាកាលបរិនិព្វានរបស់ព្រះសមណគោតមនោះ, វិប្បដិសារៈគប្បីកើតដល់យើងក្នុងកាលជាខាងក្រោយ ព្រោះហេតុតែមិនបានសួរព្រះសមណគោតម" ហើយចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ត្រូវព្រះអានន្ទហាមឃាត់ ក៏នៅតែបានចូលទៅក្នុងរាំងនន ព្រោះបានព្រះសាស្ដាទ្រង់ធ្វើឱកាសឲ្យ ហើយត្រាស់ថា " ម្នាលអានន្ទ អ្នកកុំហាមឃាត់សុភទ្ទឡើយ, សុភទ្ទចូរសួរបញ្ហានឹងតថាគត " ទើបអង្គុយព្វដ៏ខាងក្រោមនៃគ្រែតូចទូលសួរបញ្ហាទាំងនេះថា " បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា ស្នាមជើងក្នុងអាកាសមានដែរឬ ? សមណៈខាងក្រៅសាសនានេះមានដែរឬ ? សង្ខារទាំងឡាយ ឈ្មោះថាទៀង មានដែរឬ ព្រះអង្គ ?" ។

## [ ព្រះសាស្ដាទ្រង់ដោះស្រាយបញ្ហារបស់សុភទ្ទ ]

គ្រានោះ ព្រះសាស្តា កាលនឹងត្រាស់ប្រាប់ការមិនមានស្នាមជើងក្នុងអាកាសជាដើមទាំងនោះដល់សុភទ្ទ ទើបទ្រង់សម្តែងធម៌ដោយព្រះគាថាទាំងនេះថា :-

មលវគ្គវណ្ណនា រឿងសុភទ្ទបរិព្វាជក

១២ អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។
អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ សមណោ នត្ថិ ពាហិរេ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅមិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅមិនមាន សង្ខារទាំងឡាយជារបស់ទៀង មិនមានព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់

ញ៉ាំវទេ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បទំ** សេចក្ដីថា ស្នាមជើងនៃសត្វណាៗ ដែលបុគ្គលគប្បីបញ្ញត្តថា “ មានរូបយ៉ាងនេះ ” ដោយអំណាចនៃពណ៌ និងសណ្ឋានទ្រង់ទ្រាយ ក្នុងអាកាស

**ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ**

មិនមាន ។

បទថា **ពាហិរេ** សេចក្ដីថា សមណៈអ្នកតាំងនៅក្នុងមគ្គ និងផលខាងក្រៅពីសាសនានេះ មិនមាន ។

បទថា **បជា** សេចក្ដីថា ពួកសត្វ ពោល គឺសត្វលោកនេះ ត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរមានតណ្ហាជាដើមប៉ុណ្ណោះ ។

បទថា **និប្បបញ្ចា** សេចក្ដីថា ចំណែកព្រះតថាគតទាំងឡាយ ជាអ្នកឈ្មោះថា មិនមានធម៌ជាគ្រឿងយឺតយូរ

ព្រោះព្រះអង្គទ្រង់កាត់ធម៌ជាគ្រឿងឃឹតឃូរទាំងពួង បានជាសមុច្ឆេទនៅក្រោមមណ្ឌលពោធិព្រឹក្សហើយ ។

ខន្ធ ៥ ឈ្មោះថា សង្ខារ, បណ្តាខន្ធទាំង ៥ នោះ ខន្ធណាមួយឈ្មោះថា ទៀង មិនមាន ។

បទថា **ឥញ្ជិតំ** សេចក្តីថា ជនទាំងឡាយគប្បីប្រកាន់ “ សង្ខារទាំងឡាយជារបស់ទៀង ” ដោយអំណាចកិលេសជាគ្រឿងញាប់ញ័រ គឺតណ្ហា មានះ និងទិដ្ឋិឯណា , កិលេសជាគ្រឿងញាប់ញ័រនោះ មិនមានដល់ព្រះពុទ្ធទាំងឡាយឡើយ ។

*មលវគ្គវណ្ណនា រឿងសុភទ្ទបរិព្វាជក*

ក្នុងកាលចប់ធម្មទេសនា សុភទ្ទបរិព្វាជកតាំងនៅក្នុងអនាគាមិផល ។ ព្រះធម្មទេសនា បានមានប្រយោជន៍សូម្បីដល់បរិស័ទអ្នកប្រជុំគ្នានៅទីនោះ ៕

( រឿងសុភទ្ទបរិព្វាជក ចប់ )

88888888888888888888

## មលវគ្គវណ្ណនា ចប់

## វគ្គទី ១៨ ចប់

## ធម្មបទគាថា ធម្មដ្ឋវគ្គទី ១៩

*ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ*
*យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ។*

**អសាហសេន ធម្មេន សមេន នយតី បរេ**
**ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។**

បុគ្គលកាត់សេចក្ដីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្ដីទាំងពីរ គឺសេចក្ដីពិតនិងសេចក្ដីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ ( ដល់ទោស ) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

**ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមានប៉ុណ្ណា ឈ្មោះថាជាបណ្ឌិតដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គលដែលមានសេចក្ដី

ក្រេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

**ន តាវតា ធម្មធរោ  យាវតា ពហុ ភាសតិ**
**យោ ច អប្បម្បិ សុត្វាន  ធម្មំ កាយេន បស្សតិ**
**ស វេ ធម្មធរោ ហោតិ  យោ ធម្មំ នប្បមជ្ជតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណ ប៉ុនណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុ មានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែ បុគ្គលណា ស្ដាប់ព្ទវចនៈ សូម្បីមានប្រមាណ តិចហើយ ឃើញធម៌ដោយនាមកាយ គឺចិត្តបាន បុគ្គលនោះទើបឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ បុគ្គល ណា មិនមើលងាយធម៌ បុគ្គលនោះឯង ឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ ។

**ន តេន ថេរោ ហោតិ  យេនស្ស បលិតំ សិរោ**
**បរិបក្កោ វយោ តស្ស  មោឃជិណ្ណោតិ វុច្ចតិ ។**

យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ស វេ វន្តមលោ ធីរោ  សោ ថេរោតិ បវុច្ចតិ ។

បុគ្គលមានក្បាលស្កូវហើយ  ដោយហេតុណា ឈ្មោះថាជាថេរៈ ដោយហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ជ្រុលហើយ  ហៅថា ចាស់ជាមោឃៈ ។ លុះត្រាតែ សច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ  ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។

ន វាក្ករណមត្តេន  វណ្ណបោក្ខរតាយ វា
សាធុរូបោ នរោ ហោតិ  ឥស្សុកី មច្ឆរី  សឋោ ។
យស្ស ចេតំ សមុច្ឆិន្នំ  មូលឃច្ចំ សមូហតំ
ស វន្តទោសោ មេធាវី  សាធុរូបោតិ វុច្ចតិ ។

បុគ្គលមានសេចក្តីឫស្យា  មានសេចក្តីកំណាញ់

ជាអ្នកអួតអាង ឈ្មោះថាជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ ( ល្អ ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនទាន់បានទេ ។ លុះត្រាតែទោសជាតិ មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះ ជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាជាមនុស្សល្អបាន ។

**ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ**
**ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។**
**យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ**
**សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។**

បុគ្គលមិនបានឈ្មោះថាជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលវត្ត និងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកប

ដោយសេចក្តីប្រាថ្នា និងលោភៈ ឈ្មោះថា ជាសមណៈដូចម្តេចបាន ។ លុះត្រាតែបុគ្គលណារម្ងាប់បាបទាំងឡាយទាំងតូចទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

**ន តេន ភិក្ខុ សោ ហោតិ យាវតា ភិក្ខវេ បរេ**
**វិសំ ធម្មំ សមាទាយ ភិក្ខុ ហោតិ ន តាវតា ។**
**យោធ បុញ្ញញ្ច បាបញ្ច ពាហេត្វា ព្រហ្មចរិយវា**
**សង្ខាយ លោកេ ចរតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណាដើរសូមជនទាំងឡាយដទៃ ដោយហេតុត្រឹមណា បុគ្គលនោះ មិនទាន់បានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមណោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនទាន់បានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យ និងបាប

ចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរត្រាច់ ទៅក្នុងលោកដោយសេចក្តីចេះដឹង បុគ្គលនោះឯង ទើបហៅថាជាភិក្ខុ ។

**ន មោនេន មុនិ ហោតិ    មូឡ្ហរូបោ អវិទ្ទសុ**
**យោ ច តុលំវ បគ្គយ្ហ    វហរមាទាយ បណ្ឌិតោ**
**បាបានិ បរវជ្ជេតិ    ស មុនិ តេន សោ មុនិ**
**យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។**

បុគ្គលមានសេចក្តីវង្វេង ជាធម្មតា មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីងហើយថ្លឹងដូច្នោះ បុគ្គលនោះទើបឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះ ហៅថា មុនី ដោយហេតុនោះ ។

**ន តេន អរិយោ ហោតិ  យេន បាណានិ ហឹសតិ**
**អហឹសា សព្វបាណានំ  អរិយោតិ បវុច្ចតិ  ។**

បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថា ជាអរិយៈដោយហេតុនោះទេ បុគ្គលដែលតថាគតហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

**ន សីលព្វតមត្តេន  ពាហុសច្ចេន វា បន**
**អថ វា សមាធិលាភេន  វិវិត្តសយនេន វា**
**ផុសាមិ នេក្ខម្មសុខំ  អបុថុជ្ជនសេវិតំ**
**ភិក្ខុ វិស្សាសមាបាទិ  អប្បត្តោ អាសវក្ខយំ  ។**

ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាលទុកចិត្តដោយគុណត្រឹមតែសីល និងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញ

ពាល់ត្រូវនៃទុក្ខមួសុខ ដែលបុថុជ្ជនមិនដែលជួប
ប្រសព្វ ដូច្នេះឡើយ ។

**ធម្មដ្ឋវគ្គទី ១៨ ចប់**

# ១៩. ធម្មដ្ឋវគ្គវណ្ណនា

## ១ រឿងមហាអមាត្យអ្នកវិនិច្ឆ័យ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាអមាត្យអ្នកវិនិច្ឆ័យ ត្រាស់ព្រះធម្មទេសនានេះថា “ **ន តេន ហោតិ ធម្មដ្ឋោ** ” មានបទដូច្នេះជាដើម ។

## [ ពួកភិក្ខុឃើញមហាអមាត្យទទួលសំណូក ]

សេចក្តីពិស្តារថា ថ្ងៃមួយ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតក្នុងស្រុកជិតខ្លោងទ្វារខាងទិសឧត្តរ នៃក្រុងសាវត្ថី ត្រឡប់មកអំពីបិណ្ឌបាតហើយមកកាន់វិហារតាមផ្លូវកណ្តាលក្រុង ។

ខណៈនោះ មហាមេឃតាំងឡើង ញុំាងភ្លៀងឲ្យធ្លាក់ចុះមក ។ ភិក្ខុទាំងនោះ ចូលទៅកាន់សាលាសម្រាប់វិនិច្ឆ័យដែលនៅក្នុងទីចំពោះមុខ ឃើញពួកមហាអមាត្យអ្នកវិនិច្ឆ័យ



ទទួលយកសំណូក ហើយធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ទើបគិតថា “ ឱ ! មហាអមាត្យទាំងនេះមិនតាំងនៅក្នុងធម៌ , កាលភ្លៀងរាំងហើយ ក៏និមន្តមកកាន់វិហារ ថ្វាយបង្គំព្រះ-

សាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ក្រាបទូលសេចក្តីនោះចំពោះព្រះសាស្តា ។

## [ លក្ខណៈរបស់បុគ្គលអ្នកតាំងនៅ ឬមិនតាំងនៅក្នុងធម៌ ]

ព្រះសាស្តា ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ពួកអាមាត្យអ្នកវិនិច្ឆ័យ ជាអ្នកធ្លាក់ក្នុងអំណាចអគតិ មានឆន្ទាគតិជាដើម កាត់សេចក្តី ( ក្តី ) ដោយការវៀចវេរ ( ការលំអៀង ) មិនឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ទេ , ចំណែកបុគ្គលណា ដេញដោល សាកសួររកនូវកំហុសឲ្យល្អិតល្អន់សិន ហើយសឹមធ្វើការវិនិច្ឆ័យក្តី ឲ្យសមគួរតាមកំហុស ទើបឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ " ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា :-

**១ ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ**

*ធម្មដ្ឋវគ្គវណ្ណនា រឿងមហាអមាត្យអ្នកវិនិច្ឆ័យ*

**យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ**

អសាហសេន ធម្មេន  សមេន នយតី បរេ
ធម្មស្ស គុត្តោ មេធាវី  ធម្មដ្ឋោតិ បវុច្ចតិ ។

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិត ណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌ តាមសមគួរ ( ដល់ទោស ) បុគ្គលនោះ ឈ្មោះថា ជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **តេន** ប្រែថា ដោយសារហេតុត្រឹមតែប៉ុណ្ណោះឯង ។ បទថា **ធម្មដ្ឋោ** សេចក្តីថា បុគ្គលអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ ដែលព្រះរាជាទាំងឡាយគប្បីធ្វើដោយផ្ទាល់ព្រះអង្គឯង មិនឈ្មោះថា ជាអ្នកតាំងនៅ

ក្នុងធម៌ទេ ។ បទថា **យេន** ប្រែថា ដោយហេតុណា ។

បទថា **អត្ថំ** សេចក្តីថា នូវគតិដែលចុះសម្រុងហើយ ដែលខ្លួនគប្បីវិនិច្ឆ័យ ។

ពីរបទថា **សហសា នយេ** សេចក្តីថា បុគ្គលអ្នកតាំងនៅក្នុងអគតិមានឆន្ទាគតិជាដើម វិនិច្ឆ័យក្តីដោយការរៀចវេរ ( ដោយការលំអៀង ) គឺដោយពោលកុហក ។ អធិប្បាយថា ពិតណាស់ បុគ្គលណាតាំងនៅក្នុងឆន្ទាគតិ គឺសេចក្តីស្រឡាញ់ ពោលមុសាវាទ រមែងធ្វើញាតិ ឬមិត្តសម្លាញ់របស់ខ្លួនដែលមិនមែនជាម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យ , តាំងនៅក្នុងទោសាគតិ គឺសេចក្តីស្អប់ ពោលមុសាវាទ រមែងធ្វើអ្នកដែលជាសត្រូវរបស់ខ្លួន ដែលជាម្ចាស់ទ្រព្យពិតៗ មិនឲ្យជាម្ចាស់ទ្រព្យ , តាំងនៅក្នុងមោហាគតិ គឺការវង្វេង ទទួលសំណូកក្នុងវេលាវិនិច្ឆ័យក្តី ហើយធ្វើដូចជាបញ្ជូនចិត្តទៅកាន់ទីដទៃ សម្លឹងមើលខាងនោះ និងខាងនេះ ពោលពាក្យកុហក

រមែងណែនាំបុគ្គលដទៃដោយវៀចវេរថា “ អ្នកនេះឈ្នះ , អ្នកនេះចាញ់ ” តាំងនៅក្នុងភយាគតិ គឺការភ័យខ្លាច រមែងលើក

*ធម្មដ្ឋវគ្គវណ្ណនា រឿងមហាអមាត្យអ្នកវិនិច្ឆ័យ*

នូវការឈ្នះឲ្យទៅបុគ្គលណាមួយ ដែលជាអ្នកប្រកបដោយជាតិជាឥស្សរជន សូម្បីបុគ្គលនោះ ជាអ្នកចាញ់ក៏ដោយ ” បុគ្គលនេះ ឈ្មោះថា ជាអ្នកណែនាំសេចក្ដីដោយការវៀចវេរ បុគ្គលនោះ មិនឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ទេ ។

បាទព្រះគាថាថា **យោ ច អត្ថំ អនត្ថញ្ច** សេចក្ដីថា នូវហេតុពិត និងហេតុមិនពិត ។ ពីរបទថា **ឧភោ និច្ឆេយ្យ** សេចក្ដីថា ចំណែកបុគ្គលណាជាបណ្ឌិត វិនិច្ឆ័យហេតុដែលជាគតិ និងហេតុដែលមិនមែនជាគតិទាំងពីរ ។

បទថា **អសាហសេន** គឺមិនពោលមុសាវាទ ។ បទថា **ធម្មេន** ប្រែថា ដោយធម៌ជាគ្រឿងវិនិច្ឆ័យ គឺមិនមែនដោយអំណាចអគតិ មានឆន្ទាគតិជាដើមទេ ។ បទថា **សមេន** គឺ

រមែងណែនាំជនទាំងឡាយដទៃ គឺឲ្យដល់ការឈ្នះ ឬការចាញ់ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរដល់ទោស ។

ពីរបទថា **ធម្មស្ស គុត្តោ** សេចក្តីថា បុគ្គលនោះដែលធម៌ឃុំគ្រងហើយ គឺដែលធម៌រក្សាហើយ ប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ឈ្មោះថា អ្នកមានបញ្ញា ព្រះមានព្រះភាគ

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

ទ្រង់ត្រាស់ថា “អ្នកតាំងនៅក្នុងធម៌” ព្រោះជាអ្នកតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យក្តី ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

***( រឿងមហាមាត្យអ្នកវិនិច្ឆ័យក្តី ចប់ )***

# ២ រឿងឆព្វគ្គិយភិក្ខុ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា “**ន តេន បណ្ឌិតោ ហោតិ** ” មានបទដូច្នេះជាដើម ។

[ ឆព្វគ្គិយភិក្ខុធ្វើរោងឲ្យវឹកវរ ]

បានឮថា ឆព្វគ្គិយភិក្ខុទាំងនោះដើរធ្វើរោងកត្តឲ្យរីករាវ ក្នុងវិហារខ្លះ ក្នុងស្រុកខ្លះ ។

ក្រោយមក នៅថ្ងៃមួយ ភិក្ខុទាំងឡាយសួរភិក្ខុកំលោះ និងសាមណេរអ្នកធ្វើកត្តកិច្ចក្នុងស្រុកហើយ ត្រឡប់មកថា “ នែ អាវុសោទាំងឡាយ រោងកត្តដូចម្តេច ?” ភិក្ខុកំលោះ និងសាមណេរ ឆ្លើយតបថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយកុំសួរឡើយ ” ពួកឆព្វគ្គិយពោល ថា ពួកយើងជាអ្នកឆ្លាត , ពួកយើងជាបណ្ឌិត នឹងប្រហារ ភិក្ខុទាំងនេះ រាយសម្រាមលើសីសៈ ហើយបណ្តេញចេញ ហើយចាប់ខ្នងពួកខ្ញុំ រោយសម្រាមលើក្បាលរបស់ពួកខ្ញុំ ធ្វើ

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

រោងកត្តឲ្យរីករាវ ។ ភិក្ខុទាំងឡាយទៅកាន់សម្នាក់ព្រះសាស្តា ហើយ ក្រាបទូលរឿងនោះ ។

## [ លក្ខណៈបណ្ឌិត និងមិនមែនបណ្ឌិត ]

ព្រះសាស្តាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ តថាគត មិនហៅបុគ្គលអ្នកនិយាយបៀតបៀនអ្នកដទៃ ថាជាបណ្ឌិត ឡើយ , ប៉ុន្តែ តថាគតហៅបុគ្គលដែលក្សេម មិនមានពៀរ មិនមានភ័យថា “ ជាបណ្ឌិត ” ដូច្នេះហើយ ត្រាស់ព្រះគាថា នេះថា :-

**ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ**
**ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។**

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណ ប៉ុនណា ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនទាន់បានទេ លុះត្រាតែបុគ្គល ដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **យាវតាជាដើម** សេចក្តីថា បុគ្គលមិនឈ្មោះថា ជាបណ្ឌិតដោយហេតុត្រឹមតែនិយាយ

ច្រើនក្នុងកណ្ដាលជុំនុំសង្ឃនោះទេ , ចំណែកបុគ្គលណា ខ្លួនឯងជាអ្នកមានសេចក្ដីក្សេម មិនមានពៀរទាំង ៥ ជាអ្នកមិនមានភ័យ គឺភ័យ រមែងមានដល់មហាជន ព្រោះអាស្រ័យបុគ្គលនោះ , បុគ្គលនោះឈ្មោះថា “ ជាបណ្ឌិត ” ដូច្នេះឯង ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

( រឿងឆព្វគ្គិយភិក្ខុ ចប់ )

## ៣ រឿងព្រះឯកុទានត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧីណាស្រេពឈ្មោះថាឯកុទានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “ **ន តាវតា ធម្មធរោ** ” មានបទដូច្នេះជាដើម ។

## [ ពួកទេវតាឲ្យសាធុការ ដល់ទេសនារបស់ព្រះថេរៈ ]

បានឮថា ព្រះថេរៈនោះ តែងតែគង់នៅក្នុងព្រៃតែមួយអង្គឯង ។ ហើយតែងតែឧទានគាថាមួយគាថាប៉ុណ្ណោះថា :

“ សេចក្តីសោកទាំងឡាយ រមែងមិនមានដល់បុគ្គល
អ្នកមានចិត្តតាំងមាំហើយ មិនប្រមាទ ជាមុនី សិក្សា
ក្នុងធម៌ជាផ្លូវនៃមោនបដិបត្តិ ជាអ្នកនឹងធឹង ស្ងប់
រម្ងាប់ហើយ មានសតិសព្វកាល ។

បានឮថា ក្នុងថ្ងៃឧបោសថ លោកប្រកាសការស្តាប់ធម៌ខ្លួនឯងហើយ ពោលគាថានេះ ។ សំឡេងនៃសាធុការរបស់ទេវតាដូចជាសំឡេងនៃការស្រុតផែនដី ។ គ្រានោះ

ភិក្ខុ អ្នកទ្រទ្រង់ព្រះត្រៃបិដកពីររូប មានបរិវារមួយអង្គៗ ៥០០ បានទៅកាន់សម្នាក់របស់ព្រះថេរៈរូបនោះ ក្នុងថ្ងៃឧបោសថ , ព្រះថេរៈនោះឃើញភិក្ខុទាំងនោះភ្ញាម ក៏មានចិត្តត្រេកអររីករាយ ហើយពោលថា “ លោកម្ចាស់ទាំងឡាយមកកាន់ទីនេះ ជាការប្រពៃពេកណាស់ , ថ្ងៃនេះ ពួកខ្ញុំនឹងស្តាប់ព្រះធម៌ក្នុងសម្នាក់របស់លោកម្ចាស់ទាំងឡាយ ” ។

ភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដកសួរថា ម្នាលអាវុសោ ក៏ជនអ្នកស្តាប់ធម៌ក្នុងទីនេះ មានដែរឬ ?

ព្រះឯកុទានឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន មាន, ដងព្រៃនេះ ជាប្រទេសគឹកកងទៅដោយសំឡេងនៃសាធុការរបស់ទេវតាទាំងឡាយ រមែងមានក្នុងថ្ងៃស្តាប់ព្រះធម៌ ។

## [ ពួកទេវតាមិនឲ្យសាធុការដល់ទេសនា របស់ភិក្ខុពីររូប ]

បណ្ដាភិក្ខុពីរអង្គនោះ ព្រះថេរៈអ្នកទ្រទ្រង់ព្រះត្រៃ-បិដកមួយអង្គសូធ្យធម៌ , មួយអង្គពោលធម៌ ។ ទេវតាតែមួយអង្គក៏មិនបានឲ្យសាធុការដែរ ។ ភិក្ខុទាំងនោះ ក៏សួរព្រះ



ឯកុទានថា “ ម្នាលអាវុសោ ក្រែងលោកពោលថា ក្នុងថ្ងៃស្ដាប់ព្រះធម៌ ពួកទេវតាទាំងឡាយក្នុងដងព្រៃនេះ រមែងឲ្យសាធុការដោយសំឡេងដ៏លាន់ឮ មិនមែនឬ ? តើរឿងនេះជាយ៉ាងណា ? ” ។

ព្រះឯកុទាន. បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងថ្ងៃដទៃៗជាយ៉ាងនោះ , ប៉ុន្តែថ្ងៃនេះ ខ្ញុំព្រះករុណាមិនដឹងថា ជាយ៉ាងណាដែរ ។

ភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទៅកាន់ព្រះឯកុទានថា ម្នាលអាវុសោ បើដូច្នោះ អ្នកចូរពោលធម៌លមើល ។

ព្រះឯកុទានចាប់ផ្ដិតវិជនី រួចគង់លើអាសនៈ ហើយពោលគាថានោះ, ទេវតាទាំងឡាយឲ្យសាធុការដោយសំឡេងដ៏លាន់ឮ ដូចជាសំឡេងស្រុតផែនដី ។

## [ ពួកភិក្ខុតិះដៀលទេវតា ]

គ្រានោះ ភិក្ខុជាបរិវាររបស់ព្រះតេបិដកត្ថេរនោះលើកទោសពួកទេវតាថា " ទេវតាក្នុងព្រៃនេះ ឲ្យសាធុការដោយការយល់មុខ , កាលភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដកពោលធម៌

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

សូម្បីមានប្រមាណប៉ុណ្ណោះ, ក៏មិនបានពោលអ្វីៗ សូម្បីតែការសរសើរ , កាលព្រះថេរៈចាស់អង្គនេះ ពោលគាថាតែមួយគាថាហើយ ក៏នាំគ្នាឲ្យសាធុការដោយសំឡេងដ៏លាន់ឮ ដូចជាសំឡេងស្រុតផែនដី " ភិក្ខុទាំងនោះ ទៅដល់វិហារហើយក្រាបទូលសេចក្ដីនោះចំពោះព្រះសាស្ដា ។

## [ លក្ខណៈរបស់អ្នកទ្រទ្រង់ធម៌ និងមិនទ្រទ្រង់ធម៌ ]

ព្រះសាស្ដាត្រាស់ថា “ ម្នាលភិក្ខុទាំងឡាយ តថាគត មិនហៅបុគ្គលអ្នករៀនច្រើន ឬនិយាយច្រើនថា ជាអ្នកទ្រទ្រង់ធម៌ទេ , ចំណែកបុគ្គលណាស្ដាប់ព្រះពុទ្ធវចនៈ សូម្បីតែមួយគាថា ហើយចាក់ធ្លុះសច្ចៈទាំងឡាយបាន បុគ្គលនោះ តថាគតហៅថាជាអ្នកទ្រទ្រង់ធម៌ ” ដូច្នេះហើយ ក៏ទ្រង់ត្រាស់ព្រះគាថានេះថា :-

**៣ ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ**
**យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ**
**ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។**

*ធម្មដ្ឋវគ្គវណ្ណនា រឿងព្រះឯកុទានត្ថេរ*

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុនណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះមិនទាន់បានទេ លុះត្រាតែបុគ្គលណា ស្ដាប់ពុទ្ធវចនៈ សូម្បីមានប្រមាណតិចហើយ ឃើញធម៌ដោយនាមកាយ គឺចិត្តបាន

បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនមើលងាយធម៌ បុគ្គលនោះឯងឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ។

## អធិប្បាយគាថា

បណ្ដាបទថាទាំងនោះ បទថា **យាវតា** ជាដើម សេចក្ដីថា បុគ្គលមិនឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ដោយហេតុត្រឹមតែនិយាយច្រើន ដោយហេតុមានការរៀន និងការទ្រទ្រង់ ចាំនិងការប្រាប់ជាដើមទេ ។

បទថា **អប្បម្បិ** ជាដើម សេចក្ដីថា ចំណែកបុគ្គលណាស្ដាប់ធម៌សូម្បីតែមានប្រមាណតិច ហើយអាស្រ័យធម៌ អាស្រ័យអត្ថ ជាអ្នកបដិបត្តិធម៌ដ៏សមគួរដល់ធម៌ កំណត់



បានឮថា ព្រះពោឋិលៈនោះ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក បង្រៀនធម៌ដល់ភិក្ខុ ៥០០ រូប ក្នុងសាសនានៃព្រះពុទ្ធ ៧ អង្គ ។ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា " ភិក្ខុនេះ

រមែងមិនមានសូម្បីការគិតថា យើងនឹងធ្វើនូវអំពើជាគ្រឿងរលាសចេញចាកទុក្ខដល់ខ្លួន , តថាគតនឹងញុំាងភិក្ខុនេះឲ្យតក់ស្លុត ” ។

ជាប់ពីពេលនោះមក ព្រះអង្គតែងតែត្រាស់ទៅកាន់ព្រះថេរៈនោះ ក្នុងវេលាដែលព្រះថេរៈមកកាន់ទីជាទីបម្រើព្រះអង្គថា “ ម្នាលភិក្ខុស្លឹករឹតទទេ ( គម្ពីរទទេ ) ចូរមក, ម្នាលភិក្ខុគម្ពីរទទេ ចូរអង្គុយ , ម្នាលភិក្ខុគម្ពីរទទេ ចូរទៅ



ចុះ, សូម្បីក្នុងវេលាដែលព្រះថេរៈក្រោកចេញទៅ ក៏ត្រាស់ថា ភិក្ខុគម្ពីរទទេទៅហើយ ” ។ ព្រះបោឋិលៈនោះគិតថា យើងជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា បង្រៀនធម៌ដល់ភិក្ខុ ៥០០ រូប ក្នុងគណៈធំៗ ដល់ទៅ ១៨ , ទុកណាជាដូច្នោះ ព្រះតថាគតតែងតែត្រាស់ហៅយើងរឿយៗថា នៃភិក្ខុគម្ពីរទទេ , ព្រះសាស្តាត្រាស់ហៅយើងយ៉ាងនេះ ព្រោះការមិនមានគុណវិសេស មានឈានជាដើមដោយពិត”

លោកមានសេចក្តីសង្វេគកើតឡើងហើយ ក៏គិតថា ឥឡូវ នេះ យើងនឹងចូលទៅកាន់ព្រៃហើយធ្វើសមណធម៌ ចាត់ចែងបាត្រ និងចីវរខ្លួនឯងហើយ បានចេញទៅជាមួយនឹងភិក្ខុអ្នករៀនធម៌ ហើយចេញទៅក្រោយភិក្ខុទាំងអស់ក្នុងវេលាជិតភ្លឺ ។ ពួកភិក្ខុអន្តេវាសិកដោយស្វាធ្យាយក្នុងបរិវេណ មិនបានកំណត់លោកថា “ អាចារ្យ ” ។ ព្រះថេរៈទៅអស់ ២ ពាន់យោជន៍ ហើយចូលទៅរកភិក្ខុ ៣០ រូប ដែលមានអាវាសនៅក្នុងព្រៃ ថ្វាយបង្គំព្រះសង្ឃត្ថេរហើយ ពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជាទីពឹង



របស់ខ្ញុំព្រះករុណា ” ។

ព្រះសង្ឃត្ថេរ.“ ម្នាលអ្នកមានអាយុ អ្នកជាធម្មកថិកព្រះពុទ្ធវចនៈណាៗ ដែលពួកយើងគប្បីដឹងបាន ក៏ព្រោះអាស្រ័យអ្នក , ហេតុដូចម្តេច ទើបអ្នកពោលយ៉ាងនេះ ?

ព្រះបោឋិលៈ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំធ្វើយ៉ាងនេះឡើយ , សូមលោកម្ចាស់ជាទីពឹងរបស់ខ្ញុំ ។

## [ វិធីកម្ចាត់មានះរបស់ព្រះបោឋិលៈ ]

ក៏ព្រះថេរៈទាំងអស់នោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។

គ្រានោះ ព្រះមហាថេរៈ បញ្ជូនព្រះបោឋិលៈនោះទៅកាន់សម្នាក់ព្រះអនុថេរៈ ដោយគិតថា “ ភិក្ខុនោះមានមានះព្រោះអាស្រ័យការរៀនដោយពិត ” ។ សូម្បីព្រះអនុថេរៈក៏ពោលទៅកាន់ព្រះបោឋិលៈនោះ ដូច្នោះដែរ ។ ព្រះថេរៈទាំងអស់ កាលបញ្ជូនលោកទៅដោយទំនងនេះ ក៏បញ្ជូនទៅកាន់សម្នាក់សាមណេរមានអាយុ ៧ ខួប ដែលថ្មីជាង

សាមណេរទាំងអស់ ដែលគងធ្វើកម្ម គឺការដេរចីវរក្នុងទីសម្រាកពេលថ្ងៃ ។ ព្រះថេរៈទាំងឡាយនាំមានះរបស់ព្រះថេរៈចេញបានដោយឧបាយយ៉ាងនេះ ។

## [ ព្រះបោឋិលៈអស់មានះ ]

ព្រះបោឋិលៈនោះ មានមានះដែលព្រះថេរៈទាំងឡាយនាំចេញហើយ ទើបផ្គងអញ្ជលីក្នុងសម្នាក់សាមណេរហើយពោលថា “ នែ អ្នកសប្បុរស ចូរអ្នកជាទីពឹងរបស់ខ្ញុំ ” ។

សាមណេរ. ស្ដាប់ហើយ លោកអាចារ្យ លោកនិយាយអ្វី លោកជាមនុស្សចាស់ ជាពហុស្សុត, ជាពហុស្សុតការណ៍អ្វីៗ ជាកិច្ច ដែលខ្ញុំគប្បីដឹងក្នុងសម្នាក់របស់លោកម្ចាស់ មាន ។

ព្រះបោឋិលៈ. នែអ្នកជាសប្បុរស អ្នកកុំធ្វើយ៉ាងនេះឡើយ អ្នកចូរជាទីពឹងរបស់ខ្ញុំ ។

សាមណេរ. ប្រសិនបើ លោកម្ចាស់ជាអ្នកអត់ទ្រាំចំពោះឱវាទបាននោះ , ខ្ញុំនឹងជាទីពឹងរបស់លោកម្ចាស់ ។

ព្រះបោឋិលៈ. នៃអ្នកសប្បុរស ខ្ញុំអាចអត់ទ្រាំបាន ,

មគ្គវគ្គវណ្ណនា រឿងព្រះបោឋិលត្ថេរ

កាលអ្នកពោលថា សូមចូលទៅកាន់ភ្លើង ខ្ញុំនឹងចូលទៅកាន់ភ្លើងដោយពិត ។

## [ ព្រះបោឋិលៈបដិបត្តិតាមឱវាទរបស់សាមណេរ ]

គ្រានោះ សាមណេរនោះ សម្តែងស្រះមួយក្នុងទីមិនឆ្ងាយ ហើយពោលទៅកាន់ព្រះបោឋិលៈថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ស្លៀកដូចដើមនោះហើយ សូមចុះទៅកាន់ស្រះនេះ ” ។ ពិតណាស់ សាមណេរនោះសូម្បីដឹងថា ចីវរពីរជាន់ដែលព្រះថេរៈស្លៀកដណ្តប់នោះ មានតម្លៃច្រើនហើយក៏ដោយ ប៉ុន្តែដោយមានបំណងនឹងល្បងមើលលោកថា “ ព្រះថេរៈនេះនឹងជាអ្នកអត់ទ្រាំចំពោះឱវាទបានដែរឬទេ ” ទើបពោលយ៉ាងនោះ ។ សូម្បីព្រះថេរៈក៏ចុះទៅកាន់ស្រះដោយពាក្យតែមួយម៉ាត់ប៉ុណ្ណោះ ។ គ្រានោះ ក្នុងវេលាដែលជាយចីវរទទឹក សាមណេរទើបពោលទៅ

កាន់លោកថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមមកចុះ ” ហើយពោលនឹងលោក ក្នុងពេលដែលលោកមកឈរដោយ ពាក្យតែមួយម៉ាត់ប៉ុណ្ណោះថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន



ដំបូក ១ មានរន្ធ ៦, បណ្ដារន្ធទាំងនោះ មេទន្សងមួយចូល ទៅតាមរន្ធមួយ បុគ្គលប្រាថ្នានឹងចាប់វាទើបចុករន្ធទាំង ៥ ក្រៅនេះ ទម្លាយរន្ធទី ៦ ហើយ ទើបចាប់យកតាមរន្ធដែល ដែលវាចូលទៅនោះឯង , បណ្ដាទ្វារទាំង ៦ នោះ សូម លោកម្ចាស់បិទទ្វារទាំង ៥ នោះហើយ ផ្ដើមតាំងកម្មនេះទុក មនោទ្វារ ” ។ ព្រះបោឋិលៈនោះពោលថា “ នៃអ្នកសប្បុ-រស ហេតុមានប្រមាណប៉ុណ្ណោះមែនពិត ” ហើយទើបញុំាង ញាណឲ្យស្ទុងចុះក្នុងករជកាយ ប្រារព្ធសមណធម៌ ។

## [ ផ្លូវចម្រើន និង ផ្លូវវិនាសទៅនៃបញ្ញា ]

ព្រះសាស្ដា ទ្រង់គង់នៅត្រង់ទីបំផុតប្រមាណ ១២០ យោជន៍ ទ្រង់ឃើញភិក្ខុនោះហើយ ទ្រង់ព្រះតម្រិះថា “ភិក្ខុ

នោះជាអ្នកមានបញ្ញា ( ទូលំទូលាយ ) ដូចជាផែនដីដោយប្រការណា , ការដែលភិក្ខុនោះ តម្កល់ខ្លួនទុកដោយប្រការនោះ រមែងគួរ " ។ លុះទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាត្រាស់នឹងភិក្ខុនោះ ត្រាស់ព្រះគាថានេះថា :-

មគ្គវគ្គវណ្ណនា រឿងព្រះពោឋិលត្ថេរ

៥ យោគា វេ ជាយតី ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធាបថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។

ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្ដីវិនាសប្រាជ្ញារមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញាដឹងការប្រកប និងការមិនប្រកបទាំងពីរនេះថា ជាគន្លងនៃសេចក្ដីចម្រើន និងសេចក្ដីវិនាសហើយ ប្រាជ្ញាចម្រើនឡើងដោយប្រការណា គួរតម្កល់ខ្លួនទុកដោយប្រការនោះ ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **យោគា** សេចក្ដីថា ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃក្នុងអារម្មណ៍ ៣៨ ។

ពាក្យថា **ភូរិ** នោះ ជាឈ្មោះនៃបញ្ញាដ៏ទូលំទូលាយដូចជាផែនដី ។ ការវិនាស ឈ្មោះថា ការអស់ទៅ ។

ពីរបទថា **ឯតំ ទ្វេធា បថំ** គឺនូវការប្រកប និងការមិនប្រកបនោះ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

បាទព្រះគាថាថា **ភវាយ វិភវាយ ច** គឺការចម្រើន និងការមិនចម្រើន ។

បទថា **តថត្តានំ** សេចក្ដីថា បណ្ឌិតគួរតម្កល់ខ្លួនទុកដោយប្រការដែលបញ្ញា ពោលគឺ ភូរិនេះចម្រើនឡើងបាន។

ក្នុងកាលចប់ទេសនា ព្រះបោឋិលៈតាំងនៅក្នុងព្រះអរហត្ត ៕ល៚

( រឿងព្រះពោឋិលត្ថេរ ចប់ )

8888888888888888888888888888888

## ៦ រឿងព្រះថេរៈចាស់

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់ច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា “ **វនំ ឆិន្ទថ** ” ជាដើម ។

## [ ពួកកុដុម្ពិកលះបង់យកវាសចេញបួស ]

បានឮថា ភិក្ខុទាំងនោះកាលនៅជាគ្រហស្ថជាកុដុម្ពិក ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន នៅក្នុងក្រុងសាវត្ថី ជាសម្លាញ់នឹងគ្នា ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ គិតថា “ ពួកយើងជាមនុស្សចាស់ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់ពួកយើង ” ដូច្នេះហើយ ទូលសូមព្រះសាស្តាបួស , ប៉ុន្តែព្រោះភាពជាមនុស្សចាស់ មិនអាចរៀនធម៌បាន ទើបប្រើគេឲ្យកសាងបណ្ណសាលាក្នុងទីបំផុតវិហារ ហើយនៅរួមគ្នា , សូម្បីកាលត្រាច់ទៅបិណ្ឌបាត ទៅកាន់ផ្ទះរបស់កូន និងប្រពន្ធដោយច្រើន ហើយឆាន់ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

## [ ពួកភិក្ខុចាស់យំសោកចំពោះឧបាសិកា ]

បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូប មានកិរិយាចាស់ ឈ្មោះនាងមធុរបាណិកា ( ស្ត្រីមានថ្វីដៃខាងធ្វើម្ហូបឆ្ងាញ់ )

នាងមានឧបការៈដល់ភិក្ខុទាំងនោះ ព្រោះហេតុដូច្នោះ ភិក្ខុទាំងអស់កាន់យកអាហារ ដែលខ្លួនបានហើយទៅកាន់ផ្ទះរបស់នាង ។ ចំណែកនាងក៏ប្រគេនសូបៈ និងព្យញ្ជនៈ ( ម្ហូបទឹក និងម្ហូបគោក ) តាមដែលខ្លួនចាត់ចែងទុក ។

នាងត្រូវអាពាធមួយប្រភេទពាល់ត្រូវហើយ បានធ្វើកាលកិរិយាទៅ ។ គ្រានោះ ព្រះថេរៈចាស់ៗ ទាំងនោះប្រជុំគ្នាក្នុងបណ្ណសាលារបស់ព្រះថេរៈ អ្នកជាសម្លាញ់ឱបកគ្នាយំរៀបរាប់ថា “ ឧបាសិកាអ្នកមានថ្វីដៃខាងធ្វើម្ហូបឆ្ងាញ់ស្លាប់ហើយ ” កាលភិក្ខុទាំងឡាយស្ទុះចូលទៅអំពីជុំវិញ ហើយ សួរថា “ ម្នាលអាវុសោ ហេតុដូចម្តេច បានជាអាវុសោឯងយំ ?” ក៏ពោលថា “ បពិត្រលោកម្ចាស់ដ៏ចម្រើន ភរិយាចាស់នៃសម្លាញ់របស់ពួកយើងស្លាប់ , នាងជាស្ត្រីមានឧបការៈច្រើនដល់ពួកយើង , ឥឡូវនេះពួកយើង

នឹងបានស្ត្រីបែបនោះអំពីណាទៀត , ព្រោះហេតុដូច្នោះទើបពួកយើងយំ " ។

## [ ព្រះសាស្ដាត្រាស់កាកជាតកដល់ភិក្ខុទាំងឡាយ ]

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភា ។ ព្រះសាស្ដាស្ដេចមកហើយ ត្រាស់សួរថា " ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ ?" កាលភិក្ខុទាំងនោះក្រាបទូលថា " ដោយកថាឈ្មោះនេះ " ក៏ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ , សូម្បីក្នុងកាលមុន កាលនាងមធុរបាណិកានោះកើតក្នុងកំណើតក្អែក ត្រាច់ទៅក្បែរឆ្នេរសមុទ្រ ត្រូវរលកសមុទ្រ ( ទាញ ) ចូលទៅកាន់សមុទ្រឲ្យស្លាប់ហើយ ភិក្ខុទាំងនោះ ( កើត ) ជាក្អែកខ្សឹកខ្សួលហើយ គិតថា ពួកយើងនឹងនាំមេក្អែកនោះទៅ , ទើបនាំគ្នាបាចមហាសមុទ្រដោយចំពុះមាត់ទាំងឡាយ ដល់លំបាកហើយ " ។ ទ្រង់នាំអតីតនិទានមកហើយ ត្រាស់កាកជាតកឲ្យពិស្ដារថា :-

( ពួកក្អែកពោលថា ) អើ ចង្កាយើងក៏រោយ មាត់យើង



ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល ។

ហើយត្រាស់ហៅភិក្ខុទាំងនោះមក ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអាស្រ័យព្រៃ គឺរាគៈ ទោសៈ និងមោហៈ ទើបដល់នូវទុក្ខនេះ , ការដែលអ្នកទាំងឡាយកាត់ព្រៃនោះចេញ គួរ , ពួកអ្នកនឹងជាអ្នកផុតទុក្ខបានដោយអាការយ៉ាងនេះ ” ហើយទ្រង់ភាសិតគាថាទាំងនេះថា :-

៦ វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី ភយំ
ឆេត្វា វនំ វនថញ្ច និព្វនា ហោថ ភិក្ខវោ ។
យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពន្ធមនោ វ តាវ សោ
វច្ឆោ ខីរបកោវ មាតរិ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ ( ព្រោះ ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង



ឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេសដូចជាព្រៃឡើយ ព្រោះថា កិលេសដូចដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារីដរាបណា នរជននោះឯង តែងមានចិត្តជាប់ចំពោះក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេដរាបនោះ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **មា វុក្ខំ** សេចក្តីថា ក៏កាលព្រះសាស្តាត្រាស់ថា “ អ្នកចូរកាត់ព្រៃ , ភិក្ខុទាំងនោះ

ទើបតែបួសហើយអស់កាលមិនយូរ ការគិតក្នុងកាលជាអ្នកប្រាថ្នានឹងកាត់ដើមឈើ រមែងកើតឡើងថា " ព្រះសាស្ដាទ្រង់ញុំាងយើងទាំងឡាយ ឲ្យកាន់យកគ្រឿងសស្ត្រាទាំង-ឡាយ មានកាំបិតជាដើមកាត់ព្រៃ " កាលបើដូច្នោះ ព្រះសាស្ដាកាលនឹងទ្រង់ហាមភិក្ខុទាំងនោះថា " តថាគតពោល

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

ពាក្យនោះសំដៅយកព្រៃ គឺកិលេស មានរាគៈជាដើម មិនមែនសំដៅយកដើមឈើទេ " ទើបត្រាស់ថា " កុំកាត់ដើមឈើ " ។

បទថា ***វនតោ*** សេចក្ដីថា ភ័យអំពីសត្វសាហាវមានសីហៈជាដើម រមែងកើតអំពីព្រៃជាប្រក្រតី យ៉ាងណាសូម្បីភ័យ មានភ័យអំពីជាតិជាដើម រមែងកើតអំពីព្រៃ គឺកិលេស ដូច្នេះដែរ ។

ពីរបទថា ***វនំ វនថញ្ច*** នេះ គប្បីជ្រាបការវិនិច្ឆ័យថា ដើមឈើធំឈ្មោះថាព្រៃ , ឈើតូចៗ ដែលតាំងនៅក្នុងព្រៃ

នោះ ឈ្មោះថា ឈើតាំងនៅក្នុងព្រៃ ន័យម្យ៉ាងទៀត ដើមឈើដែលកើតមុន ឈ្មោះថា ព្រៃ ដែលកើតតៗ គ្នាមក ឈ្មោះថា ពួកឈើតាំងនៅក្នុងព្រៃ ( យ៉ាងណា ), កិលេសដែលឲ្យផលក្នុងបច្ចុប្បន្ន ឈ្មោះថា កិលេសដូចជាដើមឈើដុះក្នុងព្រៃ , ន័យម្យ៉ាងទៀត កិលេសដែលកើតមុន ឈ្មោះថា កិលេសដូចជាព្រៃ ដែលកើតតៗ មក ឈ្មោះថា ដូចជាដើមឈើដែលដុះក្នុងព្រៃដូច្នោះដែរ ។ ក៏កិលេសជាតិ



សូម្បីទាំងពីរយ៉ាងនោះ ព្រះយោគាវចរគប្បីកាត់ដោយញាណដែលសម្បយុត្តដោយមគ្គទី ៤ , ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា “ ចូរកាត់កិលេសដូចជាព្រៃ និងដូចជាដើមឈើដែលដុះក្នុងព្រៃ ” ។

ពីរបទថា **និព្វនា ហោថ** ប្រែថា អ្នកទាំងឡាយ ចូរជាអ្នកមិនមានកិលេសចុះ ។

ពីរបទថា **យាវញ្ហិ វនថោ** សេចក្ដីថា កិលេសដូចជាដើមឈើ ដែលដុះក្នុងព្រៃរបស់នរជននោះ សូម្បីមានប្រមាណតិចក៏ដោយ បើកាត់មិនដាច់ក្នុងពួកនារីជរាបណា, នរជននោះក៏ដូចជាកូនគោនៅកំពុងបៅដោះ មានចិត្តប្រតិព័ទ្ធ គឺមានចិត្តជាប់ជំពាក់នៅនឹងមេជរាបនោះ ។

ក្នុងវេលាចប់ទេសនា ព្រះថេរៈចាស់ទាំងនោះតាំងនៅក្នុងសោតាបត្តិផល , ទេសនាបានមានប្រយោជន៍ដល់បុគ្គលអ្នកប្រជុំគ្នាហើយ ដូច្នោះ ៕

( រឿងព្រះថេរៈចាស់ ចប់ )

8888888888888888888888888

## ៧ រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្រ

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា “ **ឧច្ឆិន្ទ** ” ជាដើម ។

## [ មាណពបួសហើយបានកម្មដ្ឋានមិនមិនត្រូវអធ្យាស្រ័យ ]

បានឮថា បុត្ររបស់ជាងមាសម្នាក់ មានរូបស្រស់សង្ហា បួសក្នុងសម្នាក់ព្រះសារីបុត្រ ។

ព្រះសារីបុត្រគិតថា “កំលោះៗ ទាំងឡាយ មានរាគៈក្រាស់ ” ហើបានឲ្យកម្មដ្ឋានដល់ភិក្ខុនោះ ដើម្បីប្រឆាំងតបចំពោះរាគៈ , ប៉ុន្តែ កម្មដ្ឋាននោះមិនជាទីសប្បាយដល់ភិក្ខុនោះ , ព្រោះហេតុនោះ ភិក្ខុនោះចូលទៅកាន់ព្រៃ ហើយព្យាយាមអស់ ៣ ខែ មិនបាននូវគុណ ត្រឹមជាអ្នកមានចិត្តមានអារម្មណ៍មូលតែមួយ ទើបមកកាន់សម្នាក់ព្រះថេរៈវិញ

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

កាលព្រះថេរៈពោលថា “ អាវុសោ កម្មដ្ឋានមកប្រាកដដល់អ្នកហើយឬ ?” ក៏ប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះព្រះថេរៈពោលនឹងភិក្ខុនោះថា “ ការរួញរាដោយគំនិតថា កម្មដ្ឋានមិនសម្រេច ដូច្នេះ រមែងមិនសមគួរ ” ហើយប្រាប់កម្មដ្ឋាននោះឯងឲ្យក្រៃលែងឡើងទៀត ហើយបានឲ្យដល់ភិក្ខុនោះ ។ ក្នុងវារៈទី ២ ភិក្ខុនោះក៏មិនអាចញ៉ាំងគុណវិសេសអ្វីៗ ឲ្យកើតឡើងបាន ក៏ត្រឡប់មកប្រាប់ព្រះថេរៈ។ សូម្បីព្រះថេរៈក៏ប្រាប់កម្មដ្ឋាននោះឯង ធ្វើឲ្យមានហេតុ ឲ្យមានឧបមា ។ ភិក្ខុនោះ ក៏មកប្រាប់កម្មដ្ឋាន ដែលមិនសម្រេចម្តងទៀត ។ ព្រះថេរៈគិតថា “ ភិក្ខុអ្នកធ្វើសេចក្តីព្យាយាម រមែងដឹងនូវនីវរណធម៌ទាំងឡាយ មានការពេញចិត្តក្នុងកាមជាដើម ដែលមានក្នុងខ្លួនថា មាន ហើយដែលមិនមានក្នុងខ្លួនថា មិនមាន , ក៏ភិក្ខុនេះ ជាអ្នកធ្វើសេចក្តីព្យាយាម មិនមែនជាអ្នកមិនធ្វើ , ជាអ្នកបដិបត្តិ មិនមែន

ជាអ្នកមិនបិបត្តិ , ប៉ុន្តែ យើងមិនដឹងអធ្យាស្រ័យរបស់ភិក្ខុនេះ , ភិក្ខុនេះនឹងជាអ្នកដែលព្រះពុទ្ធគប្បីណែនាំ ទើបនាំ

មគ្គវគ្គវណ្ណនា រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្រ

ភិក្ខុនោះចូលទៅគាល់ព្រះសាស្តា ក្នុងវេលារសៀល ហើយក្រាបទូលការប្រព្រឹត្តទៅទាំងអស់នោះថា " បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ , ខ្ញុំព្រះអង្គឲ្យកម្មដ្ឋាននេះដល់ភិក្ខុនេះ ដោយហេតុនេះ " ។

## [ ព្រះសាស្តាប្រទានកម្មដ្ឋាន ដែលសមគួរដល់ភិក្ខុនោះ ]

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់ព្រះថេរៈនោះថា " ដែលឈ្មោះថា អាសយានុសយញ្ញាណនោះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ អ្នកបំពេញបារមីហើយ ញ៉ាំងមុឺនលោកធាតុឲ្យរញ្ជួយហើយ ដល់ភាពជាព្រះសព្វញ្ញូ " ទ្រង់ក៏រំពឹងថា " ភិក្ខុនេះបួសអំពីត្រកូលណាហ្ន៎ " ទើបជ្រាបថា អំពីត្រកូលជាងមាស , ទ្រង់បានពិចារណាមើលនូវអត្តភាព

ដែលកន្ទងហើយ ទ្រង់ឃើញអត្តភាព ៥០០ របស់ភិក្ខុនោះ ដែលកើតតែក្នុងត្រកូលជាងមាសដោយលំដាប់ ហើយទ្រង់ព្រះតម្រិះថា " ភិក្ខុកំលោះនេះ ធ្វើជាងមាស អស់កាលយូរ រំលាយតែមាសដែលមានពណ៌ក្រហមតែម្យ៉ាង ដោយ

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

គិតថា យើងនឹងធ្វើជាផ្កាកណិការ និងផ្កាឈូកជាដើម ។ អសុភបដិកូលកម្មដ្ឋានមិនសមគួរដល់ភិក្ខុកំលោះនេះ , កម្មដ្ឋានដែលជាទីរីករាយប៉ុណ្ណោះ ទើបជាកម្មដ្ឋានជាទីសប្បាយដល់ភិក្ខុនេះ " ទើបត្រាស់ថា " ម្នាលសារីបុត្រ អ្នកនឹងឃើញភិក្ខុដែលអ្នកឲ្យកម្មដ្ឋាន លំបាកហើយអស់ ៤ ខែ សម្រេចអរហត្តក្នុងកាលខាងក្រោយភត្តថ្ងៃនេះឯង អ្នកទៅចុះ " ដូច្នេះហើយ ទ្រង់បញ្ជូនព្រះថេរៈទៅ ទ្រង់និមិត្តផ្កាឈូកមាសប្រមាណប៉ុនកងចក្រដោយឫទ្ធិ ហើយទ្រង់ធ្វើឲ្យដូចជាបញ្ចេញនូវដំណក់ទឹកតាមត្របក និងទង ហើយបានប្រទានឲ្យភិក្ខុនោះ ដោយព្រះតម្រាស់ថា " ម្នាលភិក្ខុ

យកចុះ អ្នកចូរកាន់យកផ្កាឈូកនេះទៅដាក់លើគំនរដីខ្សាច់ក្នុងទីបំផុតវិហារ ចូរអង្គុយពត់ភ្នែនខាងមុខផ្កាឈូកនោះ ហើយធ្វើបរិកម្មថា **លោហិតកំ លោហិតកំ** “ ពណ៌ក្រហម ពណ៌ក្រហម ” ។ កាលភិក្ខុនោះទទួលយកផ្កាឈូក អំពីព្រះហស្តរបស់ព្រះសាស្តាភ្លាម ចិត្តក៏ជ្រះថ្លា , ភិក្ខុនោះទៅកាន់ទីបំផុតវិហារ ពូនដីខ្សាច់ឡើងហើយ អង្គុយពត់ភ្នែន



ខាងមុខផ្កាឈូក ហើយបរិកម្មថា **លោហិតកំ លោហិតកំ** ។

## [ ភិក្ខុនោះសម្រេចគុណវិសេស ]

គ្រានោះ នីវរណៈទាំងឡាយរបស់លោកស្ងប់រម្ងាប់ ហើយក្នុងខណៈនោះឯង ឧបចារជ្ឈានក៏កើតឡើង ។ លោកញ៉ាំងឈានឲ្យកើតឡើង ក្នុងលំដាប់នៃឧបចារជ្ឈាននោះ ឲ្យដល់ភាពជាអ្នកជំនាញដោយអាការ(១) ៥ អង្គុយដូចដើមនោះឯង ហើយសម្រេចឈានទាំងឡាយ មានទុតិយជ្ឈានជាដើម ហើយអង្គុយចូលឈានក្នុងចតុត្ថជ្ឈានដ៏ស្ងាត់ ។

ព្រះសាស្ដាទ្រង់ជ្រាបថា ឈានទាំងឡាយកើតឡើង ដល់ភិក្ខុនោះហើយ ទ្រង់ពិចារណាមើលថា ភិក្ខុនេះនឹងអាច ញ៉ាំងគុណវិសេសដ៏ក្រៃលែងឲ្យកើតឡើង តាមធម្មតារបស់ ខ្លួនឬហ្ន៎ , ទ្រង់ជ្រាបថា នឹងមិនអាច ហើយទ្រង់អធិដ្ឋាន ថា " ផ្កាឈូកនោះចូរស្វិតទៅ " ផ្កាឈូកនោះក៏ស្វិត មាន

---

( ១ ) អាការ ៥ យ៉ាងនោះ គឺ **អាវជ្ជន** ការនឹក , **សមាបជ្ជន** ការចូល , **វុដ្ឋាន** ការចេញ , **អធិដ្ឋាន** ការអធិដ្ឋាន , **បច្ចវេក្ខណៈ** ការពិចារណា ។

***ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ***

ពណ៌ខ្មៅ ដូចជាផ្កាឈូកដែលត្រូវគេឈ្លីដោយដៃ ដូច្នោះ ។ ភិក្ខុនោះចេញចាកឈានហើយ សម្លឹងមើលផ្កាឈូកនោះ ឃើញអនិច្ចលក្ខណៈថា " ហេតុដូចម្ដេចហ្ន៎ ផ្កាឈូកនេះ ត្រូវជរាពាល់ត្រូវហើយទើបប្រាកដបាន កាលអនុបាទិន្នក-សង្ខារត្រូវជរាគ្របសង្កត់យ៉ាងនេះ ដូច្នេះ មិនចាំបាច់ពោលថ្វីចំពោះឧបាទិន្នកសង្ខារ , ជរាគង់នឹងគ្របសង្កត់ឧបាទិន្នក-សង្ខារនេះ " ។ អនិច្ចលក្ខណៈដែលភិក្ខុនោះឃើញហើយ ,

ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ក៏ឈ្មោះថា ភិក្ខុនោះឃើញហើយដែរ ។ ភព ៣ ប្រាកដដល់ភិក្ខុនោះដូចជាភ្លើងឆេះទូទៅហើយ និងដូចជាសាកសពដែលបុគ្គលចងត្រង់-ក ។

ក្នុងខណៈនោះ កុមារតូចៗ ទាំងឡាយចុះកាន់ស្រះមួយ ក្នុងទីមិនឆ្ងាយអំពីភិក្ខុនោះ កាច់ផ្កាកុមុទទាំងឡាយហើយធ្វើឲ្យជាគំនរលើគោក ។ ភិក្ខុនោះ សម្លឹងឃើញផ្កាកុមុទទាំងឡាយលើគោក និងក្នុងទឹក ។

គ្រានោះ ផ្កាកុមុទក្នុងទឹករីកស្រស់ស្អាត ប្រាកដដល់ភិក្ខុនោះ ដូចជាបង្ហូរទឹកចេញ , ផ្កាកុមុទក្រៅនេះស្វិតជុំវិញ



ហើយត្រង់ចុងៗ ។ ភិក្ខុនោះ ឃើញអនិច្ចលក្ខណៈជាដើមច្បាស់ឡើងថា " ជរារមែងពាល់ត្រូវនូវអនុបាទិន្នកសង្ខារយ៉ាងនេះ , ដូចម្តេចនឹងមិនពាល់ត្រូវនូវឧបាទិន្នកសង្ខារ ។

## [ ចូរកាត់ចំណងចម្រើនការស្ងាប់ ]

ព្រះសាស្ដា ទ្រង់ជ្រាបថា " ឥឡូវនេះ កម្មដ្ឋានប្រាកដដល់ភិក្ខុនេះហើយ ទ្រង់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់បញ្ចេញព្រះរស្មីទៅ ។ ព្រះរស្មីនោះប៉ះមុខភិក្ខុនោះ ។ កាលលោកពិចារណាថា " នេះជាអ្វីហ្ន៎ " ព្រះសាស្ដាប្រាកដដល់ភិក្ខុនោះ ហាក់ដូចជាទ្រង់មកប្រថាប់នៅចំពោះមុខៗ ភិក្ខុនោះក្រោកឡើង ហើយផ្គងអញ្ជលី ។ គ្រានោះ ព្រះសាស្ដាទ្រង់កំណត់ធម៌ជាទីសប្បាយដល់ភិក្ខុនោះហើយ ក៏ត្រាស់ព្រះគាថានេះថា :-

៧ ឧច្ឆិន្ទ សិនេហមត្តនោ
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

អ្នកចូរដកសេចក្ដីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គលដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយ

ដែ អ្នកចូរបណ្តុះនូវផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសម្តែងទុកហើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឧច្ឆិន្ទ** គឺចូរកាត់ដោយអរហត្តមគ្គ ។ បទថា **សារទិកំ** បានដល់ ដែលកើតហើយក្នុងសារទកាល ។

បទថា **សន្តិមគ្គំ** គឺនូវផ្លូវដែលមានអង្គ ៨ ដែលញុំាងសត្វឲ្យដល់ព្រះនិព្វាន ។ បទថា **ព្រូហយ** គឺចូរចម្រើន ។ បទថា **និព្វានំ** សេចក្តីថា ព្រោះព្រះនិព្វាន ព្រះសុគតទ្រង់សម្តែងហើយ , ព្រោះហេតុនោះ អ្នកទាំងឡាយចូរចម្រើនផ្លូវនៃព្រះនិព្វាននោះ ។

វេលាចប់ទេសនា ភិក្ខុនោះតាំងនៅក្នុងអរហត្ត ។៘

( រឿងសទ្ធិវិហារិករបស់ព្រះសារីបុត្រ ចប់ )

8888888888888888888888888888888888

## ៨ រឿងឈ្មួញឈ្មោះមហាធនពាណិជ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញដែលមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសានេះថា " **ឥធ វស្សំ** " ជាដើម ។

## [ ឈ្មួញមិនដឹងសេចក្តីស្លាប់ដែលនឹងមកដល់ខ្លួន ]

បានឮថា ឈ្មួញឈ្មោះមហាធនពាណិជនោះ ញុំាងរទេះ ៥០០ ឲ្យពេញដោយសំពត់ដែលជ្រលក់ដោយផ្កាដកគាំ ចេញអំពីក្រុងពារាណសី ហើយមកកាន់ក្រុងសាវត្ថី ដើម្បីជួញ ។ មហាធនពាណិជនោះមកដល់ឆ្នេរស្ទឹងហើយ គិតថា " ថ្ងៃស្អែកទើបយើងឆ្លងស្ទឹង " ដោះរទេះហើយស្នាក់នៅក្បែរឆ្នេរស្ទឹងនោះឯង ។

មហាមេឃតាំងឡើងហើយ បង្អុរចុះមកមួយយប់ទល់ភ្លឺ ។ ស្ទឹងពេញទៅដោយទឹកភ្លៀង ហើយតាំងនៅអស់

៧ ថ្ងៃ ។ រីឯក្នុងនគរ ពួកជនក៏លែងនក្ខត្តឫក្សអស់ ៧ ថ្ងៃ ។ កិច្ចដោយសំពត់ដែលជ្រលក់ ដោយផ្កាដកគាំមិនមាន ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ទើបឈ្មួញឈ្មោះមហាធនពាណិជនោះ គិតថា " ការយឺតយូរនឹងមាន, យើងនឹងធ្វើការងាររបស់យើងនៅទីនេះរហូតអស់រដូវភ្លៀង " ។

ព្រះសាស្តា ស្តេចត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ទ្រង់ជ្រាបវារៈចិត្ត ( ការគិត ) របស់ឈ្មួញនោះហើយ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ , ព្រះអានន្ទទូលសួរហេតុនៃការញញឹមនោះ ទើបត្រាស់ថា " ម្នាលអានន្ទ អ្នកឃើញឈ្មួញដែលមានទ្រព្យច្រើនទេ ?" ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

ព្រះសា. ឈ្មួញនោះមិនដឹងអន្តរាយនៃជីវិតរបស់ខ្លួន ទើបតាំងចិត្តដើម្បីលក់វត្ថុនៅទីនេះអស់ឆ្នាំនេះ ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន អន្តរាយនឹងមានដល់ឈ្មួញនោះឬ ?

ព្រះសាស្តាត្រាស់ថា " អើ អានន្ទ ឈ្មួញនោះរស់នៅបាន ៧ ថ្ងៃទៀតប៉ុណ្ណោះ នឹងតាំងនៅក្នុងមាត់មច្ចុ គឺសេចក្តីស្លាប់ " ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំង

*មគ្គវគ្គវណ្ណនា រឿងឈ្មួញឈ្មោះមហាធនពាណិជ*

នេះថា :-

សេចក្តីព្យាយាម ជាគ្រឿងញុំាងកិលេសឲ្យក្តៅទូទៅ បុគ្គលគប្បីធ្វើក្នុងថ្ងៃនេះឯង , នរណាទៅនឹងដឹងបានថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក ព្រោះថា ការបណ្តោះបណ្តែ ( គេចវេះ ) អំពីសេចក្តីស្លាប់ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។

មុនីអ្នកស្ងប់ រមែងហៅបុគ្គលអ្នកមានប្រក្រតីនៅយ៉ាងនោះ មានសេចក្តីព្យាយាមមិនខ្ជិលច្រអូស

អស់ថ្ងៃ និងយប់នោះឯងថា អ្នកមានរាត្រីមួយដ៏ចម្រើន ។

អានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅប្រាប់ឈ្មួញនោះ ។

ព្រះសា. ម្នាលអានន្ទ អ្នកស្និទ្ធស្នាលនឹងឈ្មួញនោះដូច្នេះ អ្នកចូរទៅចុះ ។

ព្រះថេរៈត្រាច់ទៅបិណ្ឌបាត ត្រង់ទីដែលឈ្មួញនោះ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

ចតរទេះ ។ ឈ្មួញនោះទទួលព្រះថេរៈដោយអាហារ ។ គ្រានោះ ព្រះថេរៈក៏ពោលទៅកាន់ឈ្មួញនោះថា “ នែ អ្នកដ៏ចម្រើន អ្នកនឹងនៅទីនេះប៉ុន្មានថ្ងៃទៀត ?” ។

ឈ្មួញ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមកអំពីទីឆ្ងាយ បើនឹងទៅកាន់ទីដទៃទៀត ការយឺតយូរនឹងមាន , ខ្ញុំនឹងនៅទីនេះអស់ឆ្នាំនេះ លក់វត្ថុ ( អស់ ) ហើយនឹងទៅ ។

ព្រះអានន្ទ. នែ ឧបាសក អន្តរាយនៃជីវិតដឹងបាន ដោយលំបាក ការធ្វើនូវសេចក្តីមិនប្រមាទ ទើបគួរ ។

ឈ្មួញ.បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តីអន្តរាយ នឹងមានឬ ?

ព្រះអានន្ទ. អើ ឧបាសក ជីវិតរបស់អ្នកនឹងប្រព្រឹត្ត ទៅបាន ៧ ថ្ងៃទៀតប៉ុណ្ណោះ ។

ឧបាសកនោះមានចិត្តតក់ស្លុត ហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានអស់ ៧ ថ្ងៃ ហើយ ទទួលបាត្រដើម្បីប្រយោជន៍ដល់ការអនុមោទនា ។

## [ មនុស្សល្ងង់រមែងមិនដឹងអន្តរាយនៃជីវិត ]

គ្រានោះ ព្រះសាស្តា កាលនឹងទ្រង់ធ្វើអនុមោទនា ដល់ឧបាសកនោះ ទ្រង់ក៏ត្រាស់ថា “ ម្នាលឧបាសក ដែល ឈ្មោះថា បណ្ឌិត បើគិតថា យើងនឹងនៅទីនេះអស់រដូវ ទាំងឡាយ មានរដូវភ្លៀងជាដើម នឹងប្រកបការងារនេះផង

រមែងមិនគួរ, គួរគិតដល់អន្តរាយនៃជីវិតរបស់ខ្លួនប៉ុណ្ណោះ"
ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :-

**៨ ឥធ វស្សំ វសិស្សាមិ   ឥធ ហេមន្តគិម្ហិសុ**
**ឥតិ ពាលោ វិចិន្តេតិ   អន្តរាយំ ន ពុជ្ឈតិ ។**

អញនឹងនៅទីនេះអស់វស្សានរដូវ អញនឹងនៅទីនេះអស់ហេមន្តរដូវ និងគិម្ហរដូវ ជនពាលរមែងគិតខុស ដូច្នេះ តែងមិនដឹងច្បាស់សេចក្តីអន្តរាយនៃជីវិតឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឥធ វស្សំ** សេចក្តីថា យើងនឹងធ្វើការងារនេះផងៗ ក្នុងទីនេះអស់រដូវភ្លៀង ៤ ខែ។ បទថា **ហេមន្តគិម្ហិសុ** សេចក្តីថា ជនពាលអ្នកមិន

ដឹងប្រយោជន៍ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយ-ភព រមែងគិតយ៉ាងនេះថា “ យើងនឹងធ្វើការងារនេះផងៗ ក្នុងទីនេះឯងអស់ ៤ ខែ សូម្បីក្នុងរដូវរងា និងរដូវក្តៅ ។

បទថា **អន្តរាយំ** សេចក្តីថា រមែងមិនដឹងអន្តរាយនៃជីវិតរបស់ខ្លួនថា “ យើងនឹងស្លាប់ក្នុងកាល ក្នុងប្រទេស ឬក្នុងវ័យឯណោះ ” ។

ក្នុងកាលចប់ទេសនា ឈ្មួញនោះតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាជាគុណជាតិមានប្រយោជន៍ សូម្បីដល់បរិស័ទដែលប្រជុំគ្នាហើយក្នុងទីនោះ ។ ចំណែកឈ្មួញនោះជូនពុទ្ធដំណើរព្រះសាស្តាទៅហើយ ត្រឡប់មកដេកលើគ្រែដោយគិតថា “ រោគទាំងឡាយ មានរោគក្នុងក្បាលជាដើម នឹងកើតឡើងដល់យើង ” ដេកហើយ ដោយអាការនោះឯង ធ្វើកាលកិរិយាហើយកើតក្នុងតុសិតវិមាន ៕

( រឿងឈ្មួញឈ្មោះមហាធនពាណិជ ចប់ )

888888888888888888888888888888888888888888

# ៩ រឿងនាងកិសាគោតមី

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតជន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា “ **តំ បុត្តបសុសម្មត្តំ** ” ជាដើម ។

## [ សេចក្ដីជាស្ងាប់របស់ទៀង ]

រឿងខ្ញុំព្រះករុណាបានពោលឲ្យពិស្ដារហើយ ក្នុងការពណ៌នាព្រះគាថាក្នុងសហស្សវគ្គថា :-

បុគ្គលណារស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះ
និព្វាន ការរស់នៅសូម្បីតែមួយថ្ងៃរបស់លោកអ្នក
ឃើញផ្លូវព្រះនិព្វានប្រសើរជាង ។

ក្នុងគ្រានោះ ព្រះសាស្ដាត្រាស់ថា ម្នាលនាងគោតមី គ្រាប់ស្ពៃប្រមាណមួយក្ដាប់ នាងរកបានហើយឬ ?

កិសាគោតមី. បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ , (ព្រោះ) ក្នុងស្រុកទាំងអស់ អ្នកដែលស្លាប់ច្រើនជាងអ្នកដែលរស់នៅ ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ

## [ មច្ចុរមែងនាំនរៈទៅដូចអន្លង់ទឹកធំ ]

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់នាងកិសាគោតមីថា " ម្នាលនាងកិសាគោតមី នាងយល់ថា បុត្ររបស់យើងប៉ុណ្ណោះស្លាប់ហើយ , សេចក្តីស្លាប់នេះជាធម៌ដ៏ទៀងទាត់របស់សត្វទាំងពួង ព្រោះមច្ចុរាជនាំសត្វដែលមានអធ្យាស្រ័យមិនទាន់ពេញប៉ុណ្ណោះ ចូលទៅកាន់មហាសមុទ្រ គឺអបាយ ដូចជំនន់ដ៏ធំ ដូច្នោះ " ដូច្នោះហើយ កាលនឹងទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា :-

**៩ តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នក

ស្រវឹងជ្រប់ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងនោះៗ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **តំ បុត្តបសុសម្មត្តំ**

មគ្គវគ្គវណ្ណនា រឿងនាងកិសាគោតមី

សេចក្ដីថា នរៈអ្នកបានបុត្រ និងបសុសត្វទាំងឡាយដែលដល់ ព្រមដោយរូប និងកម្លាំងជាដើមហើយ ស្រវឹងគឺប្រមាទ ហើយក្នុងបុត្រ និងបសុសត្វទាំងឡាយយ៉ាងនេះថា “ បុត្ររបស់យើងមានរូបស្រស់ មានកម្លាំងបរិបូណ៌ឈ្លាសវៃ ជាអ្នកអាចក្នុងកិច្ចការទាំងពួង , គោរបស់យើងមានរូបល្អ ប្រាសចាករោគ អាចនាំរបស់ទៅបានច្រើន , គោរបស់យើងមានទឹកដោះច្រើន ។

បទថា **ព្យាសត្តមនសំ** សេចក្ដីថា ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ហើយ ( ក្នុងអារម្មណ៍ ) ព្រោះបាន

បរិក្ខារទាំងឡាយ មានមាស និងប្រាក់ជាដើម ឬសមណ-បរិក្ខារទាំងឡាយ មានបាត្រ និងចីវរជាដើមហើយ ប្រាថ្នាឲ្យក្រៃលែងឡើងជាងនោះ ។ មយ៉ាងទៀត ឈ្មោះថា អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ព្រោះជាប់ស្អិតនៅក្នុងអារម្មណ៍ទាំងឡាយ មានអារម្មណ៍ដែលគប្បីដឹងដោយចក្ខុជាដើម ឬសមណបរិក្ខារទាំងឡាយ មានប្រការដូចពោលហើយ ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

ពីរបទថា **សុត្តំ គាមំ** បានដល់ ពួកសត្វអ្នកចូលដល់ការលក់ ។

បទថា **មហោឃោវ** ជាដើម សេចក្តីថា ជំនន់មហានទីដ៏ធំ ទាំងជម្រៅ ទាំងទំហំ នាំអ្នកស្រុកបែបនោះទាំងអស់ទៅ ដោយហោចទៅសូម្បីតែសុនខមិនឲ្យសេសសល់យ៉ាងណា, មច្ចុ រមែងនាំនរៈអ្នកមានប្រការដូចពោលហើយទៅ ដូច្នោះ ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមីតាំងនៅក្នុង សោតាបត្តិផល ។ ទេសនាជាគុណជាតិប្រព្រឹត្តទៅ មួយ អន្លើដោយប្រយោជន៍ ដល់បរិស័ទអ្នកដល់ព្រមហើយ ដោយប្រការ ដូច្នេះ ។៚

( រឿងនាងកិសាគោតមី ចប់ )

8888888888888888888888888888

# ១០ រឿងនាងបដាចារា

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ នាងបដាចារា ត្រាស់ព្រះធម្មទេសនានេះថា “**ន សន្តិ បុត្តា**” ជាដើម ។

# [ មិនមានអ្នកណាការពារមច្ចុបាន ]

រឿងខ្ញុំព្រះករុណាបានពោលពិស្តារហើយ ក្នុងការពណ៌នាព្រះគាថាក្នុងសហស្សវគ្គថា :-

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើត
និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃរបស់
លោកអ្នកដែលឃើញការកើតឡើង និងវិនាសទៅ
ប្រសើរជាង ។

ក្នុងកាលនោះ ព្រះសាស្តា ទ្រង់ជ្រាបថា នាងបដាចារាមានសេចក្តីសោកស្រាលស្តើងហើយ ទើបត្រាស់ថា " ម្នាលនាងបដាចារា ឈ្មោះថា បិយជនទាំងឡាយ មានបុត្រជាដើម រមែងមិនអាចជាទីពំនាក់ ឬជាទីជ្រកពួនរបស់

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ*

បុគ្គលអ្នកទៅកាន់បរលោកបានឡើយ ព្រោះហេតុនោះ ជនទាំងនោះសូម្បីមាន ក៏ឈ្មោះថា មិនមានដោយពិត ការដែលបណ្ឌិត ជម្រះនូវសីលឲ្យបរិសុទ្ធ ហើយជម្រះផ្លូវទៅទីទៅ

កាន់ព្រះនិព្វានដើម្បីខ្លួន រមែងគួរ ” ដូច្នេះហើយ កាលនឹង
ទ្រង់សម្តែងធម៌ ទ្រង់ភាសិតព្រះគាថានេះថា :

១០ ន សន្តិ បុត្តា តាណាយ   ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស   នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា   បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ   ខិប្បមេវ វិសោធយេ ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្ស ក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

មគ្គវគ្គវណ្ណនា រឿងនាងបដាចារា

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **តាណាយ** សេចក្ដីថា ដើម្បីភាពជាអ្នកការពារ គឺដើម្បីប្រយោជន៍ដល់ភាពជាទីពឹង ។

ញាតិ និងមិត្រអ្នកមានចិត្តល្អដ៏សេស វៀរបុត្រ និងមាតាបិតាចេញ ឈ្មោះថា ផៅពង្ស ។

បទថា **អន្តកេនាធិបន្នស្ស** គឺអ្នកត្រូវសេចក្ដីស្លាប់គ្របសង្កត់ ។ ពិតណាស់ ក្នុងបច្ចុប្បន្នកាល បិយជនទាំងឡាយ មានបុត្រជាដើម សូម្បីជាអ្នកអាចទីពឹងបាន ដោយការឲ្យបាយ និងទឹកជាដើម និងដោយការជួយកិច្ចការងារដែលកើតឡើងហើយ ( ប៉ុន្តែ ) ក្នុងវេលាស្លាប់ ឈ្មោះថារមែងមិនមានប្រយោជន៍ដល់ការការពារ គឺដើម្បីប្រយោជន៍ដល់ការជ្រកពួន ព្រោះជាអ្នកមិនអាចការពារនូវសេចក្ដីស្លាប់ ដោយឧបាយឯណានីមួយបាន , ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា “ **នត្ថិ ញាតីសុ តាណតា** ”។

បទថា **ឯតមត្ថវសំ** សេចក្ដីថា បណ្ឌិតដឹងនូវហេតុ

នោះ ពោលគឺការងារដែលជនទាំងនោះ ជាអ្នកមិនអាចជាទីពឹងពំនាក់ដល់គ្នានិងគ្នា ហើយជាអ្នកសង្រួម គឺរក្សា បានដល់ ឃុំគ្រងបារិសុទ្ធិសីល ៤ គប្បីជម្រះផ្លូវមានអង្គ ៨ ជាទីទៅកាន់ព្រះនិព្វានឲ្យបរិសុទ្ធដោយប្រញាប់ប្រញាល់ ។

ក្នុងវេលាចប់ទេសនា នាងបដាចារាបានតាំងនៅក្នុងសោតាបត្តិផល ជនជាច្រើន បានសម្រេចអរិយផលទាំង-ឡាយ មានសោតាបត្តិផលជាដើម ។៚

( រឿងនាងបដាចារា ចប់ )

8888888888888888888888

# មគ្គវគ្គវណ្ណនា ចប់

## វគ្គទី ២០ ចប់

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅ

០១ ឧ.ស លឹម ម៉េងជាវ ឧ.សិ អ៊ុង គឹមគី ..... ១០០០ $

០២ អ្នកស្រី ប៉ែន រម្មណីយ៍ និងស្វាមី + បុត្រ . ១៧០ $

០៣ ឧ.ស អៀម វ៉ន ឧ.សិ សុខ សៅរិទ្ធ ........ ៥០ $

០៤ ឧ.សិ ពូ ហ៊ាង ព្រមទាំងកូន ............ ៥០ $

០៥ ប្រាក់សល់ពីការជាវអដ្ឋកថានៃកម្មវិធីធ្វេង-
យល់អំពីព្រះពុទ្ធសាសនា .................. ៣២ $

០៦ ឧ.សិ ចាន់ លី ព្រមទាំងកូន .......... ២០ $

០៧ ឧ.សិ តាន់ ហ្គិច ............................ ២០ $

០៨ ឧ.សិ ជីវ គឹមសាន ព្រមទាំងកូន .......... ១០ $

០៩ ឧ.សិ ឈុន ស៊ិន កូនចៅ និងចៅទួត ...... ១០ $

១០ ឧ.សិ ផេង ឈូក ព្រមទាំងកូនចៅ .......... ១០ $

១១ ឧ.សិ ខ្វត សាំងគីម ព្រមទាំងកូនចៅ ...... ១០ $

១២ ឧ.សិ ព្រាប លួម ព្រមទាំងកូនចៅ .......... ១០ $

| | | |
|---|---|---|
| ១៣ | ឱ.សិ ជ គាង ព្រមទាំងបុត្រ ................ | ១០ $ |
| ១៤ | ឱ.សិ ថោង ពេញ ព្រមទាំងកូនចៅ .......... | ១០ $ |
| ១៥ | អ្នកស្រី ឡាយ ហ៊ុយអេង .................. | ១០ $ |
| ១៦ | អ្នកស្រី កាន់ សិរីមណី ព្រមទាំងបុត្រ ...... | ១០ $ |
| ១៧ | ឱ.សិ ឃួន មុន្នី ព្រមទាំងបុត្រ .............. | ១០ $ |
| ១៨ | ឱ.ស ហុង ជ្រិន ឱ.សិ ឡេង ចំរើន .......... | ១០ $ |
| ១៨ | ឱ.ស ង៉ួន ប៊ុន ស៊េត ឱ.សិ ប៊ុច គឹមអាន .. | ១០ $ |
| ១៩ | ឱ.សិ ទិត យ៉ុម និង ទិត សុខ ព្រមទាំងចៅ. | ៥ $ |
| ២០ | ឱ.ស ជីង វែង អៀវ ឱ.សិ គឹម យឿង និងបុត្រ. | ៥ $ |
| ២១ | ឱ.សិ ម៉ក់ គិន ព្រមទាំងបុត្រ ................. | ១ $ |
| ២២ | ឱ.សិ សាពយ គឹមលឿន ព្រមទាំងបុត្រ . | ២០០០០០ ៛ |
| ២៣ | ឱ.សិ អ៊ិន ឈួក ព្រមទាំងកូនចៅ .......... | ៥០០០០ ៛ |
| ២៤ | ឱ.សិ សេង ជី ............. .......... | ៤០០០០ ៛ |
| ២៥ | ឱ.សិ ចាន់ បូ ............. .......... | ៤០០០០ ៛ |
| ២៦ | ឱ.សិ គី គឹមហាប់ និងកូនចៅ . .......... | ៤០០០០ ៛ |
| ២៧ | ឱ.ស ជា កិរម្យ ឱ.សិ ហុង សុខហេង .... | ៤០០០០ ៛ |
| ២៨ | ផែង អង+សុហេង+ស៊ីរ+បញ្ញា+ជាម មួន+គុណានី | ៤០០០០៛ |

| | | | |
|---|---|---|---|
| ២៩ | លោក សុខ លីម អ្នកស្រី ហ៊្លួ ឃីម .... | | ៣០០០០ រ |
| ៣០ | ឧ.សិ លី ម៉េង | ............. .......... | ២០០០០ រ |
| ៣១ | ឧ.សិ ប៉ាន់ វួចឡាង | ... .......... | ២០០០០ រ |
| ៣២ | ឧបាសិកា ឃុន ណារី | ... .......... | ២០០០០ រ |
| ៣៣ | ឧ.សិ គង់ ទុំ | .......... ............ | ១០០០០ រ |
| ៣៤ | ឧ.សិ គី យក់ប៊ូយ | ......... ............ | ១០០០០ រ |
| ៣៥ | ឧ.សិ ប៉ាន គឹមហ៊ា និងបុត្រ ... | .......... | ១០០០០ រ |
| ៣៦ | ឧ.សិ ស្វែន | ............. .......... | ១០០០០ រ |
| ៣៧ | ឧ.សិ ប៉ាវ សាំងហេង | .......... ......... | ១០០០០ រ |
| ៣៨ | ឧ.សិ អាន លាងហេង + បុត្រ | ......... | ១០០០០ រ |
| ៣៩ | ឧ.សិ ធាយ ផល | .......... ............... | ៨០០០ រ |
| ៤០ | យាយ ខាន់ | .......... ............... | ៦០០០ រ |
| ៤១ | អៀម ខុន | .......... ............... | ៥០០០ រ |
| ៤២ | ឧ.សិ សាយ ស៊ុយគី | .......... ............... | ៥០០០ រ |
| ៤៣ | ឧ.សិ សូ សៀន | .......... ............... | ៥០០០ រ |
| ៤៤ | ឧ.សិ ថោង ពន្លក | .......... ............... | ៥០០០ រ |
| ៤៥ | សាយ ពៅ | .......... ............... | ៣០០០ រ |

៤៦ ឧ.សិ ខៀវ សាអែម ........... ................ ២០០០ ៛

## ពុទ្ធបរិស័ទនៅឃុំបន្ទាយដែកស្រុកកៀនស្វាយ ( កណ្តាល )

០១ ឧ.សិ យស ណា ព្រមទាំងបុត្រ .......... ១០០០០០ ៛

០២ លោកតែ ម៉េងហ៊ុយ អ្នកស្រីតាំង មុយអេង+បុត្រ.៥០០០០ ៛

០៣ ឧ.សិ អាន ស្រីម៉ៅ ................... ១០ $

០៤ លោក អ៊ុង តេងលាង ......... ............ ៤០០០០ ៛

០៥ លោក នៅ ផា អ្នកស្រី ជាលី ព្រមទាំងបុត្រ... ២០០០០ ៛

០៦ ឧ.សិ លឹម គួយ ព្រមទាំងបុត្រ ............ ២០០០០ ៛

០៧ ឧ.សិ ស៊ូ ជួក ព្រមទាំងបុត្រ ............ ២០០០០ ៛

០៨ ឧ.សិ យ៉ែម ព្រមទាំងបុត្រ ............ ១០០០០ ៛

០៩ ឧ.ស បែន ម៉េ ឧ.សិ ឯម វ៉ាត និងបុត្រ.. ១០០០០ ៛

១០ លោកប៉ក់ សុខម៉ា អ្នកស្រីធីតា និងបុត្រ. ១០០០០ ៛

១១ លោកគង់ ស៊ីថា អ្នកស្រីវត្ថនា និងបុត្រ. ១០០០០ ៛

១២ ឧបាសិកា រស់ សុភី ................ ១០០០០ ៛

១៣ ឧបាសិកា គ្រុប យឹន ព្រមព្រំងបុត្រ ....... ១០០០០ ៛

១៤ ឧ.ស រស់ ធូ ឧ.សិ ណែម និងបុត្រ ...... ១០០០០ ៛

១៥ ឧ.ស ហ៊ីង ទិត ព្រមទាំងបុត្រ ............ ១០០០០ ៛

១៦ ឧ.ស លាស់ មិន ឧ.សិ វ៉ាត និងបុត្រ .... ១០០០០ ៛
១៧ ឧ.ស រស់ សាន ឧ.សិ ង៉ាំ និងបុត្រ ..... ១០០០០ ៛
១៨ ឧ.ស លន ឧ.សិ យន ព្រមទាំងបុត្រ ..... ១០០០០ ៛
១៩ ឧបាសិកា រស់ ផូ ព្រមទាំងបុត្រ .......... ៥០០០ ៛
២០ ឧ.ស ព្រុំ ធឿន ឧ.សិ រស់ ផល និងបុត្រ. ៥០០០ ៛

## នាមពុទ្ធបរិស័ទស្រុកមណ្ឌលបូរីតាមរយៈឧបាសក ហេង វីរិទ្ធ

០១ ឧ.ស ហេង វីរិទ្ធ ព្រមទាំងក្រុមគ្រួសារ ....... ៥០០០០ ៛
០២ ឧ.ស លី តុងឃៀង ព្រមទាំងក្រុមគ្រួសារ .... ៤៥០០០ ៛
០៣ លោក ហ៊ុយ ចាន់ឈួង អ្នកស្រី លី សួរ+បុត្រ. ៤៥០០០ ៛
០៤ លោក ឱម សេដ្ឋា ................................ ៣០០០០ ៛
០៥ ឧ.សិ ស៊ូ ហួង ព្រមទាំងបុត្រ ..................... ២៥០០០ ៛
០៦ លោក ជូ ប៉ាន់ អ្នកស្រី លី ឡាយ ( លួយ ). ២២៥០០ ៛
០៧ លោក វ៉ាន់ ហាន់ អ្នកស្រី ហាង និមល + បុត្រ. ២២៥០០ ៛
០៨ លោក ចៅ រិទ្ធិហាង អ្នកស្រី ចៅ យិញ +បុត្រ. ២២៥០០ ៛
០៩ លោក ហេង វុទ្ធី ................................ ២០០០០ ៛
១០ ឧ.ស ចន្ថា ណាន់ កូមិពន្ធ ......................... ២០០០០ ៛
១១ លោកតា ឱម ប៊ុនហ៊ូ លោកយាយ គាត គិមលី ២០០០០ ៛
១២ ឧ.ស ឡុង គិមសេង ឧ.សិ អេ សង្វាន ........ ១៥០០០ ៛

| | | |
|---|---|---|
| ១៣ | ឧ.ស ឆាង ឧ.សិ រួម + នាងផល ............... | ១៥០០០ ៛ |
| ១៤ | ពេទ្យ ថន ព្រមទាំងកិរិយា ...................... | ១០០០០ ៛ |
| ១៥ | ឧ.ស ផុន សាអ៊ួន ឧ.សិ ប៉ែន ស៊ុម ............ | ១០០០០ ៛ |
| ១៦ | លោកតា កៅ ម៉េង លោកយាយ ឡុង ង៉ា ... | ១០០០០ ៛ |
| ១៧ | លោក ឌាម សុផាន់ អ្នកស្រី កៅ ឡែន + បុត្រ | ១០០០០ ៛ |
| ១៨ | លោក យ៉ាំ ជីហ្វាន់ ព្រមទាំងកិរិយា + បុត្រ . | ១០០០០ ៛ |
| ១៩ | លោក ធឹត ពលរិទ្ធ និងមាន សារ៉ុន ............. | ១០០០០ ៛ |
| ២០ | ឧ.ស អ៊ុក គួន ឧ.សិ ផាន់ ប៊ុនឡាត់ + បុត្រ... | ១០០០០ ៛ |
| ២១ | ឧ.ស ខូវ ថាង ឧ.សិ អ៊ុន សាវិន + បុត្រ ..... | ១០០០០ ៛ |
| ២២ | ឧ.ស ម៉ែន ម៉ុល ឧ.សិ តិម កួន និងតិម ផា .. | ១១០០០ ៛ |
| ២៣ | លោក ម៉ាន់ បូរ អ្នកស្រី អ៊ុច សុឃឿន ...... | ១០០០០ ៛ |
| ២៤ | ឧ.ស ណែម ហៀក ព្រមទាំងកិរិយា និងបុត្រ. | ១០០០០ ៛ |
| ២៥ | ឧ.សិ យាយ ធឿន ព្រមទាំងបុត្រ ................ | ១០០០០ ៛ |
| ២៦ | លោក ថោង ភារម្យ អ្នកស្រី ឡៅ ធី + បុត្រ. | ១០០០០ ៛ |
| ២៧ | ឧ.ស លាច សាវ៉េត និងនាងយឹម សោរ៉ុ ....... | ១០០០០ ៛ |
| ២៨ | ឧ.សិ ម៉ោល យ៉ុម ព្រមទាំងកូនចៅ ........... | ១០០០០ ៛ |
| ២៩ | ឧ.សិ ភួង គិមហេង ព្រមទាំងបុត្រ ........... | ១០០០០ ៛ |
| ៣០ | លោក សុខ មារឌី ..................... ........... | ១០០០០ ៛ |

៣១ អ៊ុច យ៉ោង ព្រមទាំងកូនចៅ .......... ........... ១០០០០ ៛

៣២ ឧ.សិ គិម យ៉ុម ព្រមទាំងបុត្រ ....... ........... ១០០០០ ៛

៣៣ ឧ.សិ ចាយ អេង .................... ........... ១០០០០ ៛

៣៤ លោកតាអិន យាយឡាយ + តាវ៉ិត យាយញ៉ាញ.១០០០០ ៛

៣៥ លោកយាយ ឡុង ព្រមទាំបុត្រ ...... ........... ១០០០០ ៛

៣៦ ឧ.សិ ចៅ ហាក់មន្ដា ព្រមទាំងបុត្រ .. ........... ១០០០០ ៛

៣៧ លោក ជុំ សំនិត អ្នកស្រី សុខ វ៉ាន្នី + បុត្រ .. ១០០០០ ៛

៣៨ ឧ.ស គ្រុយ តាំងឡេង ............................ ៦០០០ ៛

៣៩ យាយ តន និងយាយ វ៉េត .......................... ៦០០០ ៛

៤០ ឧ.សិ យូ ម៊ុយគា ព្រមទាំងបុត្រ ................ ៥០០០ ៛

៤១ អ្នកស្រី ម៉ាន់ សាវរី ព្រមទាំងបុត្រ ............... ៥០០០ ៛

៤២ អ្នកស្រី ម៉ង់ វ៉ារី ព្រមទាំងបុត្រ ............... ៥០០០ ៛

៤៣ លោក លួន ជូ និងបែ ស ............... ៥០០០ ៛

៤៤ បែ ហួត ជី ព្រមទាំងបុត្រ ............... ៥០០០ ៛

៤៥ ឧ.សិ លឹម គិមរិច ............... ៥០០០ ៛

៤៦ ឧ.សិ ផន អ៊ុន ព្រមទាំងបុត្រ ............... ៥០០០ ៛

៤៧ ឧ.ស យិវ គិមឡោ ............... ៥០០០ ៛

៤៨ ហ៊ា អ៊ុន បែ ខេង ............... ៥០០០ ៛

| | | | |
|---|---|---|---|
| ៤៩ | លោក ហ៊ួត ឡាស់ និងបុត្រ | ............... | ៥០០០ ៛ |
| ៥០ | លោកម៉ាក់ បាន អ្នកស្រី ជាត ដា ( ញាញ់ ). | | ៥០០០ ៛ |
| ៥១ | លោក ធី និងអ្នកស្រី យ៉ា | ............... | ៥០០០ ៛ |
| ៥២ | លោក ទូច និងអ្នកស្រី ចារ៉ា | ............... | ៥០០០ ៛ |
| ៥៣ | ឧ.ស លាច សាវុត ឧ.សិ ខាំ ង៉ួនលីន | ......... | ៥០០០ ៛ |
| ៥៤ | ឧ.សិ ជូ វ៉ាន់ជិន | ............... | ៥០០០ ៛ |
| ៥៥ | ឧ.សិ ទុយ ធឹយ និងបុត្រ | ............... | ៥០០០ ៛ |
| ៥៦ | ឧ.សិ សេង តាំងអៀម | ............... | ៥០០០ ៛ |
| ៥៧ | ឧ.សិ ចាន់ រ៉ែម និងបុត្រ | ............... | ៥០០០ ៛ |
| ៥៨ | សម្បត្តិ នាង រី + បុត្រ | ............... | ៥០០០ ៛ |
| ៥៩ | ឧ.សិ ស៊ីវ គិមយន់ ហៅម៉ៅ និងបុត្រ | ......... | ៥០០០ ៛ |
| ៦០ | លោក អ៊ួន អ្នកស្រី អឿត និងបុត្រ | ............ | ៥០០០ ៛ |
| ៦១ | កញ្ញា តុប គិមទី | ............. | ៥០០០ ៛ |
| ៦២ | ញ៉ឹក ពន្ធារី | ............. | ៥០០០ ៛ |
| ៦៣ | លោកយាយ កោគ ហាច និងកូនចៅ | ........... | ៥០០០ ៛ |
| ៦៤ | លោក ឡាយ សេងហួត | ............. | ៥០០០ ៛ |
| ៦៥ | ឧ.សិ ផាន់ ហ៊ាក និងបុត្រ | ............. | ៥០០០ ៛ |
| ៦៦ | ឧ.ស ថាប់ រ៉ាយ និងបុត្រ | ............. | ៥០០០ ៛ |

| | | |
|---|---|---|
| ៦៧ | យាយ ឡាំ វ៉ាត់ ............. | ៥០០០ ៛ |
| ៦៨ | ឧ.ស ហ៊ុន ឌី ឧ.សិ ស៊ិន ហូរ និងបុត្រ .......... | ៥០០០ ៛ |
| ៦៩ | ឧ.ស ហុន ឧ.សិ យាយង៉ុប និងបុត្រ. ............ | ៥០០០ ៛ |
| ៧០ | ឧ.សិ ចាន់នី និងបុត្រ ............. | ៥០០០ ៛ |
| ៧១ | ឧ.សិ យាយរឿន និងបុត្រ ............. | ៥០០០ ៛ |
| ៧២ | ឧ.ស គាំ ឧ.សិ សារូ ............. | ៥០០០ ៛ |
| ៧៣ | នាង ចន្ទ្រា និងបុត្រ ............. | ៥០០០ ៛ |
| ៧៤ | ឧ.ស ទៀវ ប៊ុនរឿម និងគ្រិត សន្ធូ និងបុត្រ ... | ៥០០០ ៛ |
| ៧៥ | លួន ចេក និងនាង ជា + បុត្រ ............. | ៥០០០ ៛ |
| ៧៦ | លោក លិម ឆាយ និងអ្នកស្រី សុហៀង ....... | ៥០០០ ៛ |
| ៧៧ | ឧ.សិ សូ ផាត ....... | ៥០០០ ៛ |
| ៧៨ | ឧ.សិ គួច វ៉ារុន និងបុត្រ ............. | ៥០០០ ៛ |
| ៧៩ | អ្នកស្រី តាន់ ង៉ាន់ និងបុត្រ ............. | ៥០០០ ៛ |
| ៨០ | លោក តាន់ យក់យាង ............. | ៥០០០ ៛ |
| ៨១ | ឧ.សិ តាន់ គិមទាវ ............. | ៥០០០ ៛ |
| ៨២ | ឧ.សិ មួង គិម ............. | ៥០០០ ៛ |
| ៨៣ | ឧ.ស កែ អាន និងឧ.សិ ហៃ ស៊ាន និងបុត្រ .. | ៥០០០ ៛ |
| ៨៤ | យាយ អឿង និងបុត្រ ............. | ៥០០០ ៛ |

| | | | |
|---|---|---|---|
| ៨៥ | ឧ.ស ណុប សុភាទូច ឧ.សិ សម ពៅ | .......... | ៥000 ៛ |
| ៨៦ | ឧ.ស កែ មាស ឧ.សិ ខេង វ៉ុង និងបុត្រ | ........ | ៥000 ៛ |
| ៨៧ | ឧ.ស វង់ ម៉ៅ និងកូនចៅ | ............. | ៥000 ៛ |
| ៨៨ | ឧ.សិ និម វ៉ាន់ | ............. | ៥000 ៛ |
| ៨៩ | ឧ.សិ ណាប់ គីវ | ............. | ៥000 ៛ |
| ៩០ | ឧ.សិ ចាន់ ប៊ុនលី ( សារ៉េង ) | ............. | ៥000 ៛ |
| ៩១ | ឧ.សិ ចន្ទី និងបុត្រ | ............. | ៥000 ៛ |
| ៩២ | ឧ.សិ ឡាយ ហ៊ុនគី | ............. | ៥000 ៛ |
| ៩៣ | លោក ង៉ួន ប៊ុនរិន និងភរិយា | ............. | ៥000 ៛ |
| ៩៤ | ឧ.សិ ជៀប ហេង និងបុត្រ | ............. | ៥000 ៛ |
| ៩៥ | ឧ.សិ ជៀប ហាំ និងបុត្រ | ............. | ៥000 ៛ |
| ៩៦ | ឧ.សិ ហេង ស៊ីនួន ព្រះស្រែ | ............. | ៥000 ៛ |
| ៩៧ | ឧ.ស សៅ ថងងិន ឧ.សិ ប៊ូ ង៏ | ............. | ៥000 ៛ |
| ៩៨ | យាយ ប៉ាច ម៉ៅ | ............. | ៥000 ៛ |
| ៩៩ | ឧ.ស ស៊ុំ ជា ឧ.សិ ចាន់ ហម | ............. | ៥000 ៛ |
| ១០០ | ឧ.សិ ប្រាង សំបាន | ............. | ៥000 ៛ |
| ១០១ | ឧ.សិ មុំ | ............. | ៥000 ៛ |
| ១០២ | ឧ.សិ ជុក ឈឿត | ............. | ៥000 ៛ |

១០៣ ឧ.សិ តឿ គិមលាន ............. ៥០០០ ៛

១០៤ ឧ.សិ ឡាំ អ៊ិតនា + ទេស ខេង ............. ៥០០០ ៛

១០៥ ឧ.ស ចាន់ ជួក ឧ.សិ ពិន លាងស៊ីម ........... ៥០០០ ៛

១០៦ ឧ.សិ ប៊ុន យ៉ុម និងបុត្រ ............. ៥០០០ ៛

១០៧ ឧ.ស យាង យាន ឧ.សិ រស់ វន ............. ៤០០០ ៛

១០៨ ឧ.សិ ឡាន់ វ៉ាត់ ............. ៤០០០ ៛

១០៩ ឧ.សិ ឈឹង និងបុត្រ ............. ៣០០០ ៛

១១០ ឧ.សិ ម៉ៅ ជី និងបុត្រ ............. ៣០០០ ៛

១១១ ឧ.ស ជ័យ វុន និងភរិយា ............. ៣០០០ ៛

១១២ ឧ.សិ ស៊ី ម៊ីន ............. ៣០០០ ៛

១១៣ ឧ.សិ ជូ ស៊ីម៉ុន និងបុត្រ ............. ៣០០០ ៛

១១៤ ឧ.សិ សន ហាន និងបុត្រ ............. ២៥០០ ៛

១១៥ ឧ.សិ មាស ចាន់សុង ............. ២០០០ ៛

១១៦ ឧ.សិ កេត សុនួន ............. ២០០០ ៛

១១៧ ឧ.សិ ឡាយ ហឿន ............. ២០០០ ៛

១១៨ ឧ.សិ យាយ រ៉ម ............. ២០០០ ៛

១១៩ យាយ វង នុយនិងបុត្រ ............. ២០០០ ៛

១២០ ឧ.សិ កែវ អ៊ាន ............. ២០០០ ៛

| | | | |
|---|---|---|---|
| ១២១ | ឧ.សិ រិន ឌិន | ............. | ២០០០ ៛ |
| ១២២ | ឧ.សិ មុយ គា | ............. | ២០០០ ៛ |
| ១២៣ | ឧ.ស ប៊ុន សុវណ្ណ ឧ.សិ ចាន់ គិមធូត | .......... | ២០០០ ៛ |
| ១២៤ | យាយ ធំ | ............. | ២០០០ ៛ |
| ១២៥ | សោម សារី ភរិយា និងបុត្រ | ............. | ២០០០ ៛ |
| ១២៦ | ឧ.សិ និល យ៉ាំ និងបុត្រ | ............. | ២០០០ ៛ |
| ១២៧ | ឧ.ស យែម ឧ.សិ ឈៀប និងបុត្រ | ............. | ២០០០ ៛ |
| ១២៨ | ឧ.សិ កួយ នាង | ............. | ២០០០ ៛ |
| ១២៩ | តា ឌុច និងយាយ ជិន | ............. | ២០០០ ៛ |
| ១៣០ | មិនមានឈ្មោះម្នាក់ | ............. | ២០០០ ៛ |
| ១៣១ | ទូច លី | ............. | ១៥០០ ៛ |
| ១៣២ | ឧ.ស អ៊ីង សារ៉េត និងកូនចៅ | ............. | ៥០០០ ៛ |

**នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅតាមរយៈ ឧ.សិ បញ្ញាវតី**

| | | | |
|---|---|---|---|
| ០១ | ឧ.សិ ជួន ស្រី និងស្វាមី + បុត្រ | ............. | ៥០ $ |
| ០២ | ឧ.សិ តឹក អេងគី ព្រមទាំងកូនចៅ | ............. | ៥០ $ |
| ០៣ | ឧ.សិ កាំង ប៉ោទៀង និងស្វាមី + បុត្រ | .......... | ២០ $ |
| ០៤ | ឧ.សិ ជួន ស៊ីមហ៊ិន ព្រមទាំងកូនចៅ | ........... | ២០ $ |
| ០៥ | ឧ.សិ អ៊ីង គីមរស់ ព្រមទាំងកូនចៅ | ........... | ២០ $ |

| | | | |
|---|---|---|---|
| ០៦ | និស្សិត ប៉ិច មករា និងចៅស្រីស្រីលីន ............ | ១០ | $ |
| ០៧ | ឧ.សិ អៀ ឈុនអេង ព្រមទាំងកូនចៅ ............ | ៥ | $ |
| ០៨ | ឧ.ស ម៉ៅ ម៉ុង ឧ.សិ ប៉ាត ម៉េង និងកូនចៅ ........ | ៥ | $ |
| ០៩ | កុមារា អ៊ុមវុទ្ធ ឡេង .......................... | ២ | $ |
| ១០ | ឧ.សិ ស៊ាប ស៊ី .......................... | ១ | $ |
| ១១ | ឧ.សិ ជីង គីមស្រ៊ី និងកូនចៅ .......................... | ១ | $ |
| ១២ | ឧ.សិ យិន ជួក និងកូនចៅ .......................... | ១ | $ |
| ១៣ | ឧ.សិ ស្រី ពៅ .......................... | ១ | $ |
| ១៤ | ឧ.សិ ប្រាក់ ស្រី និងកូនចៅ .......................... | ១ | $ |
| ១៥ | ឧ.សិ ញ៉េម រឿង និងបុត្រ .......................... | ១ | $ |
| ១៦ | ឧ.ស ទា សុង ឧ.សិ ង៉ោ ចាន់ខេង + កូនចៅ .. | ៥០០០០ | ៛ |
| ១៧ | ឧ.សិ ជា ណាយ និងកូនចៅ ...................... | ៤០០០០ | ៛ |
| ១៨ | ឧ.ស មុី សារ៉េន ភរិយា ព្រមទាំងបុត្រ ........... | ៣០០០០ | ៛ |
| ១៩ | ឧ.សិ អាយ ស្រី ស្វាមី ព្រមទាំងបុត្រ .......... | ២០០០០ | ៛ |
| ២០ | ឧ.ស តាក គីអ៊ាង ឧ.សិ ឱម លាងគ្រី+កូនចៅ. | ២០០០០ | ៛ |
| ២១ | ឧ.សិ ជិត គាវ ព្រមទាំងកូនចៅ .......... | ២០០០០ | ៛ |
| ២២ | ឧ.សិ ជា សារីម និងកូនចៅ .......... | ២០០០០ | ៛ |
| ២៣ | ឧ.សិ សោម យ៉ាន ព្រមទាំងកូនចៅ .......... | ២០០០០ | ៛ |

២៤ ឧ.សិ គ្រុយ លាងចាយ និងកូនចៅ .......... ២០០០០ ៛

២៥ ឧ.ស អ៊ុក សំណាង ឧ.សិ ប៉ាល់ ធីតា+កូនចៅ. ១០០០០ ៛

២៦ ឧ.ស ហង្ស វណ្ណៈ ភរិយា ព្រមទាំងបុត្រ ..... ១០០០០ ៛

២៧ ឧ.សិ ឈួន អួន ព្រមទាំងកូនចៅ ..... ១០០០០ ៛

២៨ ឧ.សិ សាន ជា ព្រមទាំងកូនចៅ ..... ១០០០០ ៛

២៩ ឧ.ស ឡឿក សំហៀង ឧ.សិ សោម សាន+កូនចៅ. ១០០០០ ៛

៣០ ឧ.ស ជិន លីម+ភរិយា ព្រមទាំងបុត្រ ..... ១០០០០ ៛

៣១ ឧ.សិ ផន ចន្ថា ស្វាមី និងបុត្រ ..... ១០០០០ ៛

៣២ ឧ.សិ សឹម ផាន ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៣ ឧ.សិ ហួយ ជន ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៤ ឧ.សិ កៅ គាវ ស្វាមី និងបុត្រ ..... ១០០០០ ៛

៣៥ ឧ.សិ តុប សៀកមួយ ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៦ ឧ.សិ ឈួន សុ ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៧ ឧ.សិ ឌី សុភី ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៨ ឧ.សិ ញ៉ឹក ទូច ព្រមទាំងកូនចៅ ..... ១០០០០ ៛

៣៩ ឧ.សិ តឹក ណៃជា ព្រមទាំងកូនចៅ ..... ១០០០០ ៛

៤០ កុង ជាន យាយ ណី ព្រមទាំងកូនចៅ ..... ១០០០០ ៛

៤១ ឧ.សិ សេង វ៉ាន្នី ព្រមទាំងកូនចៅ ..... ១០០០០ ៛

| | | | |
|---|---|---|---|
| ៤២ | ឧ.សិ ហ៊ិន ដារុង ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៣ | ឧ.ស ទុយ ភាពិរះ ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៤ | ឧ.ស អៀម សុខុន ឧ.សិ សួន ដា និងបុត្រ . | | ១០០០០ រ |
| ៤៥ | ឧ.សិ ហ៊ុង ទូច ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៦ | ឧ.សិ ទឹម យ៉ុង ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៧ | ឧ.សិ ជុំ ឆាយ ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៨ | ឧ.សិ ឡេា ឈុនអេង ព្រមទាំងកូនចៅ | ..... | ១០០០០ រ |
| ៤៩ | ឧ.សិ ហេង ចន្ទកុលសុក: និងក្រុមគ្រួសារ .. | | ១០០០០ រ |
| ៥០ | ឧ.សិ សុខ ស៊ីម ព្រមទាំងបុត្រ | ..... | ១០០០០ រ |
| ៥១ | ឧ.សិ សេ់ ជិន ព្រមទាំងញាតិ | ..... | ១០០០០ រ |
| ៥២ | ឧ.សិ តូច លីណា៉ា ស្វាមី និងបុត្រ | ..... | ១០០០០ រ |
| ៥៣ | ឧ.ស សំ សាន កិរិយា ព្រមទាំងបុត្រ | ..... | ១០០០០ រ |
| ៥៤ | ឧ.សិ យស ទឹម ស្វាមី ព្រមទាំងបុត្រ | ..... | ១០០០០ រ |
| ៥៥ | ឧ.ស គង់ សាន (វត្តសំពៅមាន) | ..... | ៥០០០ រ |
| ៥៦ | ឧ.សិ សៃ ទៀង ព្រមទាំងកូនចៅ | ..... | ៥០០០ រ |
| ៥៧ | ឧ.ស កែវ សឿន ព្រមទាំងកូនចៅ | ..... | ៥០០០ រ |
| ៥៨ | ឧ.សិ ឈឹម សុវណ្ណ ព្រមទាំងកូនចៅ | ..... | ៥០០០ រ |
| ៥៩ | ឧ.សិ ប្រាក់ សារឹមនារីរ័ត្ន | ..... | ៥០០០ រ |

| | | | |
|---|---|---|---|
| ៦០ | ឧ.សិ ឡេង សុធន្នី និងកូនចៅ | ..... | ៥០០០ ៛ |
| ៦១ | ឧ.សិ អ៊ុក វណ្ណថា ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦២ | ឧ.សិ ស៊ិន វឿន ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៣ | គួច សុជាតិ | .............................. | ៥០០០ ៛ |
| ៦៤ | ឧ.សិ ហួត ជី ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៥ | ឧ.សិ កុយ អុន ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៦ | ឧ.សិ ទិត ផាង ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៧ | ឧ.សិ ដួង វណ្ណថន ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៨ | ឧ.សិ ឃុត គឹមថន ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៦៩ | ឧ.ស តុង ណេង ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៧០ | ឧ.សិ តាន់ យុហ៊ាង ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៧១ | ឧ.សិ ទុយ សាន ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៧២ | ឧ.សិ អៀង ប៉ុក ព្រមទាំងកូនចៅ | ..... | ៥០០០ ៛ |
| ៧៣ | ឧ.សិ ជូ ធន និងស្វាមី ព្រមទាំងបុត្រ | ..... | ៥០០០ ៛ |
| ៧៤ | ឧ.សិ ម៉ម ឈាំងសាត ព្រមទាំងកូនចៅ | ..... | ៤០០០ ៛ |
| ៧៥ | ឧ.ស កូវ ធីម ឧ.សិ គីម ឡាយ + កូនចៅ .. | | ៤០០០ ៛ |
| ៧៦ | ឧ.សិ សេក យីម ព្រមទាំងកូនចៅ | ..... | ៣០០០ ៛ |
| ៧៧ | ឧ.សិ ម៉ម ម៉ុន | ........................... | ៣០០០ ៛ |

៧៨ ឧ.សិ ជុំ ណាង ព្រមទាំងកូនចៅ ..... ២៥០០ ៛
៧៩ ឧ.សិ គុយ យ៉ុន ព្រមទាំងកូនចៅ ..... ២០០០ ៛
៨០ ឧ.សិ សៅ សុផារី ព្រមទាំងកូនចៅ ..... ២០០០ ៛
៨១ ឧ.សិ សេង លី ព្រមទាំងកូនចៅ ..... ២០០០ ៛
៨២ ឧ.សិ ទិត រួចណៃ ព្រមទាំងកូនចៅ ..... ២០០០ ៛
៨៣ ឧ.សិ គ្រួច សារី ព្រមទាំងកូនចៅ ..... ២០០០ ៛
៨៤ ឧ.សិ យាយ ជុន .................. ១០០០ ៛

**នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅតាមរយៈ ឧ.សិ សុខ ភួង**

០១ ឧ.សិ សុខ ភួង ឧ.សិ សុខ ផៃ ព្រមទាំងកូនចៅ ... ១០ $
០២ ឧ.សិ ស៊ុប គឹមអឿន ព្រមទាំងកូនចៅ .......... ៥ $
០៣ ឧ.ស គ្រី សុខុន ឧ.សិ ម៉ិច ហ៊ិន .......... ៥ $
០៤ ឧ.ស តូច ផុន ឧ.សិ ហ៊ុយ ហុង និងបុត្រ ......... ៥ $
០៦ អ្នកស្រី រ័ត្ន សុផៃ និងស្វាមី (សហរដ្ឋ) ......... ៥ $
០៧ លោក រ័ត្ន វាសនា (សហរដ្ឋ) .......... ៥ $
០៨ ឧ.សិ ទី សុធី ព្រមទាំងកូនចៅ .......... ៥ $
០៩ ឧ.សិ អ៊ាង ណៃហ៊ាង ....................... ៥ $
១០ ឧ.សិ សោម សុវណ្ណារ៉េត ...................... ១ $
១១ ឧ.សិ ប៉ាត់ កំសាន្ត ព្រមទាំងកូនចៅ .......... ៦០០០០ ៛

១២ ឧ.សិ លី ហ្គិចឡាង ស្វាមី និងបុត្រ .......... ២០០០០ ៛

១៣ ឧ.សិ លី គុយហ៊ួ ព្រមទាំងកូនចៅ .......... ១០០០០ ៛

១៤ ឧ.សិ ស្រេង គីម ស្វាមី និងបុត្រ .......... ១០០០០ ៛

១៥ ឧ.ស វ៉ា ហុង ឧ.សិ លូ ឡាយ និងកូនចៅ .. ១០០០០ ៛

១៦ ឧ.សិ មាស រស់ និងប្អូន ព្រមទាំងក្មួយ ....... ១០០០០ ៛

១៧ ឧ.សិ ពៅ ចាន់សេនា ស្វាមី និងបុត្រ ........ ១០០០០ ៛

១៨ ឧ.សិ ជិន ស៊ីនិន ស្វាមី និងបុត្រ .......... ១០០០០ ៛

១៩ ឧ.សិ ពេញ ហាន និងក្រុមគ្រួសារ .......... ៥០០០ ៛

២០ ឧ.សិ កែវ សង្វ៉ាន ស្វាមី និងបុត្រ .......... ៥០០០ ៛

## នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅតាមរយៈ ឧ.សិ បាន រ៉ូ

០១ ឧ.សិ រស់ ហុង ព្រមទាំងកូនចៅ .......... ១០ $

០២ ឧ.សិ ស៊ុន ជា ព្រមទាំងកូនចៅ .......... ១០០០០៛+ ២ $

០៣ ឧ.សិ បាន រ៉ូ + អ្នកម្ដាយអឹម យ៉ម+បងប្អូន .... ៤០០០០ ៛

០៤ ឧ.សិ បាន ឌី + ស្វាមី និងបុត្រ ........... ១០០០០ ៛

០៥ ឧ.សិ បាន ឌិន + ស្វាមី និងបុត្រ ........... ១០០០០ ៛

០៦ ឧ.សិ ធំ ឧ.សិ ស្រេង ព្រមទាំងបុត្រ ........... ១០០០០ ៛

០៧ ឧ.សិ គឹម អ៊ា ព្រមទាំងបុត្រ ........... ១០០០០ ៛

០៨ ឧ.សិ យុន អេង ព្រមទាំងបុត្រ ........... ១០០០០ ៛

| | | |
|---|---|---|
| ០៩ | ឧ.ស ទេព ផនសុខា ព្រមទាំងកូនចៅ .......... | ១០០០០ ៛ |
| ១០ | ឧ.សិ កែវ ចិន្តា ស្វាមី និងបុត្រ ........... | ១០០០០ ៛ |
| ១១ | ឧ.សិ វ៉ន ស៊ីណាត ..................... | ១០០០០ ៛ |
| ១២ | លោក មាស ទីន និងភរិយា ស្រីឃួច ....... | ១០០០០ ៛ |
| ១៣ | លោក សុង ងួន និងភរិយា ហេង សៀអ៊ី .... | ១០០០០ ៛ |
| ១៤ | ឧ.សិ មាឃ ស៊ុំ ព្រមទាំងកូនចៅ ........... | ១០០០០ ៛ |
| ១៥ | ឧ.សិ ឃឹម ហ្គេចអ៊ូច ព្រមទាំងកូនចៅ ......... | ១០០០០ ៛ |
| ១៦ | ឧ.សិ តែ គឹមមួយ ព្រមទាំងកូនចៅ .......... | ១០០០០ ៛ |
| ១៧ | ឧ.ស ផុន លី ព្រមទាំងកូនចៅ ........... | ៥០០០ ៛ |
| ១៨ | ឧ.ស គឹម លុច ឧ.សិ គឹម ស៊ូ និងបុត្រ ..... | ៥០០០ ៛ |
| ១៩ | ឧ.ស ហេង ឡៀមបែល .................. | ៥០០០ ៛ |
| ២០ | ឧ.ស បូ ឧ.សិ ណៃ ព្រមទាំងបុត្រ .......... | ៥០០០ ៛ |
| ២១ | ឧ.ស ស៊ីម លីម ឧ.សិ គឹម ស៊ុនធារី +បុត្រ.. | ៥០០០ ៛ |
| ២២ | លោក ចាន់ ថុល +ភរិយា ចាន់ ណាត +បុត្រ .. | ៥០០០ ៛ |
| ២៣ | ឧ.ស ពេញ ឧ.សិ ហ៊ីង ព្រមទាំងបុត្រ ........ | ៥០០០ ៛ |
| ២៤ | ឧ.សិ ពីង ព្រមទាំងកូនចៅ ............. | ៥០០០ ៛ |

***************************